00844166

E1/120.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Sep-2012, 14:22
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១០៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ច័ន្ទ តារាស្មី

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ហ្វីលីពីន ស៊ុតហ្ស៍

*(Ms. Philipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីន្ធូហ្វ៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក នង សុផង់ (TCW-480) | ខ្មែរ |

## ខ្ញបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នង សុផង់** (TCW-480)

សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖........................................................ទំព័រ ៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ កិច្ចដំណើរការសវនាការពិភាក្សាដេញដោល ដែលនឹងបន្តការតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា ចំពោះសាក្សី នង សុផង់។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សី លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៣:២១]

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែជនជាប់ចោទលោក អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ។ ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់រយៈពេលពេញ១ថ្ងៃ នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ លោក អាកទួរ វែកគែន ជាមេធាវីការពារក្តីអន្តរជាតិរបស់ក្រុមលោក ខៀវ សំផន នឹងមកដល់សាលសវនាការ ប្រហែលជានៅម៉ោងប្រាំបួនព្រឹកនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ មុននឹងបន្តកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី នៃរឿងក្តីក្នុងសំណុំរឿង០០២ ទាំងអស់ឲ្យបានជ្រាបថា នៅក្នុងកិច្ចដំណើរការសវនាការក្នុងសប្តាហ៍នេះ ដែលចាប់ផ្តើមពីថ្ងៃនេះ នៅថ្ងៃ៣ ខែកញ្ញា ឆ្នាំ២០១២ នេះទៅ និងថ្ងៃបន្តបន្ទាប់ លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ មានធុរៈផ្ទាល់ខ្លួន គាត់មិនអាចចូលរួម នៅក្នុងកិច្ចដំណើរការសវនាការបាន។ បន្ទាប់ពីយើង

បានពិគ្រោះយោបល់ជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំង លោកស្រី ក្លូឌា ហ្វេនស៍ ជាចៅក្រមបម្រុងអន្តរជាតិ ជំនួសកន្លែងចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដែលអវត្តមានរហូតដល់ពេលណា លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការអនុវត្តនេះ ដោយផ្អែកតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

សេចក្ដីសម្រេចលើពាក្យសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញ១ថ្ងៃនេះ។

លោកវេជ្ជបណ្ឌិត អែម សារឿន គ្រូពេទ្យទទួលពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ បានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ខ្លាំង នោមញឹក ឈឺចង្កេះ និងឈឺខ្នង និងបានផ្ដល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

[០៩:០៦:១៧]

នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់លោក អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។ បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពី

ចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

[០៩:០៧:១២]

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន សូមអរគុណ និងសូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ភាគី និងសួស្តីលោកសាក្សី នង សុផង់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ជាដំបូង ខ្ញុំសូមសួរបន្តនឹងអ្វីដែលយើងបានពិភាក្សាគ្នាកាលពីសប្តាហ៍មុន។ បន្ទាប់មកយើងនឹងបន្តទៅមុខទៀត ដូចដែលខ្ញុំបានបញ្ជាក់កាលពីសប្តាហ៍មុន យើងនឹងនិយាយអំពីសារទូរលេខដោយលម្អិត។ នៅពេលដែលយើងពិភាក្សាហេតុការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោកបានរៀបរាប់អំពីការទទួលជ័យជម្នះក្រោយពីថ្ងៃ១៧ មេសា នោះ។ ខ្ញុំបានសួរលោក ហើយលោកបាននិយាយថាលោកបានរៀបចំឯកសារជ័យជម្នះនោះ ដើម្បីយកមកផ្សព្វផ្សាយតាមវិទ្យុ ហើយលោកក៏បានពន្យល់ផងដែរថា សារនោះគឺមិនបាន គេបានសរសេរជាលេខកូដសម្ងាត់នោះទេ គឺសរសេរលក្ខណៈរៀបរាប់អំពីជ័យជម្នះតែម្តង។

[០៩:០៩:០១]

ខ្ញុំនឹងធ្វើការអាននូវប្រតិចារឹក ដែលគេបានសរសេរនៅក្នុងការផ្សព្វផ្សាយវិទ្យុចុះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយសូមឲ្យលោកបញ្ជាក់ថាតើអ្វីដែលសរសេរនៅក្នុងអត្ថបទដែលខ្ញុំនឹងអាននេះឆ្លើយតបដូចនឹងខ្លឹមសារដែលលោកបានជួយរៀបចំសម្រាប់ការផ្សព្វផ្សាយនៅថ្ងៃ១៧ មេសា នោះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រមជាទីគោរព! ឯកសារនេះគឺលេខ E/118 គឺជាការដកស្រង់ចេញពីកាសែត *ហ្វ៊ីប៊ីស* ជាអកុសលផ្នែកត្រង់ដែលខ្ញុំអាននេះមិនមានជាភាសាបារាំង និងខ្មែរនោះទេ ក៏ប៉ុន្តែ

យើងស្នើសុំឲ្យមានការបកប្រែរួចមកហើយ។ ដូច្នេះយើងខ្ញុំសូមអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះអានផ្នែកដែលសង្ខេបមួយចេញពីអត្ថបទនេះ ដើម្បីឲ្យសាក្សីនោះ បញ្ជាក់ថាតើគាត់ស្គាល់នូវខ្លឹមសារទាំងអស់នេះដែរឬទេ? ERN ជាភាសាអង់គ្លេសគឺ 00166976។

លោកប្រធាន យើងខ្ញុំសូមអនុញ្ញាត ការអនុញ្ញាតធ្វើការអានដំណកស្រង់ -- ការដកស្រង់ខ្លីចេញពីអត្ថបទនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[០៩:១០:២៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ភាគីទាំងអស់នៅក្នុងនេះ និងនៅក្រៅបន្ទប់សវនាការ។

នេះគឺជារបាយការណ៍មួយ វាមិនមែនជាសារមួយពិតប្រាកដ ដែលបានផ្សព្វផ្សាយនោះតែម្ដងនោះទេ។ អ្វីដែលខ្ញុំបានឮនោះគឺថា សារនោះត្រូវបានផ្សាយតាមវិទ្យុ។ ក៏ប៉ុន្តែនេះបានបង្ហាញអង្គការផ្លូវការមួយដែលជាអ្នកយកសារនេះ យកមកសរសេរឡើងវិញ។ យើងមិនដឹងថា ខ្លឹមសារនោះជាខ្លឹមសារពាក្យដើម ឬក៏យ៉ាងណាក៏នោះទេ ដោយវាជាភាសាអង់គ្លេសទៀត។ ដូច្នេះហើយខ្ញុំសូមជំទាស់ទៅលើការអាននូវអត្ថបទចេញពីខ្លឹមសារនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

[០៩:១១:២៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគាំទ្រលោកមេធាវី ម៉ៃខល កាណាវាស ចំពោះការជំទាស់នេះ ហើយម្យ៉ាងទៀតដោយសារអត្ថបទនេះមិនមែនជាអត្ថបទភាសាដើម ជាភាសាខ្មែរ ហើយត្រូវបកប្រែជាត្រឡប់ទៅត្រឡប់មក។ អ៊ីចឹងវាធ្វើឲ្យព័ត៌មានដែលនឹងផ្ដល់ជូនសាក្សីនេះមានភាពច្របូកច្របល់ មិនអាចយល់ថាវាជាព័ត៌មានដែលសាក្សីបានស្ដាប់នៅពេលនោះ ឬយ៉ាងណាទេ?

ម្យ៉ាងទៀតតំណាងសហព្រះរាជអាជ្ញាអាចប្រើប្រាស់ខ្លឹមសារនេះបាន មិនចាំបាច់អានទេ ពីព្រោះ

ការអាននេះធ្វើឱ្យមានភាពមិនច្បាស់លាស់ទៅវិញទេ ដោយសារសាក្សីប្រាកដជាមិនធ្លាប់បានឮអត្ថបទភាសាអង់គ្លេស ឬក៏មិនធ្លាប់បានឃើញអត្ថបទនេះរួចទៅហើយ។ អ៊ីចឹងដោយសារវាជាការបកប្រែ អ៊ីចឹងមានន័យថា វាមិនមែនជារបស់ដើមពិតដែលសាក្សីបានស្ដាប់ឮនោះទេ។ តែបើសិនជាតំណាងសហព្រះរាជអាជ្ញាប្រើប្រាស់នូវខ្លឹមសារនេះ ដើម្បីសួរដេញដោល នេះជាមធ្យោបាយដែលអាចធ្វើ។ សូមអរគុណ។

[០៩:១២:៣០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប។ ខ្ញុំសូមសន្និដ្ឋានលើកឡើងថា មេធាវីការពារក្ដីដែលបានលើកឡើងការជំទាស់នោះ មិនមានមូលដ្ឋាននោះទេ។ យើងបានឮរួចមកហើយកាលពីសប្ដាហ៍មុន ការផ្ដល់ចម្លើយរបស់សាក្សីនេះ ដែលរៀបរាប់អំពីខ្លឹមសារផ្សព្វផ្សាយនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលក្នុងនោះបានប្រកាសជ័យជម្នះទីក្រុងភ្នំពេញ។ គាត់បានលើកឡើថា សារនោះគឺបានផ្សព្វផ្សាយដោយស្ថានីយវិទ្យុសម័យនោះ។ ជាការពិតសាក្សីមិនបានឃើញឯកសារនេះពីមុននោះទេ។

ដូច្នេះនៅក្នុងការសន្និដ្ឋានរបស់ខ្ញុំនេះ វាមានភាពទាក់ទងដោយផ្ទាល់ទៅនឹងចម្លើយរបស់សាក្សីនេះតែម្ដង។ ដូច្នេះបានន័យថា គាត់បានន័យថា គាត់បានដឹងជាក់ស្ដែងទៅលើខ្លឹមសារ និងអ្វីដែលមានសរសេរនៅក្នុងឯកសារនេះ។ ឯកសារនេះមាននៅក្នុងសំណុំរឿង បានទទួលយករួចមកហើយដោយអង្គជំនុំជម្រះ។ ខ្ញុំសូមរំឭកថា អង្គជំនុំជម្រះបានអនុញ្ញាតកាលពីសប្ដាហ៍មុនឱ្យខាងភាគីមេធាវី ខៀវ សំផន អានខ្លឹមសារជូនលោកដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន លើឯកសារកម្ពុជាសាធារណៈ -- កម្ពុជាប្រជាធិបតេយ្យ។ លោក អែម អឿន មិនបានឃើញឯកសារនោះពីមុនមកនោះទេ។

[០៩:១៤:០០]

ហេតុដូច្នេះហើយទំនាក់ទំនងនេះមានលក្ខណៈរឹងមាំណាស់ ដែលសាក្សីបានរៀបរាប់ខ្លឹមសារនេះរួចមកហើយ។ ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់មេធាវីថា វាធ្វើឱ្យសាក្សីច្រឡំ ហើយសាក្សីនោះគឺគាត់មិនស្គាល់ទៅលើឯកសារនេះ ថាតើវាត្រឹមត្រូវ រៀបរាប់ពាក្យជាក់ស្ដែង ពាក្យដើមដែរឬទេ? នេះជាគោលបំណងដែលយើងចង់សួរសំណួរ ដើម្បីឱ្យសាក្សីបញ្ជាក់ ហើយឱ្យគាត់ធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់ទៅលើភាពត្រឹមត្រូវនៃឯកសារនេះ។

ខ្ញុំសូមរំឭកថា លោក ដេវីដ ឆេនដ៍ល័រ មានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការសិក្សាប្រវត្តិ-

សាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺគាត់បានបញ្ជាក់ទៅលើចំណុចនេះផងដែរ។

ដូច្នេះហើយ គឺខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា ការជំទាស់របស់មេធាវីការពារក្ដីគ្មានមូលដ្ឋាននោះទេ។

សូមអរគុណ។

[០៩:១៤:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៦:១៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនមានមូលដ្ឋានសមស្រប។ អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចដកស្រង់នូវឯកសារនេះ ដើម្បីសួរដេញដោលសាក្សីបាន ដោយសារឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ គឺE3 ហើយនៅក្នុងការតាំងសំណួរដេញដោល ដោយការដកស្រង់ ឬក៏ដកស្រង់នូវខ្លឹមសារនេះ គឺជាលទ្ធភាពរបស់ភាគីដែលពាក់ព័ន្ធអាចធ្វើដូច្នេះបាន។ ហើយចំណែកឯតម្លៃនៃភស្តុតាងនោះ គឺអង្គជំនុំជម្រះនឹងពិចារណាវាយតម្លៃនៅពេលក្រោយ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក នង សុផង់ ខ្ញុំនឹងអានដោយសង្ខេបចេញពីការកត់ត្រានៅក្នុងឯកសារនេះ។ ចុះ -- ឯកសារនេះ ចុះថ្ងៃទី១៧--

**លោក គង់ សំអុន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[០៩:១៧:៣៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអត់ជំទាស់នឹងសេចក្ដីសម្រេចរបស់លោកប្រធានអំមិញទេ ប៉ុន្តែខ្ញុំសូមធ្វើការកត់សម្គាល់ថា ឯកសារដែលតំណាងសហព្រះរាជអាជ្ញាប៉ុនប៉ងនឹងបង្ហាញទៅសាក្សីនេះពុំ

មានដាក់បង្ហាញនៅក្នុង *អ៊ីនធីហ្វេស* របស់តុលាការនេះទេ។ អ៊ីចឹងសួរថា តើលោកអាចត្រូវធ្វើការសួរនេះដែរឬទេ ឬមួយក៏មិនមានចេតនាចង់សួរទេ?

បាទ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងបានគោរពតាមការណែនាំរបស់អង្គជំនុំជម្រះ ដែលយើងបានដាក់បញ្ចូលឯកសារមួយចំនួនជាក់លាក់តែប៉ុណ្ណោះ ដើម្បី -- ដែលយើងនឹងយកមកប្រើប្រាស់។ ឯកសារនេះលេចចេញពីការផ្តល់សក្ខីកម្មរបស់សាក្សីកាលពីសប្តាហ៍មុន។ យើងបានដាក់ឯកសារនេះ មុនពេលដែលសាក្សីបានមកដល់។ ឯកសារនេះ គឺវាលេចចេញពីសក្ខីកម្មរបស់សាក្សី។ ដូច្នេះតាមការយល់សេចក្តីណែនាំរបស់លោកអង្គជំនុំជម្រះ ភាគីត្រូវដាក់ឯកសារមួយចំនួនសមរម្យ ដែលប្រាកដថាខ្លួននឹងប្រើប្រាស់។ ចំណុចនេះគឺមានរារាំងភាគីមិនឲ្យយោងឯកសារផ្សេងនោះទេ ប្រសិនបើឯកសារផ្សេងនោះវាបង្ហាញថា ពាក់ព័ន្ធហើយមានការពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីដែលបានលាតត្រដាង។

[០៩:១៩:០៦]

ដូច្នេះ យើងមិនមានលទ្ធភាពក្នុងការសម្រួលទៅលើអ្វីដែលយើងបានលើកឡើងនេះ ហើយយើងគឺក៏បានបញ្ជាក់ថា ឯកសារនេះវាមានការពាក់ព័ន្ធទៅនឹងខ្លឹមសារដែលមាននៅក្នុងសំណុំរឿងផងដែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនត្រូ អ៊ីនូហ្ស៊ី៖**

អរុណសួស្តីលោកប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ភាគីទាំងអស់។ យើងឯកភាពជាមួយនឹងការបត់បែន ក៏ប៉ុន្តែគួរតែឲ្យវាមានដាក់នៅក្នុងកំណត់ហេតុឲ្យបានត្រឹមត្រូវ ដើម្បីឲ្យយើងទាំងអស់គ្នានេះអាចប្រើប្រាស់ឯកសារទាំងអស់គ្នាបាន។ ឯកសារនេះ មិនមាននៅក្នុងប្រព័ន្ធ *អ៊ីនធីហ្វេស* ដូច្នេះហើយវាមិនគោរពជាការឯកភាពគ្នានូវអ្វីដែលយើងបានសម្រេចរួចមកហើយ។ យើងដឹងហើយថា ភាគីទាំងអស់គឺអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ E3 ក៏ប៉ុន្តែយ៉ាងណាក៏ដោយគួរតែបញ្ចូលនៅក្នុងប្រព័ន្ធឯកសារប្រចាំថ្ងៃរបស់យើង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមលើកដោយសង្ខេប។ ខ្ញុំយល់អំពីជំហររបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា គឺមានលក្ខណៈបត់បែននៅពេលដែលយើងលើកឡើងចំណុចនេះ ដូចដែលយើងបានធ្វើនៅកាលពីអតីត-កាល។ ប្រសិនបើយអ៊ីចឹងមែន សហព្រះរាជអាជ្ញា គួរតែជូនដំណឹងមកកាន់ភាគីទាំងអស់ឲ្យបានជ្រាបថាតើឯកសារណាដែលខ្លួនគ្រោងនឹងប្រើប្រាស់ ទោះបីមិនបានដាក់ចូលនៅក្នុងប្រព័ន្ធ*អ៊ីនធីហ្វេស*ក៏ដោយ។

[០៩:២០:៤៩]

នេះគឺជាវិធីសាស្ត្រមួយត្រឹមត្រូវ។ ខ្ញុំស្វាគមន៍ និងគោរពសេចក្តីណែនាំរបស់អង្គជំនុំជម្រះ ហើយក៏គាំទ្រការប្រើប្រាស់ឯកសាររបស់សហព្រះរាជអាជ្ញានេះផងដែរ ដរាបណាមេធាវីការពារក្តីទទួលបានការប្រព្រឹត្តដូចគ្នា។ ភាគីមួយបានយល់ និងដឹងអំពីអំពីភាពចាំបាច់ក្នុងការប្រើប្រាស់ឯកសារមួយជាក់លាក់។ ដូច្នេះហើយភាគីគួរតែទទួលបានការជូនដំណឹង ដើម្បីឲ្យយើងត្រៀមខ្លួនរួចជាស្រេចពិនិត្យឯកសារទាំងអស់នេះ។ នេះជាគោលបំណងដែលយើងបង្កើតប្រព័ន្ធឯកសារប្រចាំថ្ងៃ ដើម្បីអាចឲ្យយើងមើលលើឯកសារនេះ ដាក់ការជំទាស់របស់យើងក្នុងពេលស្រប នៅក្នុងពេលដែលយើងដំណើរការក្តី។ សូមអរគុណ។

[០៩:២១:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៣:១១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រី ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានឡើងអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។

ជាបឋម ខ្ញុំសូមបញ្ជាក់បំភ្លឺថា យើងមិនគួរមានការច្រឡូកច្របល់យល់ច្រឡំទៅលើវិធាន ដែលគ្រប់គ្រងទៅលើការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ និងវិធានដែលគ្រប់គ្រងការដាក់ឯកសារ

នៅក្នុងប្រព័ន្ធដាក់ឯកសារប្រចាំថ្ងៃ។

[០៩:៣៣:៥៣]

នៅពេលដែលខ្ញុំលើកឡើងដូច្នេះ ការដាក់ឯកសារនេះគឺការដាក់ឯកសារនៅក្នុងប្រព័ន្ធអ៊ីនធឺហ្វេស ដោយសារឯកសារនេះ បានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចមកហើយ។ ការដាក់ឯកសារនៅក្នុងប្រព័ន្ធឯកសារប្រចាំថ្ងៃនេះ គឺជាការជូនដំណឹងឲ្យមុនទៅដល់ភាគី។ ជាក់ស្ដែងវាអាស្រ័យទៅលើការវិវត្តនៃកិច្ចដំណើរការនីតិវិធី ភាពបត់បែនមួយចំនួនវាមានភាពចាំបាច់ដើម្បីអនុវត្តវិធាននេះបាន។ នៅពេលដែលខ្ញុំលើកឡើងដូច្នេះ នៅក្នុងករណីជាក់លាក់នេះ ដែលសាក្សីមានលទ្ធភាពមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែក ហើយគ្មានការជូនដំណឹងជាមុនទេនោះ សហព្រះរាជអាជ្ញា សូមជូនដំណឹងដល់សហព្រះរាជអាជ្ញា ភាគីសហព្រះរាជអាជ្ញានេះ គួរតែសួរសំណួរពាក់ព័ន្ធនេះ នៅថ្ងៃស្អែក ដោយសារផ្ដល់លទ្ធភាពឲ្យសហព្រះរាជអាជ្ញានេះ ជូនដំណឹងជាមុនទៅដល់ភាគីទៅលើឯកសារនេះ នៅក្នុងថ្ងៃនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណចៅក្រម ហ្វេនស៍។ ខ្ញុំសូមជម្រាបក្រុមប្រឹក្សាជំនុំជម្រះ និងភាគីថា តាមការណែនាំរបស់អង្គជំនុំជម្រះ យើងខ្ញុំនឹងគោរពតាមការណែនាំទៅលើការដាក់ឯកសារ តាមសេចក្ដីបង្គាប់ដែលយើងស្ដាប់ឮនេះ។

[០៩:៣៥:២៨]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក នង សុផង់ ពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលលោកបានឆ្លើយ ទិដ្ឋភាពមួយទៀតចំណុចមួយទៀតពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយដែលលោកបាននិយាយប្រាប់កាលពីសប្ដាហ៍មុន គឺការទំនាក់ទំនងដែលប្រើៗប្រាស់លេខ *ម៉ស* លេខកូដ *ម៉ស*។ ខ្ញុំសូមសួរបញ្ជាក់លោកដោយខ្លីៗ ឲ្យខ្ញុំយល់ថាតើលេខកូដ *ម៉ស* នេះគេប្រើប្រាស់ដោយរបៀបណា? ឬក៏ខ្ញុំអាចសួរសំណួរលោក ឲ្យលោកធ្វើការពន្យល់ជូនយើងខ្ញុំវិញ។ តើលេខកូដ *ម៉ស* នេះគេប្រើប្រាស់ដោយរបៀបណានៅក្នុងការបញ្ជូនសារពីមជ្ឈិមទៅកាន់ភូមិភាគនោះ?

[០៩:៣៦:២៨]

**លោក នង សុផង់៖**

**ឆ៖** បាទ សូមជម្រាបថា ការជូនខ្លឹមសារពីមជ្ឈិមទៅភូមិភាគ វាមានភាគច្រើនមិនមានជា

*ម័ស* ទេ គឺមានតែលេខកូដបាទ។ ឯខាងមូលដ្ឋានផ្សេងៗវិញ បើគេមានដំណឹងចំហ បានគេប្រើ *ម័ស*។ ឧទាហរណ៍ដូចជាដំណឹងជ័យជម្នះជាដើម។

**ស៖** សូមអរគុណ។ នៅពេលដែលយើងមើលការផ្ញើទំនាក់ទំនងរបៀបនេះ តាមរយៈការមធ្យោបាយផ្សេងក្រៅពី *ម័ស* កាលពីសប្ដាហ៍មុន លោកបានពន្យល់ជូនយើងខ្ញុំថា អត្ថបទសរសេរជាលាយលក្ខណ៍អក្សរ ត្រូវបានធ្វើបំភ័ន្តអក្ខរៈ ក្រោយមកទើបបញ្ជូនចេញទៅ។ ចំពោះយើងខ្ញុំដែលមិនជំនាញនៅក្នុងការងារនេះ តើលោកអាចជួយពន្យល់បានដែរឬទេ តើមន្ទីរ ក-១៨ នោះធ្វើការបញ្ជូនទូរលេខនោះតាមរបៀបណាទៅកាន់ភូមិភាគ? ហើយធ្វើម៉េចទើបគេដឹងអត្ថន័យទាំងអស់នោះ?

**ផ៖** បាទ ចំពោះសារទូរលេខដែលផ្ញើចេញ ការដែលគេបំភ័ន្តអក្ខរៈរួចហើយ គេត្រូវផ្ញើសារហ្នឹងទៅកន្លែង ក-១៨ ដើម្បីបញ្ជូនទៅតាមមុខព្រួញនីមួយៗ ដែលគេបានដាក់នៅលើសារហ្នឹងស្រាប់។ ឧទាហរណ៍ យើងចង់ឲ្យខាង ក-១៨ បញ្ជូនទៅភូមិភាគបូព៌ា គឺមានទិសដែលគេដាក់នៅលើសារហ្នឹងថា អា-៧៥។ ដូច្នេះ កាលណាគេឃើញ អា-៧៥ ខាង ក-១៨ ក៏បានចាត់ចែងសារទូរលេខនេះទៅឲ្យអ្នកកាន់វិទ្យុទូរលេខហ្នឹង ដែលកាន់ទិស អា-៧៥ ហ្នឹង។ គេឡើងទាក់ទងគ្នាតាមម៉ោងកំណត់។ ពេលណាគេទាក់ទងគ្នាឮហើយ គេក៏បញ្ជូនសារហ្នឹងទៅតាមរលកអាកាស។

[០៩:៣៩:៥៩]

**ស៖** យើងខ្ញុំសូមសួរបញ្ជាក់ឲ្យបានជាក់លាក់ថាតើ ការបញ្ជូននេះដោយរបៀបណា? គឺគេប្រើម៉ាស៊ីនតេឡេក្រាម ដើម្បីបញ្ជូនសញ្ញាសំឡេងទៅភាគីម្ខាងទៀត ដែលគេនឹងទទួលបានលិខិតនោះ ឬក៏គេមានម៉ាស៊ីនអ្វីដែលអាចបញ្ជូនទូរលេខនោះបាន?

**ផ៖** បាទ ក្នុងសម័យហ្នឹងមិនមានម៉ាស៊ីនអីទំនើប ក្រៅពីម៉ាស៊ីនដែលគេប្រើវ៉ាកាណូ រវៃដោយដៃ ហើយគេចុចជាសញ្ញាៗ ទូរលេខ។ ឧទាហរណ៍ថា ទិចទិចតា គឺជាលេខ១ ឧទាហរណ៍អីចឹង។ សញ្ញាដែលគេវៃដោយសំឡេង ឮសូរ ទិចទិច ទិចទិចតាៗ ហ្នឹងបាទ ហ្នឹងជាសញ្ញាសំឡេង ជួនកាលវាជាលេខ ជួនកាលវាជាអក្សរបាទ។

[០៩:៤១:១៣]

**ស៖** សូមអរគុណចំពោះការពន្យល់របស់លោក។ តើលោកបានដឹងទេថា មានប្រព័ន្ធណាមួយនៅនឹងកន្លែងរួចជាស្រេច ដើម្បីបញ្ជាក់អះអាងផ្ទៀងផ្ទាត់ថា សារហ្នឹងគឺថាត្រូវបានម្ខាងទៀតទទួលនោះ? ឧទាហរណ៍ បើសិនណាជាមានសារដែលត្រូវផ្ញើ ដូចជាលោកទើបតែប្រាប់អម្បាញ់មិញថា ផ្ញើ

ចេញពី ក-១៨ ហ្នឹង តើមានមធ្យោបាយណាមួយដែលខាងភូមិបញ្ជាក់មកដល់ក-១៨ វិញថាខ្លួនបានទទួលសារពី ក-១៨ នោះដែរទេ?

**ឆ៖** បាទ ចំពោះការទាក់ទងទូរលេខ គេមានរលកអាកាស ហៅថា ហ្វ្រេកង់ ឯកសារទាក់ទងហ្នឹង ដូចគ្នា។ ភាគីខាង ក-១៨ ក៏មានឯកសារហ្នឹង ភាគីខាងភូមិភាគក៏មានឯកសារទាក់ទងតាមរលកអាកាសហ្នឹងដូចគ្នា។ ដើម្បីបញ្ជាក់ថា ដៃគូគេមែន ឬពុំមែន គេមានសួរសញ្ញាសម្ងាត់ទៀត។ បើសួរសម្ងាត់ ឧទាហរណ៍ថា គេសួរសំណួរ អា.អេស.បេ? ឆ្លើយមកវិញ អ្វីមួយដែលគេកំណត់ទៅលើឯកសារទាក់ទង បើឆ្លើយត្រូវ បានន័យថាដៃគូគេមែន។ ក៏ប៉ុន្តែពេលដែលគេសួរសញ្ញាថា អា.អេស.បេ? ទៅឆ្លើយអីផ្សេងៗ ឬមួយក៏មិនឆ្លើយសោះ អាហ្នឹង គឺមិនមែនជាដៃគូរបស់គេទេ គេមិនអាចបញ្ជូនសារហ្នឹងទៅឲ្យអ្នកហ្នឹងទេ បាទ។

[០៩:៤៣:៤៧]

**ស៖** សូមអរគុណចំពោះការពន្យល់នេះ។ លោកបានធ្វើការនៅក្នុងការិយាល័យមួយ មន្ទីរមួយដែលទំនាក់ទំនងពាក់ព័ន្ធទៅនឹងការទំនាក់ទំនងគ្នានេះ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថាតើកម្រិតនៃៗសីលធម៌ក្នុងការបំពេញកិច្ចការហ្នឹង តើៗវាមានកម្រិតប៉ុនណាដែរ?

**ឆ៖** បាទ ជាកម្រិតសីលធម៌នៅរបស់ក្រុមសារទូរលេខ បកប្រែទូរលេខ ក៏ដូចជាបញ្ជូនទូរលេខគេទាំងឡាយគឺសុទ្ធតែមានវិន័យល្អណាស់។ រាល់កិច្ចការដែលទាំងឡាយ ទាំងពួង គឺគេខំធ្វើការងារដោយហ្មត់ចត់ បាទ។ គ្រប់អង្គភាព គឺគេខំធ្វើការដោយមានវិន័យម៉ឺងម៉ាត់ តាមការដែលអង្គការបានកំណត់ជាគោលការណ៍នៅក្នុងសម័យនោះបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលលោករៀបរាប់អំពីមន្ទីរផ្សេងៗ ដែលទទួលខុសត្រូវបំពេញការងារផ្សេងៗពីគ្នានោះ ក្នុងការបញ្ជូន និងការទទួលសារទូរលេខកាលពីសប្តាហ៍មុននេះ លោកបានរៀបរាប់អំពីអង្គភាពនៃ ក-១ គឺអង្គភាពរបស់លោកផ្ទាល់ ហើយលោកក៏បានរៀបរាប់អំពី ក-១៨ ដែរ។ ខ្ញុំចង់សួរទៅលោកអំពីការបកប្រែសារទូរលេខមួយទៀត ដែលលោកបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារដែលមាននៅក្នុង E3/64 ជាចម្លើយលើកទី១ របស់សាក្សី ហើយ ERN ដែលពាក់ព័ន្ធនោះ គឺមាន ERN ខ្មែរ 00328035, ERN បារាំង 00411703, ERN អង់គ្លេស 00334053។

[០៩:៤៧:០៣]

ខ្ញុំសូមអានខ្លឹមសារនៃចម្លើយនេះ ជូនទៅលោក ថាតើលោកនៅចាំប៉ុនណា? “សំណួរ៖ លោកបាននិយាយថា អៀង សារី មានកន្លែងធ្វើការរបស់លោកផ្ទាល់ ថាតើមានសារទូរលេខណាដែលគាត់ត្រូវទទួលនៅកន្លែងគាត់ទេ? ហើយ អៀង សារី មានក្រសួងការបរទេសរបស់គាត់ ដូច្នេះគាត់មានការបកប្រែសារទូរលេខផ្ទាល់របស់គាត់តែម្តង”។ តើក្រៅពីការបក -- អង្គភាពបកប្រែសារទូរលេខហ្នឹង តើលោកអាចបកស្រាយរឿងមួយផ្សេង -- រឿងណាក្រៅពីហ្នឹងបានទេ? ថាតើមាន -- ថាតើគេត្រូវមានធ្វើកិច្ចការអ្វីផ្សេងទៀតដែរ ក្រៅពីបកប្រែសារទូរលេខនោះ?

**ឆ៖** បាទ ចំពោះការទាក់ទងសារទូរលេខកន្លែងលោក អៀង សារី ខ្ញុំមិនបានចាំអស់ទេ។ ហើយក៏ខ្ញុំមិនសូវដឹងថា លោកមានកន្លែងបកប្រែ ឬមួយក៏កន្លែងបញ្ជូនសារទូរលេខទីណាក៏ខ្ញុំក្តាប់មិនបានបាទ។ សូមអរគុណបាទ។

[០៩:៤៨:៤០]

**ស៖** ដូច្នេះយើងខ្ញុំអាចនឹងកែតម្រូវចម្លើយរបស់លោក លោកថា មិនដឹងថាតើមានអង្គភាពបកប្រែសារទូរលេខប្រចាំនៅក្រសួងការបរទេសដែរឬក៏អត់នោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំមិនសូវច្បាស់ រឿងនេះបាទ បានជាខ្ញុំមិនប៊ានិយាយ ព្រោះអ្វីដែលមិនច្បាស់គឺខ្ញុំមិននិយាយបាទ។

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមលើកឡើងពីមន្ទីរមួយទៀត ដែលលោកបានរៀបរាប់ជាមួយសហចៅក្រមស៊ើបអង្កេត នេះគឺមន្ទីរ ក-៧។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើក -- មន្ទីរ ក-១៧ ហ្នឹងជាមន្ទីរអីដែរ?

**ឆ៖** បាទ មិនមែន ក-១៧ ទេ គឺ ក-៧ បាទ។ ក-៧ នេះគឺជាកន្លែងនីរសារសម្រាប់ទទួលសំបុត្រ ក៏ដូចជាទទួលភ្ញៀវដែលមកពីបណ្តាខេត្តនានាបាទ។

**ស៖** តើ ក-៧ ត្រូវបានប្រើប្រាស់ដើម្បីផ្ញើសារទៅកាន់បណ្តាខេត្តនានាដែរឬទេ?

**ឆ៖** បាទ ខ្ញុំពុំដឹងច្បាស់ទេ ព្រោះពុំមែនជាកន្លែងរបស់ខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំសូមលើកឡើងអំពីការរៀបរាប់របស់លោកជូនសហចៅក្រមស៊ើបអង្កេតគឺនៅឯកសារ E3/64 ERN គឺ 00328029, បារាំង 00411698, ហើយERN អង់គ្លេស 0033 4047។ នេះគឺជាការរៀបរាប់របស់លោក លោកថា “អង្គភាពនីរសារ គឺវានៅខាងជើងព្រះបរមរាជវាំង ហើយ ព្រំ គឺជាប្រធានអង្គភាពនេះ។ តួនាទីរបស់ ក-៧ គឺដើម្បីទទួលសារពីបណ្តាខេត្តនានា ហើយនិង

បញ្ជូនសារទូទៅទៅកាន់គ្រប់ទីកន្លែង។ នៅពេលដែលមានភ្ញៀវចង់មកទាក់ទងជាមួយ ក-១ គេត្រូវតែទំនាក់ទំនងជាមួយ ក-៧ ជាមុនសិន។ ខ្ញុំមិនបានចាំទេ ចំណែកឯអនុប្រធាន ក-៧ ខ្ញុំមិនចាំទេ។ ព្រុំ ជាប្រធាននៅ ក-៧ រហូតដល់ពេលវៀតណាមចូលមកដល់”។

[០៩:៥២:៥២]

ហើយនៅក្នុងឃ្លាបន្តទៅទៀត សួរថា“តើអង្គភាពក-៧ មានទំនាក់ទំនងយ៉ាងម៉េចជាមួយក-១?” ឆ្លើយ “មានទំនាក់ទំនងដូចជា បើមានលោកណាចង់ជួបខាង ក-១ គឺទាល់តែឆ្លងតាម ក-៧ ក៏ដូចជាការបញ្ជូនសំបុត្រពីកន្លែងផ្សេងៗ។ បើចង់ជូនសំបុត្រជាចំហ មក ក-១ គឺបញ្ជូនតាម ក-៧។”

ដូច្នេះខ្ញុំចង់បញ្ជាក់ ថាតើតួនាទីរបស់ ក-៧ នេះវាត្រឹមត្រូវយ៉ាងដូច្នេះដែរឬក៏អត់? តើខ្ញុំលើកឡើងសង្ខេបអំពីចម្លើយរបស់លោកថា “សារទាំងអស់ សំបុត្រទាំងអស់ ក៏ដូចជាភ្ញៀវ គឺថា ដែលចង់មក ក-១ គឺត្រូវតែឆ្លងកាត់ ក-៧ ជាមុនសិន គឺត្រូវឆ្លងកាត់ឈ្មោះ ព្រុំ នេះជាមុនសិន”។ តើវាយ៉ាងដូច្នេះមែនទេ?

**ឆ៖** បាទ គឺយ៉ាងដូច្នេះមែនបាទ។ គេមិនអាចចូលផ្ទាល់ទៅកន្លែង ក-១ បានទេ យ៉ាងហោចណាស់ក៏គេមានទូរស័ព្ទទាក់ទងទៅកន្លែង ប៉ុន សិនដែរ។ បើមានលោកណាចង់មកជួប ឬមួយក៏មានជូនសំបុត្រស្នាម ឬចង់ជូនសម្ភារៈអីផ្សេងៗមកកន្លែង ក-១ នេះបាទ។

**សៈ** សូមអរគុណ។ តើលោកមានដឹងការញែកឲ្យដាច់ពីគ្នារវាងប្រភេទសារ ដែលត្រូវបញ្ជូនតាមរយៈសារទូរលេខ តាមរយៈ ក-១៨ ហើយនិងមន្ទីរផ្ញើលេខកូដសម្ងាត់ ដែលសំបុត្រទាំងអស់ត្រូវកាន់មកឆ្លងកាត់តាមរយៈ ក-៧ នេះ។ លោកដឹងទេនៅពេលនោះ ថាតើពេលណាដែលគេអាចធ្វើការទាក់ទងតាមរយៈតេឡេក្រាម ហើយនិងលិខិតដែលត្រូវបញ្ជូនតាមរយៈ ក-៧ នោះ? តើលោកអាចដឹងអំពីការញែកឲ្យខុសពីគ្នានេះទេ?

**ឆ៖** ខ្ញុំមិនដឹងល្អិតទេ ប៉ុន្តែការដែលត្រូវជូនតាមរយៈ ក-៧ហ្នឹង គឺភាគច្រើនជាសំណើសុំសម្ភារៈផ្សេងៗ ដើម្បីយកទៅកសាងអ្វីៗទៅតាមមូលដ្ឋានផ្សេងៗ។ អាហ្នឹងគឺមានលក្ខណៈចំហមិនជាសម្ងាត់មិនជាប្រញាប់អី គឺគេអាចសរសេរតាមសំបុត្របាន ទំនាក់ទំនងគ្នាតាមសំបុត្របាន។ ក៏ប៉ុន្តែអ្វីដែលគេត្រូវទាក់ទងដោយសម្ងាត់ គឺគេត្រូវធ្វើតាមសារសម្ងាត់ តាមលេខកូដសម្ងាត់ ហើយបានគេបញ្ជូនតាមទូរលេខមកតាម ក-១៨ហ្នឹង។ ហើយបើសិនណាជាមានបញ្ហាអីសម្ងាត់ខ្លាំង ជួនកាលគេមិនបាច់ធ្វើតាមទូរលេខទេ ជួនកាលគេមកជួប សំណើសុំជួបគណៈមជ្ឈិមផ្ទាល់តែម្តង។

[០៩:៥៦:៥៥]

**ស៖** បាទ អ៊ីចឹង ដូច្នេះតាមរយៈចម្លើយរបស់លោកនេះ តើលោកដឹងថា តើអ្នកណាដែលចូលមកដោយផ្ទាល់តែម្តង ដើម្បីមកជួបជាមួយមជ្ឈិមនេះ? អ្នកណាជាអ្នកដែលមកដោយផ្ទាល់តែម្តង ដើម្បីជួបជាមួយខាងគណៈមជ្ឈិមនោះ?

**ឆ៖** បាទ ខ្ញុំមិនដឹងកិច្ចការរាក់ជ្រៅអីប៉ុន្មានទេ បាទព្រោះរឿងនេះ វាជាលាក់ការ ជាគោលការណ៍របស់មជ្ឈិម។ ដូច្នេះ គឺការងាររបស់ខ្ញុំ គឺមានសិទ្ធិត្រឹមតែបកប្រែសារ និងបញ្ជូនសារតែប៉ុណ្ណោះ ឯរឿងកិច្ចការលាក់ -- រាក់ជ្រៅរបស់មជ្ឈិមយ៉ាងណាៗ។ អ្នកណាមានសិទ្ធិចូល អ្នកណាមានសិទ្ធិមិនត្រូវចូល។ ខ្ញុំមិនដឹង បាទ សូមអរគុណបាទ។

**ស៖** ខ្ញុំចង់ឲ្យលោកពន្យល់បន្ថែមទៀតនេះ ថាតើចម្លើយរបស់លោកនេះអាចធ្វើឲ្យលោកចងចាំឡើងវិញបានទេ។ ចូលទៅដល់ឯកសារ E3/64 ដដែល។ ERN ជាភាសាខ្មែរ 00328035, ERN ជាភាសាបារាំង 00411703, ERN ជាភាសាអង់គ្លេស 00334053។ ខ្ញុំសូមលើកឡើងដោយសង្ខេបទេ។ សំណួរថា "តើសារទូរលេខមកពីភូមិភាគណាដែលលោកបកប្រែ? ខ្ញុំបកប្រែគ្រប់ភូមិភាគទាំងអស់។ ខ្លឹមសារ ការ -- ដូចជាខ្លឹមសារការលើកទំនប់ប្រឡាយ, ស្នើសម្ភារៈនេះសម្ភារៈនោះ, សមាសភាពផ្ទៃក្នុងដែលនៅក្នុង -- និងបាតុភាពអ្វីដែលកើតឡើងនៅមូលដ្ឋាន។ ចំណែកឯ សារ៉ាយ គឺការរាយការណ៍អំពីខ្មាំង ឬជនក្បត់ គឺគណៈភូមិភាគមកជួបផ្ទាល់ជាមួយគណៈមជ្ឈិម"។

តើនេះគឺជាចម្លើយរបស់លោកដែលត្រឹមត្រូវ ដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនោះ ឬក៏យ៉ាងណា ដែលលោកថា គឺគណៈភូមិភាគជាអ្នកមកជួបផ្ទាល់ជាមួយគណៈមជ្ឈិមនោះ?

[០៩:៥៩:៥១]

**ឆ៖** បាទ ចម្លើយនេះគឺខ្ញុំអត់មានកែប្រែទេ ពីព្រោះថាភាគច្រើនកិច្ចការផ្ទៃក្នុងដែលធ្វើតាមរយៈសារទូរលេខមានតិចតួចណាស់ ដែលខ្ញុំស្ទើរតែមិនសូវដឹង។ តែភាគច្រើនគឺថា គេអាច បើមានផ្ទៃក្នុង គេមិន -- កន្លែងខ្លះ ក៏គាត់មិនអាចធ្វើតាមទូរលេខ ដើម្បីឲ្យបែកការខ្ចរខ្ចាយដែរ គឺគេអាចមកជួបផ្ទាល់ ពិភាក្សាជាមួយគណៈមជ្ឈិមផ្ទាល់តែម្តងបាន។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើគណៈភូមិភាគមករាយការណ៍ ឬក៏មកពិភាក្សាអំពីបញ្ហាផ្ទៃក្នុងជាមួយមជ្ឈិមដោយរបៀបណាដែរ?

[១០:០១:០៥]

**ឆ៖** បាទ គេមានមធ្យោបាយច្រើន ក្នុងការទំនាក់ទំនងជាមួយមជ្ឈិមហ្នឹង។ តែជាដំបូង គឺថា អ្វីៗចង់ជួបមជ្ឈិម គឺទាល់តែឆ្លង ក-៧ សិនបាទ។

**ស៖** សំណួររបស់ខ្ញុំ គឺថាតើលោកដឹងថា តើលោកបានឃើញ ឬក៏វាជាបទពិសោធន៍របស់លោក? ឬក៏លោកនិយាយជាមួយនឹងអ្នកដទៃចំពោះបញ្ហាគណៈភូមិភាគ មកជួបគណៈមជ្ឈិមនេះ?

**ឆ៖** បាទ រឿងមកជួប មកគណៈមជ្ឈិមនេះ ក៏ពេលខ្លះ ក៏គេធ្វើតាមសារទូរលេខសម្ងាត់។ ឧបមាថា សំណើសុំជួប បងណាៗ នៅកន្លែងណាៗ គេឲ្យមានសារទូរលេខខ្លះ គេឲ្យដំណឹងមុនបាទ ធ្វើតាមសារទូរលេខសម្ងាត់បាទ។ នេះជាមធ្យោបាយដែលឲ្យខ្ញុំសន្និដ្ឋានថា វាមានបញ្ហាអីសម្ងាត់ ជួនកាលគេមិនជាធ្វើតាមសារទូរលេខសម្ងាត់ទេ នាំឲ្យវាវែងអន្លាយ ពីព្រោះត្រូវពិភាក្សាគ្នាល្អិតល្អន់។ អ៊ីចឹងគឺគេសុំជួប គេធ្វើជាសារខ្លីៗ សុំជួបមុន បាទ នេះ បានជាខ្ញុំដឹង។

**ស៖** សូមអរគុណលោក ដែលបានជួបបំភ្លឺនូវសំណួរនេះ។ តើមានការអញ្ជើញណាផ្សេងទៀតដែលចេញពីគណៈមជ្ឈិមដែលត្រូវអញ្ជើញ ឬក៏កោះហៅខាងគណៈភូមិភាគឲ្យមកចូលរួមប្រជុំ ឬក៏ពិភាក្សាអ្វីមួយនោះ យោងទៅតាមសារទូរលេខដែលលោកបានដឹងហ្នឹងនោះ?

[១០:០៣:២៤]

**ឆ៖** បាទ រឿងនេះ ក៏ខ្ញុំជួបប្រទះច្រើនដែរ នូវការអញ្ជើញកម្មាភិបាលភូមិភាគមកប្រជុំ។ គេធ្វើជាសារខ្លីៗទេ មិនមានវែងទេ បាទ។ គឺមុននឹងបើកការប្រជុំ ឧទាហរណ៍ ប្រជុំរួមទូទាំងប្រទេសនៅបុរីកីឡា គេមានធ្វើសារអញ្ជើញគ្រប់តំបន់ គ្រប់ភូមិភាគ ឲ្យអញ្ជើញមកចូលរួមនៅក្នុងការបើកវគ្គការរៀនសូត្រ នៅក្នុងសាលាបក្ស នៅក្នុងបុរីកីឡា បាទ។

**ស៖** តើលោកនៅចាំទេ តើអ្នកណាជាអ្នកស៊ីញ៉េនៅលើសារ ឬក៏ថាត្រូវបញ្ជូនក្នុងនាមឲ្យអ្នកណានោះ លោកនៅចាំបានទេ?

**ឆ៖** បាទ ខ្ញុំចាំបានថា លោកដែលមានសិទ្ធិចាត់ចែង ថាសារណា ត្រូវជូនទៅលោកណា។ សារណា ត្រូវជូនទៅបងណា អ៊ំណា គឺលោក ប៉ុន បាទ។

[១០:០៤:៥៧]

**ស៖** តើលោកនៅចាំបានទេ អំពីសារនីមួយៗហ្នឹង តើមានឈ្មោះរបស់មនុស្ស ឬក៏ឈ្មោះមន្ទីរអង្គភាព ដែលបញ្ជាក់អំពីអ្នកដែលរៀបចំសារហ្នឹង បញ្ជាក់ពីអង្គភាព ឬក៏មន្ទីររបស់អ្នកដែលរៀបចំសារហ្នឹងដែរឬទេ?

**ឆ៖** បាទ ធម្មតាសារនីមួយៗ គេមានក្បាលមានកន្ទុយរបស់គេ។ ក្បាលហ្នឹងគេដាក់ថា តាមទម្លាប់ទៅតាមកន្លែងមួយៗ។ ជួនកាលគេដាក់ថា "ជូនបងជាគោរព"។ ជួនកាលគេដាក់ថា "ជូនគណៈ ៨៧០"។ ជួនកាល "បងជាទីគោរពស្នេហា"។ បាទនេះជាទម្រង់ដែលវាអាស្រ័យទៅលើកន្លែងមួយ ដែលគេរៀបចំក្បាលអាក្បាលសារហ្នឹងបាទ។ ហើយនៅខាងកន្ទុយនេះ គឺមានចុះថ្ងៃខែឆ្នាំ ហើយនិងហត្ថលេខាអ្នកដែលបញ្ជូនមក។ បាទ ខ្ញុំចាំមិនអស់ទេ ពីព្រោះថាវាច្រើនឆ្នាំមកហើយ ខ្ញុំមិនអាចចាំថានរណាខ្លះចុះហត្ថលេខអីៗ បាទនេះគឺតាមបាន គឺថាគេមានក្បាល មានកន្ទុយអ៊ីចឹងដែលសារនីមួយៗ។

[១០:០៦:៣៦]

**ស៖** លោកនិយាយថា ពេលខ្លះគឺនីវសារ គឺ -- សារហ្នឹងគឺបញ្ជូនទៅមន្ទីរ៨៧០ តើលោកនៅចាំអំពីការអញ្ជើញឲ្យមកចូលរួមប្រជុំដែលត្រូវបានស៊ីញេ បានចុះហត្ថលេខាដោយខាងៗមន្ទីរ៨៧០ ដែរទេ?

**ឆ៖** បាទ ខ្ញុំចំណាំបានលេខ ដែលចេញពីមន្ទីរ៨៧០ គេសរសេរថា ៨៧០ នៅក្នុងកន្ទុយសារហ្នឹង គឺគេដាក់៨៧០ អ៊ីចឹងតែម្តងបាទ។ លេខសម្ងាត់៨៧០ គឺបានន័យថាលេខមជ្ឈិមហើយហ្នឹង។

**ស៖** សូមអរគុណច្រើន។ ឥឡូវខ្ញុំសូមបន្តចូលទៅពិភាក្សាទៅលើឯកសារមួយចំនួនជាមួយលោកសាក្សី លោក នង សុផង់។ កាលពីសប្តាហ៍មុនខ្ញុំបាននិយាយថា ខ្ញុំនឹងមិននិយាយអំពីលេខកូដសម្ងាត់លម្អិតនោះទេ។ ដូច្នេះខ្ញុំនឹងរក្សាការសន្យារបស់ខ្ញុំនេះ។ ប៉ុន្តែដើម្បីជួយឲ្យអង្គជំនុំជម្រះបានជ្រាបអំពីប្រតិបត្តិការជាក់ស្តែងអំពីលេខកូដ ឬលេខសម្ងាត់នោះ ខ្ញុំចង់បង្ហាញជូននូវឯកសារមួយ ដែលបានដាក់ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងចម្លើយលើកទី១របស់លោក។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺជាឯកសារ D200/3.8 វាជាតារាងដែលនិយាយអំពីចំនួន១០០ម៉ែត្រការ៉េ បើសិនណាជាលោកប្រធានអនុញ្ញាត ខ្ញុំសូមជូនឯកសារជាក្រដាសជូនទៅសាក្សី ហើយក៏សូមឲ្យបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រនេះផងដែរ ដើម្បីឲ្យភាគីដទៃទៀត ក៏ដូចជាសាធារណជនបានឃើញទាំងអស់គ្នា។ សូមអរគុណ។

[១០:០៨:១៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជ

អាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ប្រសិនបើខ្ញុំយល់មិនខុសនោះទេ តារាងនេះ គឺលោកជាអ្នកគូរក្រោយ -- នៅពេលដែលលោកត្រូវបានអ្នកស៊ើបអង្កេតសម្ភាសនោះ។ តើអ៊ីចឹងដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ តារាងនេះគឺខ្ញុំធ្វើដោយផ្ទាល់ដៃខ្ញុំមែនបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផងដែរ។ សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ តើលោកអាចពន្យល់ជាមូលដ្ឋាន ឬពន្យល់ជារួម តើគេប្រើតារាងនេះដោយរបៀបណា ដើម្បីបំភ័ន្តអក្ខរៈទៅជាតួអក្សរនីមួយៗនោះ?

[១០:១០:៤៥]

**លោក នង សុផង់៖**

**ឆ៖** បាទ នេះគឺជា គេហៅថា តារាង១០០ក្រឡា គឺប្រើសម្រាប់បំភ័ន្តអក្ខរៈ។ ពាក្យថា "បំភ័ន្តអក្ខរៈ" គឺមានន័យថា ប្រែពីអក្សរធម្មតាឱ្យទៅជាលេខកូដបាទ។ ឧទាហរណ៍ សារយើងធម្មតាគេឃើញអក្សរ "ក" នៅក្នុងសារទូរលេខ ដែលគេសរសេរមកឱ្យយើងប្រែហ្នឹង។ អ៊ីចឹងយើងចង់បានអក្សរ "ក" បំភ័ន្តវាឱ្យទៅជាលេខវិញ គឺអក្សរ "ក" នៅក្នុងតារាងនេះ គឺនៅក្នុងក្រឡា លេខសូន្យបាទ។ ជួរខាងលើនេះ គឺជា ខ្សែបណ្ដោយក្រហមនេះ គេចាត់ទុកវាជាលេខដើមបាទ។ ឯអាលេខបញ្ឈរក្រហមនេះ គឺជាលេខកន្ទុយ។ អ៊ីចឹង គឺចង់បានអក្សរ "ក" គេត្រូវសរសេរសូន្យៗ ហ្នឹងគឺលេខកូដសូន្យៗ គឺជាអក្សរ "ក" ហើយបាទ។ ឧទាហរណ៍មួយទៀត លោកចង់បានជាលេខវិញ ឧទារហណ៍លេខ៩។ លេខ៩ គឺនៅក្នុងក្រឡាបណ្ដោយ គឺចំលេខ៨ ហើយនៅខ្សែបញ្ឈរនេះគឺលេខ១។ អ៎! សូមទោស ខ្ញុំច្រឡំទេ ព្រោះភ្លេចភ្លាំង។ គឺគេយកអាខាងបញ្ឈរនេះជាក្បាលវិញ អាបណ្ដោយនេះជាកន្ទុយបាទ។ ឧទាហរណ៍ថា លេខ៩ នេះគេយកអាខ្សែបញ្ឈរគឺលេខ១ ឯខ្សែបណ្ដោយនេះគឺលេខ៨។ អ៊ីចឹងគឺ១៨ គឺតំណាងឱ្យលេខ៩ បាទ។

[១០:១៣:១៧]

**ស៖** ដូច្នេះដើម្បីសង្ខេបតួអក្សរនៅក្នុងតារាងនីមួយៗនេះ គឺគេមានការដាក់លេខកូដបញ្ឈរ និង លេខកូដផ្ដេក នៅក្នុងជួរផ្ដេក។ តើអ៊ីចឹងដែរឬទេ គេកំណត់តាមរបៀបហ្នឹង?

**ឆ៖** បាទ គេមើលតាមរបៀបយ៉ាងនេះឯង គឺថាបញ្ឈរគឺជាគោល ឯផ្ដេកនេះ គឺជាលេខដែល យើងត្រូវភ្ជាប់ពីបញ្ឈរទៅអាផ្ដេក បើនៅក្នុងក្រឡាណា ផ្ដេកនៅក្រឡាណា កន្ទុយវាប៉ុណ្ណឹងឯង។

**ស៖** សូមអរគុណ។ ខ្ញុំចង់យោងនិយាយទៅលើចម្លើយដែលលោកបានឆ្លើយរៀបរាប់អំពីតារាង នេះ។ នៅក្នុងចម្លើយនោះលោកបានរៀបរាប់ដូចតទៅ ឯកសារនោះគឺ E3/64 ខ្មែរ 00328046, បារាំងគឺ 00411713, អង់គ្លេស 00334062។ លោកបានបញ្ជាក់ថា “ខ្ញុំត្រូវតែហៅបក្ស និងជម្រាប អំពីបញ្ហាបច្ចេកទេស ហើយបន្ទាប់មកផ្ដល់បក្សនូវតារាងនេះមួយច្បាប់”។ ខ្ញុំសូមសួរលោក តើនៅ ពេលណាជាពេលដំបូង ដែលលោកអាចកោះហៅសមមិត្តរបស់លោកម្ខាងទៀតនោះ ឲ្យមកចូលរួម ប្រជុំជាមួយលោកដើម្បីយកតារាងនេះទៅប្រើប្រាស់នោះ?

**ឆ៖** បាទ ក្នុងតារាងនេះ គឺក្នុងករណីដែលមិនមានអីប្លែក ឬក៏មិនមានអីស្មុគស្មាញទេ នោះមិន ចាំបាច់ហៅភាគីម្ខាងទៀតមកជួបដើម្បីពន្យល់ទេ។ ក៏ប៉ុន្តែក្នុងករណីខ្លះអ្នកធ្វើការនៅភាគីម្ខាងទៀត ហ្នឹង ថ្មីមិនមានជំនាញក្នុងការប្រើប្រាស់ឯកសារនេះ ទើបខ្ញុំសំណើសុំអញ្ជើញគេមកពន្យល់បាទ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ចំណុចនេះឡើងវិញ។ លោកនឹកឃើញលើកដំបូងដែលលោកកោះហៅ អ្នកដែលធ្វើការនៅកន្លែងផ្សេងនោះឲ្យមកចូលរួមស្ដាប់លោកបង្ហាញអំពីតារាងនេះ តើពេលនុ៎ង ដំបូង ហ្នឹងគឺនៅពេលណាដែរ?

[១០:១៦:៥២]

**ឆ៖** ធម្មតាគឺមិនមានច្រើនទេ បញ្ហានេះ គឺមានតែនៅខាងភូមិភាគពាយ័ព្យ តំបន់មណ្ឌលគិរី ដែលលោកមិនមានច្បាស់ក្នុងការធ្វើសារនេះ។ អ៊ីចឹងគឺ ខ្ញុំបានអញ្ជើញអស់លោកនៅភាគីម្ខាងទៀតមក ពន្យល់អំពីឯកសារនេះ។ របៀបរបបនៃការធ្វើសារ យ៉ាងណាដើម្បីឲ្យទៅជាសារសម្ងាត់បាទ។ ឯ ភូមិភាគផ្សេងៗទៀត ភាគច្រើនគឺគេមានធនធានមនុស្ស ហើយគេមានជំនាញរបស់គេតាំងពីសម័យ សង្គ្រាមមកម្ល៉េះ។ ដូច្នេះខ្ញុំមិនសូវដែលបានអញ្ជើញអស់លោកទាំងអស់នោះមកធ្វើការពន្យល់ទេបាទ។

**ស៖** ប្រសិនបើខ្ញុំសូមសួរលោកអំពីមនុស្សមកពីមណ្ឌលគិរី តើលោកចាំដែរឬទេ? តើលោក មានចាំថា នៅពេលណាមួយនោះ តើនរណាគេខ្លះដែលបានមកនោះ ហើយពួកគេធ្វើការនៅឯណាដែរ នៅពេលនោះ?

[១០:១៨:២៩]

**ឆៈ** បាទ ខ្ញុំបានធ្លាប់ពន្យល់គេ គឺនៅខាងមណ្ឌលគិរីគេបញ្ជូនយុវនារីបាទ ជាអ្នកប្រែធ្វើការងារខាងសម្ងាត់ហ្នឹង ហើយខ្ញុំបានពន្យល់គេ ណែនាំគេ គឺនៅកន្លែងមន្ទីរ ក-៧ ហ្នឹងហើយបាទ។ ពេលដែលគេចេះច្បាស់លាស់ហើយ គេក៏ត្រឡប់ទៅមូលដ្ឋានរបស់គេវិញ។

**សៈ** សូមអរគុណ។ មុនពេលដែលយើងឈប់ពិភាក្សាទៅលើតារាងនេះ លោកបានផ្ដល់ជាយោបល់កាលពីសប្ដាហ៍មុនអំពីសារសម្ងាត់។ ប្រសិនបើជាសារសម្ងាត់នោះ គឺលោកនឹងបំភ័ន្តអក្ខរៈនោះបួនប្រាំដង តាមអ្វីដែលខ្ញុំចាំចម្លើយរបស់លោក។ នៅពេលដែលបំភ័ន្តអក្ខរៈនោះ តើលោកយកតារាងនេះ មកធ្វើការបំភ័ន្តអក្ខរៈតែម្ដង ឬក៏មានរបៀប ឬតារាងផ្សេងទៀតសម្រាប់ប្រើប្រាស់បំភ័ន្តអក្ខរៈ?

[១០:១៩:៥៧]

**ឆៈ** បាទ បញ្ហាបច្ចេកទេសវាស្មុគស្មាញណាស់លោក យើងមិនអាចនិយាយគ្នាឲ្យបានច្បាស់លាស់ទេ។ ពីព្រោះវាទាមទារពេលវេលាយូរបានលោកយល់ ពីព្រោះថា ដែលយើងសរសេរជា ប្រែតាមតារាងនេះ មិនមែនទៅត្រឹមជាសារសម្ងាត់អាចយកជាការបានជាចុងក្រោយបញ្ជូនទៅឲ្យភាគីដែលខាងវាយទូរលេខបានទេ។ បើជាសារសម្ងាត់ យើងត្រូវបង្វែងដានមួយជាន់ទៀត ហើយលេខសម្ងាត់ដែលបានទទួលភ្លាមមក ក៏យើងមិនទាន់យកសារហ្នឹងទៅប្រែភ្លាមទេ។ ពីព្រោះយើងត្រូវមាន ហៅថាបញ្ជីសម្ងាត់មួយទៀត មកធ្វើសារដែលខាងមជ្ឈិមជូនមកហ្នឹង កន្លែងណាដែលសម្ងាត់ យើងត្រូវប្រែពីអក្សរធម្មតា ឲ្យទៅជាខ្លឹមសារសម្ងាត់សិន។ ឧទាហរណ៍ ថា ចំណុចអ្វីមួយដែល សូម្បីតែឈ្មោះ ឬមួយក៏ទីកន្លែង គឺយើងត្រូវប្រើបញ្ជីសម្ងាត់មុនសិន។ ឧទាហរណ៍ថា ចំណុច ក-៧ ៗមិនមែនសរសេរ ក-៧ ធម្មតាទេ។ ក-៧ មានបញ្ជីសម្ងាត់របស់វាមួយ។ ហើយក្នុង ក-៧ មួយហ្នឹងមានលេខសម្ងាត់ពីរបីឯណោះ ដែលយើងអាចប្រើបាន។ អានេះមួយជាន់ដំបូងគឺយើងប្រែខ្លឹមសារចំហ ឲ្យទៅជាសម្ងាត់តាមរយៈបញ្ជីលេខសម្ងាត់។ ពេលណាដែលយើងធ្វើតាមបញ្ជីលេខសម្ងាត់សព្វគ្រប់អស់ហើយ ចំពោះចំណុចសំខាន់ៗ បានយើងមកធ្វើបំភ័ន្តអក្ខរៈទៅតាមតារាង១០០ ក្រឡា ឬក៏បទានុក្រម ដែលភ្ជាប់មកជាមួយឯកសារហ្នឹងស្រាប់។

[១០:២២:២១]

ពេលប្រែចេញជាលេខអស់ហើយ មិនអាចយកបញ្ជូនទៅឲ្យខាង ក-១៨ វាយភ្លាមទេ ត្រូវ

បង្វែងដានមួយជាន់ទៀត ជាមួយនឹងគេហៅថា លេខបង្វែងដាន។ អ៊ីចឹងវាមានដល់ទៅបីជាន់។ លេខបង្វែងដានរួចអស់ហើយ អាហ្នឹងហើយបានជាលេខសម្ងាត់ចុងក្រោយ ដែលយើងត្រូវបញ្ជូនទៅឲ្យខាងវិទ្យុវាយបញ្ជូនទៅ។ អ៊ីចឹងបីជាន់ បានទៅជាសារសម្ងាត់។

**ស៖** តើប្រភេទសារបែបណា ដែលទាមទារឲ្យធ្វើការបំភ័ន្តកម្រិតខ្ពស់ពីរបីតង់ដូច្នោះ?

**ឆ៖** បាទ សារដែលប្រភេទសម្ងាត់កម្រិតខ្ពស់ គឺថា ជាទី១ គឺលើដំណើរទៅមករបស់កម្មាភិបាល គឺ -- ហ្នឹងគឺត្រូវសម្ងាត់ដាច់ខាត។ ទី២ គឺលើបញ្ហាសភាពការណ៍ផ្ទៃក្នុង អ្វីៗដែលមានកើតឡើងនៅតាម -- មានបញ្ហាតាមមូលដ្ឋាននានា គឺយើងត្រូវតែបង្វែងដានដាច់ខាត សម្ងាត់ដាច់ខាតហើយ។ ឯប្រភេទសារដែលអាចថា ជាសារចំហ ឬក៏មិនបាច់បង្វែងដាន គឺសម័យនោះគឺដូចជាតិចណាស់ អារឿងគេធ្វើចំហហ្នឹងមិនសូវមានទេ។ បើថាចង់ចំហ គេប្រើជា *ម៉ស*ខ្មែរតែម្តង។

**ស៖** សូមអរគុណ។ ប្រសិនបើយើងពិនិត្យមើលឯកសារមួយទៀតវិញ ដែលលោកបានលើកយកមកពិភាក្សាជាមួយនឹងសហចៅក្រមស៊ើបអង្កេត។

[១០:២៥:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកចៅក្រម ឯកសារនេះ គឺមានលេខ E3/513 គឺជាសារទូរលេខមួយដែលសាក្សីបានឆ្លើយនៅក្នុងពេលសម្ភាសជាមួយនឹងសហចៅក្រមស៊ើបង្កេត។ សូមអនុញ្ញាតពីលោកប្រធាន ផ្តល់ឯកសារនេះជាក្រដាសទៅដាល់សាក្សី។ បន្ទាប់មកយើងខ្ញុំនឹងសូមបន្តសួរសំណួរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ហើយសូមឲ្យធ្វើការបញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ផងដែរ ដើម្បីជាប្រយោជន៍យើងទាំងអស់គ្នា។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សួផង់ ប្រសិនបើយើងចាប់ផ្តើមពិនិត្យមើលទម្រង់នៃឯកសារនេះ។ នៅខាងលើបំផុតនៃឯកសារនេះ យើងឃើញមានទូរលេខ៥៤ នៅក្រោមនោះ ២៩០ខ្ទង់។ តើលោកអាចពន្យល់ទេ

លេខខ្ទង់នេះ គឺលេខអ្វីដែរ?

**លោក នង សុផង់៖**

**ឆ៖** ទូរលេខលេខ៥៤ គឺប្រែជាបារាំង ឬអង់គ្លេស គឺថា ណាំប៊ឺ ឬ នុយមឺរ៉ូ របស់សារហ្នឹង គឺលេខ៥៤បាទ។ ឯ២៨០ខ្ទង់ហ្នឹង គឺជា ហៅថាចំនួន ស៊ី.ខេ ៗគឺប្រែថា "ខ្ទង់ ឬចង្កោម"ហ្នឹងនៃសារទូរលេខហ្នឹង វាមានចំនួន ២៨០ ស៊ី.ខេ។ គឺចំនួន២៥០ខ្ទង់។ មួយខ្ទង់ៗ គេរៀបចំជាប្រាំៗលេខ បាទ សារទូរលេខហ្នឹង។ អ៊ីចឹងគឺទូរលេខមួយខ្លឹមសារហ្នឹង គឺមានចំនួន២៨០ខ្ទង់ បាទដែលគេរាប់ឃើញ ព្រោះគេសរសេរសារ គឺមួយសន្លឹក១០០ៗ មួយខ្ទង់។ ដូច្នេះគេអាចងាយស្រួលទេក្នុងការរាប់ខ្ទង់។ ខ្ទង់ គឺជាចំនួនចង្កោម ឬហៅថា ស៊ី.ខេ ហ្នឹងហើយ។

[១០:២៧:៤៧]

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលថា តើគេបញ្ជូនទៅបុគ្គលមួយណានោះ គឺក្នុងនេះ គេបានសរសេរថា "គោរពជូនបងជាទីគោរព" តើលោកអាចបញ្ជាក់ទេ គោរពជូនបងជាទីគោរពនេះ ផ្ញើទៅកាន់នរណាគេដែរ?

**ឆ៖** បងជាទីគោរព គឺសំដៅទៅលើ ប៉ុល ពត។ ព្រោះ បង គឺសំដៅលោកលេខាបក្សហ្នឹង ហើយ។ បងទី១ ហ្នឹងហើយបាទ។

**ស៖** នៅក្នុងចម្លើយរបស់លោកត្រង់លេខ ERN ជាភាសាខ្មែរ 00328041, បារាំង គឺមាន លេខ 00411709, អង់គ្លេស គឺ00334058។ លោកបាននិយាយអំពី សរសេរដៃនៅជ្រុងខាងស្ដាំ ខាងលើ។ ហើយលោកបានឆ្លើយថា សំណេរសរសេរដៃ ចំណារសរសេរដៃនោះ សរសេរថា "អ៊ំនួន" នៅខាងឆ្វេងបាទ។ គឺសរសេរ "អ៊ំនួន" ដោយមានការចាត់ចែងនៅលើចំណុចនេះ។ តើខ្ញុំអាចបញ្ជាក់ទេ ថាអ្វីដែលលោកឆ្លើយនៅក្នុងឯកសាររបស់លោកនោះ គឺសំដៅទៅលើបុគ្គលម្នាក់ឈ្មោះ ប៉ុន?

[១០:៣០:០៥]

**ឆ៖** បាទ ពិតប្រាកដមែនបាទ។ នេះជាចម្លើយដែលខ្ញុំបានឆ្លើយ។

**ស៖** សារទូរលេខនេះ គឺនិយាយអំពីសភាពការណ៍ខ្លាំង ហើយបានលើកឡើងអំពីការចាប់ បុគ្គលមួយរូបនៅក្នុងចំណុចលេខ៣។ ខ្ញុំសូមដកស្រង់សម្ដីនៅត្រង់ចំណុចលេខ៣នេះ "បញ្ហាសភាព ការណ៍ផ្ទៃក្នុងបក្ស គឺមានសមមិត្ត សុត ប្រធានៗ រោងចក្រជុសជួលបានប៉ះពាល់សីលធម៌ជាមួយនារី ឥឡូវនេះ បានចាប់ហើយ គឺចាប់ទាំងបុរស ចាប់ទាំងនារី។ មិត្តនេះ កាលមុនមានជាប់ចម្លើយពួក

អាក្សត់ អាជួន"។ នៅពេលដែលគេសួរលោក ថាតើហេតុអ្វីបានជាប្រភេទសារទូរលេខនេះ បានបញ្ជូនទៅកាន់ នួន ជា ទៅវិញនោះ? តាមលេខ ERN ដែលខ្ញុំលើកយកចម្លើយរបស់លោកមកបញ្ជាក់នោះ លោកបានលើកឡើងថា បញ្ហាពាក់ព័ន្ធទៅនឹងស្ថានភាពផ្ទៃក្នុង និងការប៉ះពាល់សីលធម៌ គឺគេត្រូវទាក់ទងជាមួយនឹង នួន ជា ដោយសារតែ នួន ជា ទទួលភារៈលើប្រជាជន។

[១០:៣១:៤៦]

តើនេះជាសង្ខេបត្រឹមត្រូវដែរឬទេ ដែលនៅក្នុងនេះ បញ្ហាសភាពការណ៍ផ្ទៃក្នុង និងការប៉ះពាល់សីលធម៌ជាមួយនារីនេះ ត្រូវបញ្ជូនប្រាប់លោក នួន ជា នោះ?

**ឆ៖** បាទ ខ្ញុំសម័យនុំង ខ្ញុំមិនអាចដឹងបានទេ ពីព្រោះថា គេចាត់ចែងទៅណាៗ គឺនៅលើ ប៉ុនគេអ្នកចាត់ចែង។ តែដោយខ្ញុំវិភាគ នេះ គឺថាលោក អស់លោក ឲ្យខ្ញុំជួយវិភាគ គឺខ្ញុំឈរលើការយល់ដឹងរបស់ខ្ញុំ ថាបានជាគេជូនទៅ អ៊ំ នួន ជា ពីព្រោះ អ៊ំ នួន ជា គាត់ទទួលខាងសង្គមកិច្ច និងវប្បធម៌។ ដូច្នេះ គឺអ្វីដែលប៉ះពាល់ទៅដល់សីលធម៌ គេត្រូវតែបញ្ជូនទៅមុខសញ្ញាដែលការងារដែល អ៊ំ នួន គាត់ទទួលខុសត្រូវបាទ។ នេះជាការវិភាគរបស់ខ្ញុំទេបាទ។

[១០:៣៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ សម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យគាត់អញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅពេលម៉ោងកំណត់គឺម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ខ្ញុំសូមត្រឡប់ចូលមកឯកសារមុនឈប់សម្រាកនេះឡើងវិញ។ ដែលខ្ញុំចង់លើកឡើងនូវខ្លឹមសារមួយចំនួន។ ពីមុននោះលោកបានលើកឡើងថា សារទូរលេខ៥៤ គឺនិយាយអំពី -- បើខ្ញុំយល់មិនច្រឡំទេ តើសារទូរលេខ៥៤ នេះជាលេខដែលត្រូវគេកំណត់សម្រាប់មជ្ឈិម ហើយតំណាងឲ្យសារទូរលេខដែលត្រូវបញ្ជូនចេញពីកន្លែងនោះតែម្តង ឬក៏យ៉ាងណា?

[១០:៥៥:០៣]

**លោក នង សុផង់៖**

**ឆ៖** បាទ សារទូរលេខនេះ មិនមែនជាសារទូរលេខចេញទេ គឺវាជាសារទូរលេខដែលចូលមកពីមូលដ្ឋានបាទ មកខាងមណ្ឌលគិរី។

**ស៖** សូមអរគុណ។ ប្រហែលជាមានការលំបាកក្នុងការបកប្រែភាសាហើយមើលទៅ។ ប៉ុន្តែថាតើលេខ៥៤ នេះតំណាងឲ្យអ្វីដែរ? ជាតំណាងឲ្យសារទូរលេខដែលត្រូវបានបញ្ជូនរួចហើយ ឬក៏យ៉ាងណា?

**ឆ៖** បាទ សារទូរលេខ៥៤ នេះ គឺជាសារទូរលេខដែលគេបញ្ជូន ហើយបានបកប្រែជាខ្លឹមសាររួចអស់ហើយ មិនមែនជា -- មិនទាន់ គឺជាសារដែលត្រូវធ្វើចេញនោះទេបាទ។ គឺជាសារដែលគេបានបកប្រែជាខ្លឹមសារច្បាស់លាស់ហើយ។ ឯលេខ៥៤ នេះគឺជាលេខរៀង បាទលំដាប់លេខរៀង គឺមុននេះគឺមានលេខទូរលេខ៥៣ វាមកម្តងហើយ។ ដូច្នេះ គឺលើកនេះ គេទៅដាក់ទូរលេខលេខ៥៤ បាទ។

[១០:៥៦:៣៥]

**សះ** បាទ សូមអរគុណ។ តើនិយាយអំពីលេខរៀងនេះ និយាយអំពីលេខពីដើមដំបូងមក រៀងរាល់ខែ រៀងរាល់ឆ្នាំ ដែលត្រូវចាប់ផ្ដើមចេញពី សូន្យៗ ឬក៏យ៉ាងណានោះ រហូតទៅដល់លេខចុងបញ្ចប់ណាមួយ ឬក៏យ៉ាងណាដែរ?

**ឆះ** បាទ លេខរៀងហ្នឹងគឺៗចាប់ពី០១ ទៅ។ ០១ រហូតដល់ហា -- ដល់ចំណុចចប់គឺ ៩៩។ ទៅដល់ ៩៩ ហើយ គឺត្រូវត្រឡប់មក ០១ វិញហើយ។ នេះជាការដាក់លេខរៀងគឺយ៉ាងដូច្នេះ។

**សះ** សូមអរគុណ។ លោកបាននិយាយថា សារទូរលេខជាក់លាក់មួយចំនួននោះ គឺមក -- គេផ្ញើមកពីមណ្ឌលគិរី តើធ្វើម៉េចបានជាលោកដឹងថាសារទូរលេខនេះ ជាសារទូរលេខមកពីខាងមណ្ឌល-គិរី?

**ឆះ** បាទ សារនេះគឺជាទិសដែលខ្ញុំធ្លាប់បកប្រែដែរបាទ។ គឺខ្ញុំបកប្រែផ្ទាល់តែម្ដង ទិសនេះ ហើយខ្ញុំធ្លាប់ឃើញអ្នកដែលចុះហត្ថលេខាលើសារនេះ គឺឈ្មោះ សារុន អ៊ីចឹងដែរ។

[១០:៥៨:២១]

**សះ** ដូច្នេះលោកដឹងថា សារុន គឺមានតួនាទីនៅមណ្ឌលគិរី តើត្រូវអ៊ីចឹងទេ?

**ឆះ** បាទ សារុន គឺជាគណៈតំបន់ទទួលខេត្តមណ្ឌលគិរីបាទ។

**សះ** សូមអរគុណ។ បើសិនយើងមើលទៅផ្នែកខាងក្រោមនៃទំព័រដដែលហ្នឹង នៅខាងក្រោមឈ្មោះ សារុន ហ្នឹង យើងឃើញមានកាលបរិច្ឆេទ គឺនិយាយពីថ្ងៃទី២៣ ខែមេសា ១៩៧៨ ហើយបន្ទាប់មក យើងឃើញមានដាក់ថា ទទួលនៅថ្ងៃ២៣ មេសា ៧៨ នៅម៉ោងម្ភៃសូន្យ។ ពាក្យថា "បានទទួលថ្ងៃ -- នៅថ្ងៃទី២៣ មេសា ៧៨" តើជាៗកាលបរិច្ឆេទមួយដែលគេសរសេរនៅនាទីចុងក្រោយនៃពេលទទួលសារហ្នឹងឬក៏យ៉ាងណា?

**ឆះ** បាទ ការដែលចុះកាលបរិច្ឆេទទទួល គឺខ្ញុំអ្នកចុះផ្ទាល់តែម្ដង។ សារហ្នឹង ខ្ញុំបានទទួល និងបកប្រែរួចនៅថ្ងៃណា ខែណា ឆ្នាំណា ហើយម៉ោងប៉ុន្មាន ខ្ញុំជាអ្នកដាក់ចុងក្រោយបំផុតបន្ទាប់ពីកាលបរិច្ឆេទរបស់គេអ្នកផ្ញើសារចូលមក។ សារទទួលគឺគេពេលចុះហត្ថលេខាថ្ងៃ២៣ ខែ៤ ៧៨។ ឯដែលខ្ញុំបកប្រែរួចចេញជាខ្លឹមសារទូរលេខនេះ គឺនៅ ថ្ងៃទី២៣ ខែ៤ ៧៨ ហើយម៉ោងហ្នឹងម្ភៃសូន្យ ហើយដែលខ្ញុំធ្វើហើយហ្នឹងបាទ។

**សះ** ហើយខាងក្រោមបន្ទាត់ហ្នឹង យើងឃើញបន្ទាត់មួយដែលដាក់សរសេរថា "ចម្លងជូន អ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវ៉ន, មន្ទីរ និងឯកសារ"។ ដូច្នេះដំបូងខ្ញុំសូមសួរលោក ថាតើអ្នកណាជាអ្នកដាក់ឈ្មោះ

ទាំងអស់ហ្នឹង ហើយដែលត្រូវថាកំណត់ថា ជាអ្នកសម្រេចកំណត់ថា ចម្លងជូនអ្នកណាៗនោះ?

[១១:០១:១៧]

**ផ៖** បាទ អ្នកដាក់ចម្លងជូន អ្នកដែលមានសិទ្ធិ គឺមានតែប្រធានខ្ញុំ ហើយនិងលោក ប៉ុន ហើយនិងលោក ថេរ ដែរបាទ លោកជាអ្នកចាត់ចែង។ ឯខ្ញុំគឺ ខ្ញុំមានសិទ្ធិតែដាក់ថ្ងៃខែដែលខ្ញុំបានទទួល ហើយនិងបកប្រែហើយនៅម៉ោងប៉ុន្មានៗបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងមើលទៅជួរហ្នឹងឃើញថា ជួរទាំងពីរនេះ គឺថាយើង -- គេមានវាយជាអក្សរពុម្ព ក៏ដូចជាសារទូរលេខផ្ទាល់តែម្តង។ តើ ប៉ុន និង ថេរ ដែលជាអ្នកសម្រេចបង្គាប់មកលោក ថាត្រូវចម្លងជូនអ្នកណាៗ ហើយលោកជាអ្នកវាយអក្សរនេះ? ឬក៏ការសរសេរថា ចម្លងជូននេះគឺត្រូវសរសេរឡើង វាយឡើងដោយ ប៉ុន និង ថេរ ឬក៏យ៉ាងណានោះ?

**ផ៖** បាទ រឿងចម្លងជូននេះ គឺខ្ញុំបកប្រែរួច ខ្ញុំមានសិទ្ធិតែត្រឹមដាក់ថ្ងៃខែទទួល និងម៉ោង។ ឯពេលដែលគេចម្លងជូន គេយកសារហ្នឹងទៅដាក់ក្រដាសកាបូន វាយបន្តទៀតបាទ ប៉ុន្មានសន្លឹកៗ បាទ។ ហើយជូនទៅអ៊ំណាៗ គឺតាមដែលគេអ្នកចាត់ចែង គេមានសិទ្ធិសម្រេច ត្រូវជូនទៅអ៊ំ ឬមិនជូនទៅអ៊ំណាបាទ។

[១១:០៣:៣០]

**ស៖** ដូច្នេះខ្ញុំចង់បញ្ជាក់បន្ថែមបន្តិច តើលោកវាយតែមួយច្បាប់ទេ ឬក៏នៅក្នុងមន្ទីររបស់លោកហ្នឹងបន្ទាប់ពីបកប្រែរួចហើយ ត្រូវវាយដោយប្រើជា -- ដោយប្រើកាបូនកាល់កែនេះវាយច្រើនច្បាប់ ឬក៏យ៉ាងណា?

**ផ៖** បាទ ខ្ញុំប្រើកាបូនបាទ ក្រដាសកាបូនច្រើនច្បាប់ដែរ។ គឺអាស្រ័យទៅលើខ្លឹមសារដែល ប៉ុន និង ថេរ បានកំណត់។ ជូនណាក៏គេឱ្យ បញ្ជាដាក់ចម្លងជូនស្រេចតែម្តង ក៏បានដែរ ពីព្រោះខ្លឹមសារហ្នឹងគឺបាន គេបានណែនាំអស់ហើយថា ខ្លឹមសារអ្វីដែលទូទៅគឺ ធម្មតាគឺដាក់ជូនទៅអ៊ីចឹងតែម្តង។ ប៉ុន្តែអ្វីដែលខ្លឹមសារណាដែលខ្ញុំមិនច្បាស់ មុននឹងវាយដាក់ចម្លងជូន ខ្ញុំត្រូវសួរយោបល់ពីគេសិន បាទ។

**ស៖** សូមអរគុណចំពោះការបំភ្លឺរបស់លោក។ បើសិនជាយើងមើលទៅលើបុគ្គលជាក់លាក់មួយចំនួន ដែលបានរៀបរាប់ឈ្មោះនៅក្នុងបន្ទាត់ហ្នឹង នេះគឺឈ្មោះដែលលោកបានលើកឡើងនៅក្នុងចម្លើយ E3/64 ខ្មែរ ERN 00328041, បារាំង 00411709, ហើយ ERN អង់គ្លេស 00334058។ លោកបានមើលទៅលើសារទូរលេខនេះហើយ លោកបានបកប្រែគឺ ដាក់ថា "អ៊ំ នួន គឺសំដៅទៅលើ នួន

ជា, ការចម្លងជូនអ៊ំ គឺសំដៅថា ប៉ុល ពត ហើយកាលណាដាក់ថា អ៊ំនួន គឺ នួន ជា, អ៊ំវ៉ាន់ គឺ អៀង សារី, អ៊ំវន គឺ វន វ៉េត ដែលជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។ ហើយកាលនិយាយ "មន្ទីរ" គឺសំដៅទៅលើ មន្ទីរ៨៧០ ហើយពាក្យថា "ឯកសារ" គឺជាកាលប្បវត្តិដែលរក្សាទុកនៅក្នុងមន្ទីរឯកសារ។ សម្រាប់ មន្ទីរគឺ មន្ទីរ៨៧០ ប៉ុន្តែសម្រាប់ពាក្យថា ឯកសារ គឺត្រូវរក្សាទុកនៅកន្លែងបកប្រែ"។ ខ្ញុំចង់សួរបញ្ជាក់ ថាតើនេះគឺជាការបកស្រាយរបស់លោកយ៉ាងដូច្នេះ ឬក៏យ៉ាងណាដែរ?

[១១:០៧:០១]

**ឆ៖** បាទ ចម្លើយដែលលោកបានអានអម្បាញ់មិញ គឺជាការពិតបាទ គឺជាចម្លើយពិតរបស់ខ្ញុំ បាទ។

**ស៖** សូមអរគុណ។ នៅពេលដែលគេណែនាំគឺ ប៉ុន ឬក៏ ថេរ នេះឲ្យលោកបង្កើត ឬក៏ឲ្យលោក ចម្លងជាច្រើនច្បាប់។ អ៊ីចឹងក្រោយមកទៀត តើលោកត្រូវធ្វើអ្វី?

**ឆ៖** បាទ បន្ទាប់ពីវាយអង្គុលីលេខរួចហើយ ខ្ញុំក៏បានរៀបចំសារហ្នឹងដាក់ក្នុងស្រោមសំបុត្រ ហើយបញ្ជូនទៅក-១ បាទ។

**ស៖** ចុះបើសិន -- តើសារបួន ឬក៏ប្រាំច្បាប់ត្រូវដាក់ក្នុងស្រោមសំបុត្រតែមួយ ឬក៏ត្រូវដាក់ក្នុង ស្រោមសំបុត្រផ្សេងៗគ្នា ដើម្បីជូនទៅមនុស្សដែលបានរៀបរាប់ឈ្មោះចម្លងជូននេះ?

**ឆ៖** បាទ សារទាំងអស់នោះគឺ ដាក់ទៅតែស្រោមសំបុត្រមួយទេ។ ពេលទៅដល់ ក-១ ទើប លោក ប៉ុន ឬ ថេរ គេចាត់ចែងទៅតាមអ្វីដែលគេចាត់ចែងទៅជូនអ៊ំណាៗ តាមជាក់ស្តែងនៅក្នុងសារ របស់ហ្នឹង សារទាំងអស់នេះបាទ តាមឈ្មោះបាទ។

[១១:០៩:០៦]

**ស៖** បើសិនយើងត្រឡប់ចូលទៅអក្សរសរសេរដោយដៃ ដែលនៅផ្នែកលើខាងឆ្វេងដែលដាក់ ថា "អ៊ំនួន" លោកបានគិតថា ជាអក្សរដៃរបស់ ថេរ។ នៅក្នុងករណីនេះ បើសិនជាខ្ញុំយល់មិនច្រឡំនោះ ទេ អ្វីដែលលោកនិយាយថា សំណេរដោយដៃនេះ គឺត្រូវបានដាក់ចូលទៅក្នុងឯកសារបន្ទាប់ពីវាទៅដល់ ក-១ ហើយ តើអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ សំណេរដោយដៃនេះ ខ្ញុំមិនដឹងទេ ដែលខ្ញុំបក គឺសារហ្នឹងមិនមានអ៊ំនួន នៅលើខាង លើខាងឆ្វេង ផ្នែកខាងឆ្វេងនៃសារហ្នឹងទេ។ អាហ្នឹងគឺជាអក្សរ ថេរ ដែលគេជាអ្នកចាត់ចែងគេយល់ថា ខ្លឹមសារទាំងអស់នេះវាទាក់ទិននឹងអ៊ំ នួន ហើយបានគេដាក់ថា សំដៅអ្នកដោះស្រាយបញ្ហាហ្នឹង គឺអ៊ំ នួន

ហ្នឹងតែម្តងបាទ។

**ស៖** តើលោកត្រូវបញ្ជូនសារទូរលេខបីបួនច្បាប់ក្នុងស្រោមសំបុត្រតែមួយទៅ ក-១ ហ្នឹងដោយរបៀបណា?

**ឆ៖** បាទ នៅក្នុងកន្លែងរបស់ខ្ញុំមាននីរសារដែលខ្ញុំអាចចាត់ចែងផ្ញើទៅតាមនីរសារយកទៅកន្លែងមុខ ក-១ ដែលមានរោងយាមមួយប្រចាំការនៅកន្លែងហ្នឹងជាប់។ អ៊ីចឹងនីរសាររបស់ខ្ញុំ នៅសាលាខ្ញុំហ្នឹងខ្ញុំអាចប្រើប្រាស់ក្មេងណាដែលទំនេរឲ្យគេយកទៅជូននៅកន្លែងមុខរោងយាមនៅក-១ តែម្តងបាទ។

[១១:១១:៤៣]

**ស៖** នៅពេលដែលយើងពិនិត្យទៅមើលឈ្មោះទាំងអស់នេះ នៅក្នុងចម្លើយលើកទី២ របស់លោកត្រង់ទំព័រ ដែលមាន ERN ជាភាសាខ្មែរ 00294536, ERN ជាភាសាបារាំង 00379433 និង ERN ជាភាសាអង់គ្លេស 00483964 គឺឯកសារ E3/67។ លោកបានឆ្លើយដូចតទៅ៖ “ស្ទើរតែសារទូរលេខ -- សារទូរលេខស្ទើរតែទាំងអស់ត្រូវបញ្ជូនទៅអ៊ំ ដូចដែលខ្ញុំបានឃើញកាលពីមុនៗមក ប៉ុន្តែ -- សូមកែតម្រូវ ប៉ុន្តែក្នុងករណីដែលអ៊ំមិននៅ គឺមិនចាំបាច់ដែលត្រូវចម្លងជូនគាត់ទេ”។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះទេ ថាតើចម្លើយរបស់លោកហ្នឹងគឺត្រូវតែចម្លងជូនអ៊ំគ្រប់ទាំងអស់ ឬក៏ក្នុងករណីខ្លះ គឺថាមិនត្រូវចម្លងជូនគាត់ទេ បើសិនណាជាគាត់មិនមានវត្តមានទេនោះ?

**ឆ៖** បាទ រឿងហ្នឹង អ៊ីចឹងមែន។ ដូចចម្លើយខ្ញុំបានឆ្លើយរួចមកហើយ គឺមុននឹងខ្ញុំដាក់វាយចម្លងជូន ខ្ញុំសួរយោបល់គេសិន ថាតើសារនេះជូនអ៊ំណាខ្លះ? សារប្រភេទនេះ ដូចជាក្នុងសារខ្លះមានដាក់ជូនតែអ៊ំ អ៊ំនួន ឯអ៊ំវ៉ាន់ អ៊ំវន អីគឺថាមិនបាច់ទេ ព្រោះគាត់មិននៅហ្នឹងទេ។ ដូច្នេះដាក់តែអ៊ំ អ៊ំនួន មន្ទីរឯកសារទៅបានហើយ។ អ៊ីចឹងខ្ញុំក៏ដាក់តាមការណែនាំរបស់គេបាទ គឺដែលមិនបានជូនទាំងអស់ គឺមកពីអវត្តមានបាទ គាត់ទៅធ្វើការណាក៏មិនដឹង នៅក្រៅប្រទេសក៏មិនដឹង។ ដូចជា លោក អៀង សារី នេះគឺគាត់ទទួលបន្ទុកការងារបរទេស ដូច្នេះពេលដែលគាត់មិននៅក្នុងប្រទេស យើងមិនចាំបាច់វាយសារហ្នឹងជូនគាត់ទេបាទ ព្រោះគាត់មិនៗមានឆ្លើយឆ្លងបានទេ សារហ្នឹងបាទ។

[១១:១៤:៤៦]

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយលើកទី៣ របស់លោកគឺ E3/64 សូមកែតម្រូវ ចម្លើយលើកទី១ របស់លោក ERN ជាភាសាខ្មែរ 00320 -- (សូមកែតម្រូវ) ចម្លើយលើកទី១ របស់លោក ERN ជាភាសាខ្មែរ 00320 (កែតម្រូវ) 00328037, ជាភាសាបារាំង 00411605 និងជាភាសា

អង់គ្លេស 00334055។ លោកបានឆ្លើយដូចខាងក្រោមនេះ “សំណួរ៖ តាមដែលលោកយល់ តើការចម្លងជូនទាំងអស់នេះ នឹងធ្លាក់ទៅដល់ដៃអ្នកដែលត្រូវចម្លើយជូនទេ? ចម្លើយថា៖ ខ្ញុំជឿជាក់ថាពួកគាត់នឹងបានទទួល ព្រោះនីរសារ និងអ្នកបកប្រែដែលបានជ្រើសរើសឲ្យធ្វើការនៅទីនោះ គឺមានភាពស្មោះត្រង់ណាស់។ សំណួរ៖ តាមការចងចាំរបស់លោក ថាតើមានសារទូរលេខណា ដែលបានបញ្ជូនចេញទៅនោះ មិនដែលបានទៅដល់អ្នកដែលត្រូវចម្លងជូននោះដែរឬទេ? ចម្លើយ៖ ខ្ញុំមិនដែលជួបរឿងបែបនេះទេ។ ថាតើមានបញ្ហាក្នុងការផ្ញើបញ្ជូននេះទេ? ចម្លើយថា អាចនឹងមានបញ្ហាក្នុងការចម្លងជូននេះ”។ តើនេះគឺជាចម្លើយត្រឹមត្រូវរបស់លោក ជូនទៅអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

[១១:១៦:១៤]

**ឆ៖** បាទចម្លើយនេះគឺពិត ដូចខ្ញុំបានឆ្លើយកាលហ្នឹងមែន។ ហើយខ្ញុំក៏បានឆ្លើយថា វានឹងអាចមានបញ្ហាដូចជាសំណួរលោកឡើង -- លោកលើកឡើងមែន។ ពីព្រោះថា ករណីខ្លះ សារខ្លះដែលបែកការសម្ងាត់ វាមានច្រើនបែបច្រើនយ៉ាង។ ទី១ វាទាក់ទងនឹងនីរសារ ដែលជាអ្នកនាំសារ ស្មោះត្រង់ឬមិនស្មោះត្រង់។ ទី២ ទាក់ទងនឹងអ្នកចាត់ចែង សារទូរលេខដែលគេបកបានហើយហ្នឹង គេចាត់ចែងឲ្យទៅដល់ ឬក៏មិនចាត់ចែង ឬក៏មិនបញ្ជូនទៅ។ នេះករណីបែកការ ឬមួយក៏ករណីបាត់។ ករណីដែលបាត់ឯកសារ ឬមួយក៏គេយកបានការសម្ងាត់ហ្នឹង គឺចុងបំផុតគឺនៅលើត្រង់អស់លោកអ៊ំៗហ្នឹង ទុកដាក់ឯកសារហ្នឹងបានល្អត្រឹមត្រូវ ឬមួយក៏ធ្វេសប្រហែស បណ្ដាលឲ្យចារកម្មគេយកបាន។ ដូច្នេះការទំនាក់ទំនងពីរឿងបែកការសម្ងាត់ ឬមួយក៏បាត់សារនេះ វាច្រើនដំណាក់បាទ។

**សៈ** បាទ សូមទុកស្ថានភាពនេះចោលមួយអន្លើសិនចុះ។ បើខ្ញុំយល់តាមចម្លើយរបស់លោកនេះមិនច្រឡំទេ គឺតាមការយល់របស់លោកគឺថា អ្នកទទួល អ្នកដែលត្រូវទទួលសារទាំងនោះ ក្នុងករណីនេះគឺអ៊ំៗហ្នឹង ដែលគឺថាត្រូវតែបានទទួលនូវសារដែលបានផ្ញើជូនទៅពួកគាត់។ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ ភាគច្រើន ដែលនេះជាការប៉ាន់ស្មាន និងការវាយតម្លៃរបស់ខ្ញុំថា សារភាគច្រើន ពិតជានឹងបានពួក ពួកគាត់ទទួល។ ពីព្រោះថា ការរៀបចំ ការចាត់តាំង គឺអស់លោកបានរៀបចំអ្នកដែលស្មោះត្រង់ជាមួយ -- អ្នកដែលមានវិន័យ ហើយនិងអ្នកដែលធ្វើការហ្មត់ចត់។ បើអ្នកធ្វេសប្រហែសអ្នកដែលធ្វើការមិនហ្មត់ចត់ទេ ច្បាស់ជាគេមិនយកមកធ្វើការងារដែលមានលក្ខណៈសម្ងាត់ ហើយសំខាន់យ៉ាងនេះទេ។

[១១:១៩:២២]

**ស៖** យោងទៅលើការងាររបស់លោក តើលោកចង់និយាយថា ប៉ុន ឬក៏ ថេរ ឬអ្នកដទៃទៀត គឺថា ត្រូវជួបគ្នាដើម្បីពិភាក្សាអំពីតួនាទីរបស់លោក ក៏ដូចជាតួនាទីរបស់អ្នកដទៃទៀត ដើម្បីឲ្យបំពេញការងារនេះឲ្យបានត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ មានការប្រជុំ ដើម្បីដកពិសោធន៍លើកិច្ចការដែលបានអនុវត្ត ថាតើការធ្វើកន្លងមកនេះ វាមានចំណុចខ្លាំងអី ចំណុចខ្វះខាតអី គឺតែងតែមានការប្រជុំយ៉ាងហោចណាស់ក៏១ខែ ២ ឬ៣ខែម្តងដែរ ជាមួយលោក អស់លោកអ្នកដឹកនាំពីលោកខ្ញុំបាទ។ ដើម្បី ពិភាក្សាបញ្ហាបច្ចេកទេសផង បញ្ហាការងារដែលអនុវត្តល្អ ឬមិនល្អផង ហើយយើងកែលម្អតទៅទៀតដើម្បីធ្វើយ៉ាងណាឲ្យការងាររបស់យើងកាន់តែមានលក្ខណៈល្អប្រសើរបាទ។

[១១:២១:៤៤]

**ស៖** សូមអរគុណ។ បាទ ខ្ញុំសូមចូលទៅមើលចម្លើយលើកទី២របស់លោក គឺ E3/67។ ERN ជាភាសាខ្មែរ 0029548 (ស៊ីក), ERN ជាភាសាបារាំង 00374942, ERN ជាភាសាអង់គ្លេស 00483974។ លោកបានឆ្លើយដូចតទៅ នៅត្រង់កថាខណ្ឌ៣៨៖ “គេបាន -- គេណែនាំដោយផ្ទាល់មាត់ ខ្ញុំបានស្តាប់សេចក្តីណែនាំពីឈ្មោះ ប៉ុន តាមរយៈអង្គប្រជុំជាមួយ ប៉ុន ប្រសិនបើគេចង់ណែនាំអ្វី គេចុះមកណែនាំយើង។ ខ្ញុំអនុវត្តតាមសេចក្តីណែនាំនេះ ហេតុដូច្នេះបានជាខ្ញុំរស់រហូតដល់ពេលនេះ។ ខ្លឹមសារនៃសារទូរលេខទាក់ទងទៅនឹងផ្នែកណា គឺជូនទៅផ្នែកនោះតែម្តង”។ នៅពេលមើលទៅលើខ្លឹមសារនេះ។ លោក សុផង់ គឺគេមានអង្គភាពដែលនិយាយអំពីសីលធម៌ ហើយនិងវិន័យ។ តើការដែលខ្ញុំយល់បែបនេះគឺត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** បាទ នៅក្នុង ខ ចំណុចទី៣នេះ គឺនិយាយអំពីរឿងប៉ះពាល់សីលធម៌ជាមួយនារី គឺបានន័យថា មានការរំលោភផ្លូវភេទបាទ។ អ៊ីចឹងចំណុចខាងសីលធម៌នេះ គឺវាជាផ្នែកមួយដែលគេចារខាងលើថា “អំនួន” ហ្នឹងហើយបាទ។

[១១:២៣:០៦]

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមចូលមកសំណួររបស់ខ្ញុំ។ ខ្លឹមសារដែលចេញពីចម្លើយនេះហាក់បីដូចជារៀបរាប់អំពីវិន័យ និយាយអំពីប្រតិបត្តិការក្នុងការអនុវត្តវិន័យ។ លោកនិយាយថា “លោករស់រានមកដល់សព្វថ្ងៃ ដោយសារតែលោកធ្វើតាមសេចក្តីណែនាំ”។ ដូច្នេះ ខ្ញុំតាមដែលខ្ញុំយល់

ថាតើត្រឹមត្រូវទេ ដែលថានេះ គឺជាកិច្ចការមួយ ឬក៏ប្រតិបត្តិការមួយដែលត្រូវបំពេញយ៉ាងហ្មត់ចត់បំផុត។ តើយ៉ាងដូច្នេះដែរ ឬក៏អត់ទេ?

**ឆ៖** បាទ នេះជាលាក់ការណ៍ និងជាគោលការណ៍នៃ ឬក៏ជាកិច្ចប្រតិបត្តិការដែលមាននៅក្នុងការិយាល័យរបស់ខ្ញុំ ដែលខ្ញុំបានអនុវត្តជាបន្តបន្ទាប់តាមគោលការណ៍ និងតាមបទបញ្ជា ឬក៏តាមវិន័យដែលខាងលើដាក់មកសម្រាប់កិច្ចដំណើរការនៃការងាររបស់ការិយាល័យយើងខ្ញុំបាទ។

[១១:២៥:២៦]

**ស៖** សូមអរគុណ។ តើលោកដឹងទេថា ប៊ុន ហើយនិង ថេរ ហ្នឹងទទួលការណែនាំមកពីខាងណាដែរ?

**ឆ៖** បាទ ប៊ុន និង ថេរ នេះគឺគាត់ជាប់នៅផ្ទាល់ជាមួយ ប៉ុល ពត។ ដូច្នេះ ខ្ញុំគិតថា -- ហើយគាត់មានតួនាទីជាលេខាធិការដែរ។ អ៊ីចឹងខ្ញុំអាចយល់ថា ជាមតិដែលគាត់ណែនាំខ្ញុំទាំងប៉ុន្មាននេះ គឺមិនមែនចេញដោយផ្ទាល់ គំនិតខ្លួនគាត់ផ្ទាល់ទេ គឺគាត់ទទួលការណែនាំពីខាងលើ ឬមួយក៏គាត់បានទៅចូលធ្វើកំណត់ហេតុចូលរួមការប្រជុំជាមួយអចិន្ត្រៃយ៍ដែរបានៗគាត់ណែនាំបន្តមកយើងខ្ញុំនេះ។

**ស៖** សូមអរគុណ។ បើខ្ញុំយល់មិនច្រឡំទេ ពេលខ្លះគឺសេចក្តីណែនាំហ្នឹង ដែលគេបានបញ្ជូនទៅឲ្យលោក ដើម្បីឲ្យលោកវាយជាអក្សរ ហើយឈានទៅដល់ការចែកចាយសារ ឬក៏ការពិភាក្សាហ្នឹង គឺសេចក្តីណែនាំ លោកយល់ថាមកពីគណៈអចិន្ត្រៃយ៍អ៊ីចឹងទេ?

**ឆ៖** បាទ សេចក្តីណែនាំនេះ មិនមានអ្វីជាលាយលក្ខណ៍អក្សរ ឬជាភស្តុតាងការប្រជុំអចិន្ត្រៃយ៍អី មកបង្ហាញខ្ញុំផ្ទាល់ទេ ប៉ុន្តែគឺដោយសារគាត់នៅជាប់ផ្ទាល់ជាមួយប្រធានគណៈអចិន្ត្រៃយ៍តែម្តង គឺគាត់អាចនឹងយកមតិណែនាំបន្តហ្នឹងមកផ្សព្វផ្សាយ មកពន្យល់យើងខ្ញុំបាទ។

[១១:២៧:០២]

**ស៖** សូមអរគុណ។ នៅពេលនេះយើងត្រឡប់មើលឯកសារ D200/2.2 ឬក៏ E3/513 ដែលសារទូរលេខដែលយើងបានពិភាក្សាគ្នាមុននេះ។ លោកបានបញ្ជាក់មុននេះថា គឺគេបានយោងមន្ទីរ៨៧០នៅក្នុងហ្នឹង ដែលវាជាកន្លែងមួយផ្សេងមួយទៀត។ នៅពេលនេះ ខ្ញុំសូមចាប់ផ្តើមសួរទៅលើឯកសារនេះ។ ខ្ញុំយល់ត្រឹមត្រូវដែរឬទេ ឯកសារសារទូរលេខនេះគឺរក្សាទុកនៅមន្ទីរ ក-១ របស់ ប៊ុន តើអ៊ីចឹងដែរឬទេ?

[១១:២៨:០៤]

**ឆ៖** បាទ ពាក្យថា "ដាក់នៅមន្ទីរ" មួយសន្លឹកហ្នឹងគឺគេតម្កល់ទុកនៅមន្ទីរ៨៧០ គឺជាកន្លែងត្រង់ណាមិនដឹងទេ ខ្ញុំដឹងថានៅ ក-១ ហ្នឹងតែម្តង គឺកន្លែង ប៉ុន ហ្នឹងតែម្តង ហើយឯរឿងឯកសារហ្នឹងគឺដឹងថា នៅកន្លែងខ្ញុំក៏មានតម្កល់ទុកឯកសារ បើឯកសារណាដែលខ្ញុំបកប្រែ គឺខ្ញុំតម្កល់ទុកនៅកន្លែងខ្ញុំហើយ។ គេចង់មកផ្ទៀងផ្ទាត់អីៗ គឺបានគ្រប់ពេលវេលាទាំងអស់។

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់បំភ្លឺ។ ចំណុចនេះមានន័យថា នៅពេលដែលលោកបកប្រែសារទូរលេខ គឺមានមួយច្បាប់ជាឯកសារថតចម្លង គឺទុកនៅមន្ទីររបស់លោក ហើយ ប៉ុន នោះនៅមន្ទីរក-១នោះ ក៏មានឯកសារហ្នឹងមួយច្បាប់ទុកនៅទីនោះដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន គឺខ្ញុំគឺទុកសន្លឹកចុងក្រោយគេដែលមិនសូវច្បាស់ហើយ ទុកឯកសារហ្នឹង។ អាកន្លែងណាច្បាស់ៗគឺជូនទៅក-១ អស់ហើយបាទ។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ តើមន្ទីរ៨៧០ នេះតំណាងអ្វីដែរ? គឺជាមន្ទីរអ្វីដែរ?

**ឆ៖** បាទ មន្ទីរ៨៧០ គឺជាមន្ទីររបស់មជ្ឈិមបក្ស បាទ។ គឺដែលមាន ប៉ុល ពត ជាប្រធានបាទ។

**ស៖** សូមអរគុណ។ តើការដាក់លេខមន្ទីរ៨៧០ នេះ ដូចដែលលោកបានរៀបរាប់អម្បាញ់មិញគឺមានលក្ខណៈដូចគ្នា ឬក៏ខុសគ្នាទៅនឹង ៨៧០ ដែលលោកបានលើកឡើងមុននេះ?

[១១:៣១:០៤]

**ឆ៖** បាទ ៨៧០ នេះ គឺជាមន្ទីរមជ្ឈិម -- ជាមជ្ឈិមបក្ស ឬក៏ថា ជាគណៈមជ្ឈិម។ គឺលេខនេះមិនមានការប្រែប្រួលទេ តាំងពីមុន៧៥ ក៏គេប្រើពាក្យ ៨៧០ នេះ ក្នុងនាមមជ្ឈិមដែរ រហូតដល់ក្រោយរំដោះប្រទេសហើយ ក៏លេខ៨៧០ នេះ មិនមានការប្រែប្រួលទេបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលខ្ញុំមើលចម្លើយរបស់លោកលើកដំបូងលើបញ្ហា ៨៧០ នេះ គឺ E3/64 ឯកសារ E3/64 ខ្មែរ ERN គឺ 00328036, បារាំង គឺ 00411704, អង់គ្លេស គឺ 00334053។ យើងមានចំណុចនៅក្នុងនោះ ដូចតទៅ៖ "សំណួរ តើគណៈ៨៧០ មានន័យដូចម្តេច? សំដៅលើអ្នកណា? ឆ្លើយ៖ សំដៅលើគណៈមជ្ឈិមទាំងមូលតែម្តង"។ តើនេះ ជាចំណុចដែលខ្ញុំសង្ខេបទៅលើចម្លើយរបស់លោក ត្រឹមត្រូវដែរឬទេ ដែលលោកបានលើកឡើងដូច្នេះ ថា គណៈ៨៧០ គឺគណៈមជ្ឈិមទាំងមូលតែម្តង?

**ឆ៖** បាទ ត្រឹមត្រូវ ពីព្រោះថា ពាក្យ "៨៧០" នេះ គឺមិនមែនសំដៅលើឈ្មោះបុគ្គលណាម្នាក់

ឬក៏បងណាម្នាក់ទេ។ បើគេសរសេរចុះហត្ថលេខានៅកន្ទុយសារនេះ ដាក់ថា “៨៧០” គឺពុំមែនជាក្នុងនាមជាបុគ្គលទេ គឺក្នុងនាម គណៈមជ្ឈិម បាទ។ ឯការជូនមកវិញ ក៏ដូច្នោះដែរ។ បើជូនបងជាទីគោរព គឺបានសេចក្ដីថា សំដៅទៅលើបងទី១ គឺ ប៉ុល ពត ទេ។ ក៏ប៉ុន្តែកន្លែងខ្លះ គេជូនគណៈ៨៧០, ជូនអង្គការ៨៧០។ អាហ្នឹង គឺបានន័យថា គេជូនមកគណៈមជ្ឈិម។

[១១:៣៤:១២]

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។ ដើម្បីបញ្ចប់ការសួរសំណួរទៅលើឯកសារនេះ នៅក្នុងចំណុចដែលដាក់ថា “ចម្លងជូននោះ” យើងឃើញមាន អ៊ំទាំងពីរ ដែលក្នុងនោះមាន ប៉ុល ពត និងមន្ទីរ៨៧០។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចសន្និដ្ឋានថា ឯកសារនុ៎ងគឺមានពីរច្បាប់។ មួយបញ្ជូនផ្ទាល់ទៅ ប៉ុល ពត មួយច្បាប់ទៀត បញ្ជូនទៅមន្ទីរ៨៧០ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ កម្រមានតែពីរណាស់ សារ គឺច្រើនក៏បីបួននាក់ដែរ ហើយនិងមន្ទីរឯកសារ។ អ៊ីចឹងមិនមានគេធ្វើតែពីរសន្លឹកទេ គ្រប់សារទាំងអស់ គឺយ៉ាងហោចណាស់ក៏មានបួនសន្លឹកអីដែរ។ ឯរឿងអ៊ំ និងមន្ទីរនោះ បើសិនណាជា -- គឺវាដាច់ដោយឡែកពីគ្នា។ បើ អ៊ំ បានន័យថាជូនទៅ ប៉ុល ពត ឯមន្ទីរគឺមានន័យថាសម្រាប់មន្ទីររបស់៨៧០ របស់អង្គការ៨៧០ ហ្នឹងមួយច្បាប់។

**ស៖** សូមអរគុណ។ នៅពេលពិនិត្យមើលបែបបទ និងខ្លឹមសារនៃសារទូរលេខនោះ អ្វីដែលខ្ញុំចង់សួរបន្ទាប់ គឺយើងពិនិត្យមើលសារទូរលេខមួយចំនួនឲ្យបានហ្មត់ចត់ ប៉ុន្តែយើងចំណាយពេលបន្តិចបន្តួចតែប៉ុណ្ណោះទៅលើសារទូរលេខទាំងអស់នេះ។ ហើយខ្ញុំសូមឲ្យលោកធ្វើការពន្យល់ចំពោះអ្វីដែលលោកបានយល់ទៅលើបែបបទនៃសារទូរលេខ និងខ្លឹមសារនៃសារទូរលេខ។

[១១:៣៦:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានជាទីគោរព! ឯកសារបន្ទាប់--

**លោក អាកឡូវ វ៉ែកគែន៖**

បាទ លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ គឺជាការកត់សម្គាល់ដើម្បីជាកំណត់ត្រាប្រតិចារឹកព្រោះ ពីព្រោះថាសំណួររបស់សហព្រះរាជអាជ្ញានេះ ហាក់ដូចជាអាចជំទាស់បាន ដោយសារមានភាពខុសគ្នារវាងកំណត់ហេតុស្ដាប់ចម្លើយដែលគាត់បានលើកឡើង ហើយនិងខ្សែអាត់ទៅលើពាក្យគណៈ៨៧០។ នៅក្នុងចម្លើយដែលលោកព្រះរាជអាជ្ញាបានលើកឡើងនោះ គឺថាមានលើកឡើងថា គឺថាពាក្យ

ថា “គណៈ៨៧០” ហ្នឹង មានន័យថា “គណៈមជ្ឈិម” ក៏ប៉ុន្តែទន្ទឹមនឹងនោះ បើសិនជាយើងស្តាប់ខ្សែអាត់ដែលបានធ្វើឡើងដោយផ្នែកបម្រើការនៅតុលាការយើងនេះ គឺថាយើងឃើញថានៅត្រង់ចំណុចនេះ សាក្សីបានឆ្លើយថា “បាទ គណៈ៨៧០ នោះ សំដៅគណៈមជ្ឈិម ហើយនិងគណៈអចិន្ត្រៃយ៍”។ អ៊ីចឹង គឺថានៅក្នុងខ្សែអាត់នោះ ចម្លើយខុសគ្នា។ ដូច្នេះការដកស្រង់ដោយចេតនាបែបនេះរបស់លោកសហព្រះរាជអាជ្ញា គឺថាត្រូវតែសួរដោយមានការសួរផ្ទុញ បើគាត់លើកឡើងរបៀបនេះ។

[១១:៣៨:១៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការលើកឡើងនេះ ដោយខ្លាំងតែម្តង។ វាជាការលើកឡើងមិនត្រឹមត្រូវ។ ខ្ញុំបានឮសាក្សីនិយាយដោយផ្ទាល់ចេញពីសម្តីរបស់គាត់ ហើយគាត់និយាយទៅលើពាក្យនេះ។ នេះគឺជាការប៉ុនប៉ងពីខាងមេធាវីការពារក្តី អ្វីដែលសាក្សីគួរតែនិយាយ និងមិនគួរនិយាយ។ ដូច្នេះហើយលោកប្រធាន គួរតែណែនាំមេធាវីនៅត្រង់ចំណុចនេះ។ ប្រសិនបើមានការជំទាស់ គួរតែបញ្ជាក់ការជំទាស់ឲ្យបានត្រឹមត្រូវ ចៀសវាងការនិងបញ្ចេញយោបល់បែបនេះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ដំណាក់កាលដូចជាមានពីរ ទី១ សាក្សីនៅទីនេះហើយ។ ហើយភស្តុតាងគឺផ្តល់នៅចំពោះមុខអង្គជំនុំជម្រះក្នុងពេលសវនាការ។ ចំណែកបញ្ហាមានការខុសគ្នាក្នុងការផ្ទៀងផ្ទាត់នោះ គឺជាសិទ្ធិរបស់លោកមេធាវីនៅក្នុងការតាំងសំណួរដល់វេនលោកសួរ។ លោកបានប្រើពាក្យអំមិញហើយសួរផ្ទុញ ហើយសំណួរបែបនេះ គឺយើងដូចជាស៊ាំហើយ ស៊ាំនឹងសំណួរផ្ទុញនេះហើយ។ ដូច្នេះរង់ចាំដល់ពេលវេនរបស់លោកក្នុងការតាំងសំណួរអ្វីដែលវាមិនត្រឹមត្រូវ និងមិនសមស្របហ្នឹង ដើម្បីថាតើចម្លើយបែបហ្នឹង វាអាចជឿជាក់បានដែរអត់? មិនមែនមកលោកមកធ្វើពាក់កណ្តាលទីដូច្នេះទេ។

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកបន្តទៅទៀតទេ។ សូមឲ្យលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

បន្តចូលទៅដល់ឯកសារទី២ លោក សុផង់ លោក លោកស្រីចៅក្រម ឯកសារនេះគឺE3 មានលេខ E3/1679។ យើងខ្ញុំសូមអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះផ្តល់ឯកសារមួយច្បាប់នេះជូនទៅដល់

សាក្សី។ វាជាទូរលេខ ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ១៩៧៥។ សូមអនុញ្ញាតពីលោកប្រធាន ផ្តល់ឯកសារនេះមួយច្បាប់ជូនសាក្សី។

[១១:៤០:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ប៉ុន្តែសូមឲ្យបញ្ជាក់នូវអត្តសញ្ញាណឯកសារឲ្យបានជាក់លាក់ផង។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានជាទីគោរព! គឺឯកសារលេខ E3/1679 វាជាសារទូរលេខតែមួយសន្លឹកតែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ឯកសារនេះគឺឯកសារចេញមកពីថ្ងៃ -- ចេញមកពីឆ្នាំ១៩៧៥ គឺវារយៈពេលមុនឯកសារមួយអម្បាញ់មិញដែលយើងបានឃើញ។ ប្រសិនបើយើងមើលក្បាលទំព័រនៃសារទូរលេខនេះ មានទូរលេខ -- មានដាក់ថា “ទូរលេខ១៥ សូមគោរពជូនសមមិត្ត បងប៉ុល ជាទីស្នេហា” ហើយខ្ញុំគិតថា ប៉ុល នេះគឺជា ប៉ុល ពត មែនដែរឬទេ?

[១១:៤២:១៨]

**លោក នង សុផង់៖**

**ឆ៖** បាទ ត្រឹមត្រូវណាស់បាទ។

**ស៖** នៅពេលដែលយើងមើលខាងក្រោមទំព័រនេះ ជាភាសាខ្មែរ។ សូមអនុញ្ញាតឲ្យបញ្ចាំងលើអេក្រង់ទូរទស្សន៍ផង ដើម្បីឲ្យយើងឃើញទាំងអស់គ្នា។ ថ្ងៃនោះគឺដាក់ថា “៣០.១១.៧៥” យើងឃើញមានឈ្មោះ ឆុន ដែលជាអ្នករៀបចំសរសេរទូរលេខនេះឡើង។ តើលោកអាចបញ្ជាក់ថា បុគ្គល ឆុន នេះគឺជានរណាដែរ?

**ឆ៖** បាទ ខ្ញុំមិនចាំ ខ្ញុំមិនស្គាល់ ពីព្រោះសារទូរលេខនេះមិនមែនជាខ្ញុំបានបកប្រែទេ គឺជាទិសខាងភូមិភាគបូព៌ាបាទ។

**ស៖** សូមអរគុណ។ ដោយយើងមិនចាំបាច់មើលខ្លឹមសារនៃសារទូរលេខនេះឲ្យបានលម្អិតនោះទេ យើងគ្រាន់តែមើលការកម្ចាត់ជនជាតិមូស្លីមនៅភូមិភាគបូព៌ា ការបំបែកជនជាតិមូស្លីមនៅភូមិភាគ

បូព៌ា។ តើវាត្រឹមត្រូវដែរឬទេ ប្រាប់យើងខ្ញុំផង ប្រសិនបើលោកមិនដឹងថាឯកសារនេះនោះ តើត្រឹមត្រូវដែរឬ ដែលឯកសារនេះគឺផ្ញើចេញមកពីភូមិភាគបូព៌ា?

[១១:៤៤:១៣]

**ឆ៖** ឯកសារនេះ គឺត្រឹមត្រូវហើយ ដែលគេរាយការណ៍ជូន បងប៉ុល ហ្នឹងគឺពិតជាមកពីភូមិភាគបូព៌ាមែន។ ឯរឿងខ្លឹមសារវិញ គឺមិនមែនមូស្លីមទេ ខ្លឹមសារគេដាក់ថា អ៊ីស្លាមបាទ។

**ស៖** សូមអរគុណ។ តើខ្លឹមសារបែបនេះជាទូទៅផ្ញើមកពីលេខានៃភូមិភាគ ឬក៏ផ្ញើចេញមកពីបុគ្គលណាដែរ?

**ឆ៖** ខ្ញុំមិនដឹងទេ មិនដឹងជាលោកណាអ្នកធ្វើសារនេះ ប៉ុន្តែជាធម្មតាអ្នកណាជាប្រធានភូមិភាគណា គឺលោកហ្នឹងហើយ ដែលជាអ្នកមានសិទ្ធិរាយការណ៍មក បងប៉ុល នោះ។

**ស៖** តើលោកចាំដែរឬទេ នរណាគេជាលេខាភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៥?

**ឆ៖** បាទ តាមខ្ញុំដឹង គឺលោក សោ ភឹម បាទ ជាលេខាភូមិភាគបូព៌ានៅពេលនោះ។

[១១:៤៥:៥៥]

**ស៖** សូមអរគុណ។ នៅពេលដែលយើងដាក់ថា ឃើញនូវពាក្យថា "ចម្លងជូន" នៅខាងក្រោមយើងឃើញមានចម្លងជូន បងនួន, បងវឿន, បងយ៉ែម និងទុកឯកសារ។ ខ្ញុំជាបឋមនេះសូមសួរលោកថា នៅក្នុងចម្លងជូននេះគឺមិនមានដាក់ចម្លងជូនមន្ទីរនោះទេ។ ដូច្នេះតាមការឆ្លងកាត់បទពិសោធន៍របស់លោក តើវាចម្លែកដែរឬទេ ដែលអត់ចម្លងជូនមន្ទីរណាមួយជាក់លាក់នោះ?

**ឆ៖** បាទជាចម្លែកដែរ ព្រោះខ្ញុំមិនដែលឃើញគេដាក់បងវឿន, បងយ៉ែម អ៊ីចឹងដែរ។ ជាទូទៅខ្ញុំធ្លាប់តែ អ៊ំៗប៉ុន្មាននាក់ហ្នឹងទេ ដែលបានស្គាល់ច្បាស់ ឯបងវឿន, បងយ៉ែម -- ហើយក៏ចម្លែកដែរត្រង់ថាមិនមានមន្ទីរមួយ ហើយនិងទុកឯកសារនោះគឺមានជាធម្មតាបាទ។ រឿងដាក់ចម្លងជូននេះគឺពិតជាចម្លែកមែនបាទ។

[១១:៤៧:៣២]

**ស៖** នៅពេលដែលយើងមើល ពាក្យថា "បងនួន" នៅក្នុងចម្លើយដំបូងរបស់លោកត្រង់លេខ ERN ជាភាសាខ្មែរ 00328040, បារាំងគឺ 00411707, អង់គ្លេស 00334057។ លោកបាននិយាយដូចតទៅ៖ "ទូរលេខនេះ ដំបូងបញ្ជូនទៅតែ ប៉ុល ពត ម្នាក់គត់ ប៉ុន្តែដោយសារអ្នកគ្រប់គ្រងសារទូរលេខគាត់ដឹងថា បញ្ហានេះគឺត្រូវបញ្ជូនទៅអ្នកទទួលខុសត្រូវ ខាងប្រជាជនដើម្បីដោះស្រាយ ដូចជា

នួន ជា ជាដើមនេះ”។ តើចំណុចនេះខ្ញុំអានត្រឹមត្រូវតាមអ្វីដែលលោកបានរៀបរាប់ទៅតាមខ្លឹមសារនៅក្នុងសារទូរលេខនេះដែរឬទេ?

[១១:៤៨:៣៩]

**ផះ** បាទ ពិតជាត្រឹមត្រូវ ហើយក៏ពិតជាស្របនឹងដូចដែលខ្ញុំបានឆ្លើយមែន។

**សះ** សូមអរគុណ។ នៅពេលដែលយើងមើលពាក្យ “បងឡឿន” វិញម្តង។ នៅក្នុងអត្ថបទអម្បាញ់មិញដែលខ្ញុំអានចេញពីចម្លើយដំបូងរបស់លោក គេបានសួរលោក “ថាតើនរណាគេជា បងឡឿន និងបងយ៉ែម?” លោកបានឆ្លើយដូចតទៅ “ខ្ញុំមិនដឹងច្បាស់បុគ្គលពីរនាក់នេះទេ។ យ៉ែម អាចជាសមាជិកសភា ហើយ ឡឿន អាចជាប្រធានមន្ទីរធ្វើការងារជាមួយនឹង នួន ជា ឬក៏ ខៀវ សំផន ឬក៏គាត់អាចជា សមាជិកសភាទទួលភារៈខាងភូមិភាគឧត្តរ”។ តើចំណុចនេះត្រឹមត្រូវតាមការរៀបរាប់របស់លោកលើការងារពាក់ព័ន្ធទៅនឹង ឡឿន ដែរឬទេ?

**ផះ** បាទ ពិតអ៊ីចឹងមែន ព្រោះខ្ញុំមិនដែលស្គាល់ថា ឡឿន ហ្នឹងជាអ្នកណា បើថា បងនួន នេះគឺខ្ញុំដឹងថា នួន ជា ច្បាស់ហើយ។ ឯ បងឡឿន ហ្នឹងគឺមិនដឹងឈ្មោះពិត ឡឿន ហ្នឹងដើមកំណើតរបស់ឡឿនហ្នឹងជានរណា ហើយ យ៉ែម ក៏មិនដឹងជានរណា បាទ។

**សះ** សូមអរគុណ។ ក្នុងពេលដែលយើងនិយាយអំពី ឡឿន ខ្ញុំសូមពិនិត្យមើលឯកសារមួយទៀតដែលវាក្រោយរយៈពេលមុននេះបន្តិច ហើយសូមឲ្យលោកជួយពន្យល់យើងខ្ញុំអំពីតួនាទីរបស់បុគ្គលនេះ។

[១១:៥០:៥២]

**លោក អាប់ឌុលឡាក់ ថារីកះ**

លោកប្រធាន ឯកសារនេះមានលេខ E3/1103 វាជាសារទូរលេខមួយទៀត ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ សូមអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារនេះមួយច្បាប់ជូនសាក្សី។

**ប្រធានអង្គជំនុំះ**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ! ហើយនិងអនុញ្ញាតឲ្យបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផងដែរ។

[១១:៥១:៣៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

ខ្ញុំគិតថា យើងបានរៀបចំរួចហើយ ដូច្នេះខាងបច្ចេកទេសសោតទស្សន៍អាចបញ្ចាំងលើអេក្រង់ទូរទស្សន៍ កញ្ចក់ទូរទស្សន៍ផង។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងនឹងធ្វើការស្វែងយល់អំពីតួនាទីរបស់បុគ្គលអម្បាញ់មិញនេះ លោក សុផង់ ហើយខ្ញុំពិភាក្សាឯកសារសារទូរលេខនេះឲ្យបានលម្អិតជាងមុនបន្តិច។ យើងឃើញថា ឯកសារនេះចាប់ផ្តើមដោយសរសេរថា "ទូរលេខពីរ ជូនសមមិត្ត ឌឿន ជាទីគោរព និងរព្ទក។ ចំណុចទី១ យើងខ្ញុំបានទទួលទូរលេខ១៥ របស់សមមិត្តហើយស្តីអំពីសម្ភារៈផ្សេងៗ"។ នៅក្នុងចំណុចទី២ បានសរសេរថា សរសេរអំពីការស្នើសុំពីតំបន់នោះ គឺសុំដូង ១០.០០០ផ្លែ ហើយបន្ទាប់មកនៅក្នុងចំណុចទី៣ បានសរសេររៀបរាប់ដូចតទៅ៖ "យើងសូមជម្រាបថា សូមជម្រាបសមមិត្តខាងតំបន់ថា យើងក៏ចង់បញ្ជូនយុវជនខាងវិទ្យុមួយនាក់ចុះទៅរៀនខាងអក្សរសម្ងាត់ ខាងវិទ្យុទាក់ទងចង់ឲ្យចេះពេលសមមិត្តយើងចុះទៅរៀនសាលាបក្សលើកក្រោយ។ ហើយយើងក៏បានសួរអំពីឡានត្រូវមានលេខ អំពីសបុត្រធ្វើដំណើរ ១០៥ ហើយយើងក៏ចង់ដឹងថា តើអង្គការនេះចង់ឲ្យយើងចេញលិខិតនេះដែរឬទេ?

[១១:៥៣:៤៤]

សារទូរលេខនេះ គឺមានសរសេរឈ្មោះ ឆាន ហើយហាក់ដូចជាបង្ហាញថា ឯកសារសារទូរលេខនេះចេញមកពីតំបន់១០៥"។ ដូច្នេះ តើលោកអាចបញ្ជាក់ទេចំណុចនៃឯកសារសារទូរលេខនេះ?

**ឆ៖** បាទ ១០៥ គឺជាតំបន់ស្វយ័តមួយដែលជាតំបន់នៅភូមិភាគឦសានបាទ។ ហើយខ្ញុំក៏មិនស្គាល់ដែរ ឈ្មោះ ឆាន ដែលចុះហត្ថលេខាហ្នឹងជានរណា? បើ សារុន ធ្លាប់ឃើញមានសារ ប៉ុន្តែដល់ឆាន ហ្នឹងគឺខ្ញុំមិនដែលស្គាល់បាទ។

**ស៖** សូមអរគុណ។ នៅពេលនេះយើងត្រឡប់ពិនិត្យមើលចំណុចទី១ ទី២ ខាងលើ គឺមានការលើកឡើងអំពីសម្ភារៈផ្សេងៗ ហើយក្នុងនោះក៏បានស្នើសុំតំបន់សូមដូងផងដែរ។ តើលោកបាននឹកឃើញទេ នៅពេលដែលមើលចំណុចនេះ ហើយលោកអាចនឹកឃើញថា ឌឿន មានការងារទទួលខុសត្រូវអ្វីដែរ?

**ឆ៖** ប្រហែលជា ឌឿន ហ្នឹងគឺជាអ្នកទទួលចាត់ចែងខាងសម្ភារៈមួយដែរ នេះ យោងទៅលើ

ខ្លឹមសារនេះ។ តែការរៀបចំរបស់អចិន្ត្រៃយ៍ឲ្យឈ្មោះ ខឿន ហ្នឹងទទួលការងារអី ខ្ញុំមិនដឹង ហើយខ្ញុំក៏មិនធ្លាប់បានជួប ខឿន ហ្នឹងដែរបាទ។

**ស៖** នៅក្នុងចំណុចទី៣ ដែលក្នុងនោះបានរៀបរាប់អំពីសមមិត្តយុវជន ដែលបញ្ជូនទៅរៀនខាងវិទ្យុ ដែលទៅរៀនខាងអក្សរសម្ងាត់ ដូច្នេះ ខ្ញុំចង់សួរ ថាតើមានការអប់រំបណ្តុះបណ្តាលណាមួយនៅក្នុងឆ្នាំ១៩៧៦ ដែលធ្វើការអប់រំបណ្តុះបណ្តាលទៅដល់សមមិត្តយុវជនខាងវិទ្យុដែរឬទេ?

[១១:៥៦:៤]

**ឆ៖** នេះខ្ញុំ សារនេះនិយាយថា វិទ្យុទាក់ទង ប៉ុន្តែខ្លឹមសារទៀត ថាចុះទៅរៀនអក្សរសម្ងាត់។ មិនដឹងជាលោកបញ្ជូនទៅវិទ្យុមួយ អក្សរសម្ងាត់មួយ ឬយ៉ាងណា។ អានេះខ្ញុំមិនច្បាស់ទេ លើខ្លឹមសារនេះ។ មិនដឹងជាបញ្ជូនពីរនាក់ ឬមួយក៏ម្នាក់។ ពីព្រោះវិទ្យុទាក់ទងជាផ្នែកមួយ ឯខាងអក្សរសម្ងាត់ជាផ្នែកមួយទៀត។ នេះខ្ញុំស្វែរយល់បាទខ្លឹមសារនេះ។

**ស៖** តើលោកនឹកឃើញដែរឬទេ ថាតើ ខឿន មានតួនាទីភារៈខាងរៀបចំការបណ្តុះបណ្តាលអប់រំសម្រាប់សមមិត្តយុវជនមកពីតំបន់១០៥ ដែរឬទេ?

**ឆ៖** បាទ ខឿន មិនមានភារកិច្ចទៅអប់រំខាងវិទ្យុ ឬមួយខាងអក្សរសម្ងាត់ទេ។ បើគេចង់ទៅរៀនខាងវិទ្យុ គឺត្រូវទៅរៀននៅ ក -- ទាក់ទងនឹងខាង ក-១៨ បាទ គេជាអ្នកឯកទេសជំនាញខាងផ្នែកហ្នឹង។ ឯបើចង់រៀនខាងអក្សរសម្ងាត់ វាទាក់ទងនឹងឯកទេសជំនាញរបស់ខ្ញុំផ្ទាល់បាទ។

**ស៖** សូមអរគុណ។ ឯកសារសារទូរលេខនេះបានចម្លងជូនបងនួន, មន្ទីរ និងឯកសារ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ហេតុអ្វីបានជាមិនបានចម្លងជូន ប៉ុល ពត?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ អ្នកចម្លងជូននេះ -- អ្នកដែលសម្រេចថាចម្លងជូនហ្នឹងមិនដឹងគេត្រូវចាត់ចែងយ៉ាងណា ប៉ុន្តែតាមដែលខ្ញុំដឹងគឺថា ដែលជាការគោលការណ៍ណែនាំគឺថា បើអ្វីដែលសារទូរលេខណាដែលទាក់ទងនឹងផ្នែកណា គឺត្រូវជូនទៅផ្នែកនោះជាអ្នកដោះស្រាយ។ ដូចជារឿងខ្លឹមសារទាំងអស់នេះគឺទាក់ទងនឹងការបង្កបង្កើនផល រឿងពូជ រឿងធារ រឿងសម្ភារៈ គឺវាទាក់ទងនឹងមន្ទីរបាទ។ អ៊ីចឹងប្រហែលជាមន្ទីរហ្នឹងគឺ ក្នុងហ្នឹងគឺអចិន្ត្រៃយ៍បានចាត់ចែងសមមិត្ត ខឿន ហ្នឹងជាអ្នកទទួលខុសត្រូវមួយដែរ បានគេជូនបង ខឿន ហ្នឹង។ ហើយក្នុងនេះ គឺថាគេចម្លងជូនមន្ទីរហ្នឹង ដល់ថា បងខឿន ក៏មានសិទ្ធិទទួលបាននូវខ្លឹមសារទូរលេខនេះ នៅក្នុងមន្ទីរហ្នឹងដែរ។

[១២:០០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី តំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ។

អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ដល់សាក្សីរូបនេះនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

បាទ សូមអញ្ជើញលោកមេធាវី!

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទទួលការជូនដំណឹងពីលោក នួន ជា ថាគាត់ឈឺក្បាល ឈឺខ្នង និងពុំអាចផ្ចង់អារម្មណ៍បាន។ ដូច្នេះហើយសូមស្នើសុំតាមដានសវនាការនៅបន្ទប់ខាងក្រោម។ ដូច្នេះយើងខ្ញុំនឹងដាក់ជូនលិខិតបោះបង់សិទ្ធិតាមក្រោយ។ សូមអរគុណលោកប្រធាន។

[១២:០១:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ ដោយមូលហេតុបញ្ហាសុខភាព។ ហើយមេធាវីការពារក្តីសន្យាថា ខ្លួននឹងដាក់នូវពាក្យសុំលះបង់សិទ្ធិរបស់លោក នួន ជា មកអង្គជំនុំជម្រះភ្លាម។ អង្គជំនុំជម្រះសម្រេច យល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០២:៣៥]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និងខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម។ ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀល។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តនីតិវិធីសវនាការ ហើយនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយអង្គជំនុំជម្រះសូមរំឭកសាក្សីផងដែរថា សូមសាក្សីផ្តល់នូវចម្លើយណាដែលខ្លួនបានដឹង បានឮ បានចងចាំជាក់ច្បាស់។ យ៉ាងហោចណាស់ក៏បទពិសោធន៍ផ្ទាល់ ឬក៏បានសង្កេតដែរ។ ចៀសវាងនូវចម្លើយដែលស្មានៗ ឬក៏ចម្លើយដែលប្រហែលណ៎ា។ ចម្លើយប្រហែល ឬក៏ស្មាននេះ ហើយតាមការយល់ឃើញរបស់លោកនេះ គឺមិនមានតម្លៃជាភស្តុតាងទេ។ សូមលោកមានការចាប់អារម្មណ៍លើចំណុចនេះឲ្យច្បាស់។

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** សូមជម្រាបសួរលោក នង សុផង់។ នៅពេលដែលយើងបានពិនិត្យទៅលើឯកសារចុងក្រោយដែលផ្ញើជូន បងនួន -- បង ឌឿន គឺថាឯកសារនេះនិយាយអំពីការបែងចែកសម្ភារៈដែលពាក់ព័ន្ធទៅនឹងមន្ទីរ។ ដោយសារហេតុនេះហើយ ទើបគេផ្ញើលិខិតហ្នឹងជូនទៅបង ឌឿន។ ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយទៀត ដែលនិយាយអំពីសមមិត្ត ឌឿន ហើយយើងនឹងពិនិត្យមើល ថាតើឯកសារនេះអាចជួយលោក ដើម្បីឲ្យលោកអាចថាមានលទ្ធភាពក្នុងការនឹកឃើញនូវតួនាទីរបស់លោក ឌឿន។ ឯកសារនេះគឺលេខ D200/9.7។ គឺជាឯកសារដែលភ្ជាប់ជាមួយនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សីទី២។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៣:៣៧:០៥]

**លោក អាកទូរ វែកកែន៖**

សូមអរគុណលោកប្រធាន ដែលបានឲ្យខ្ញុំចបញ្ចេញយោបល់។ ខ្ញុំភ្ញាក់ផ្អើលចំពោះវិធីសាស្ត្ររបស់សហព្រះរាជអាជ្ញា។ យើងមានសាក្សីដែលបានឆ្លើយរួចមកហើយថា គាត់មិនដឹងអំពីតួនាទីរបស់ ឌឿន ទេ។ ហើយសហព្រះរាជអាជ្ញាធ្វើហាក់ដូចជាមិនដឹងមិនឮអំពីចម្លើយរបស់សាក្សី ដូចជាសាក្សីមិនបានពន្យល់ថា គាត់មិនដឹងអំពីតួនាទីពិតប្រាកដរបស់ ឌឿន ទេ។ ហើយគាត់ចេះតែបន្តបង្ហាញឯកសារជូនសាក្សី ដើម្បីនាំឲ្យសាក្សីធ្វើការប៉ាន់ស្មានទៅលើសម្ដី ទៅលើតួនាទីរបស់ ឌឿន។ ដូច្នេះនៅពេលដែលយើង -- ដូច្នេះសូមឲ្យសាក -- លោកប្រធាន -- អម្បាញ់មិញនេះលោកប្រធានបានបញ្ជាក់ច្បាស់ហើយថា សូមឲ្យនិយាយពីអ្វីដែលសាក្សីបានដឹង ហើយនិងបាននឹកឃើញនៅថ្ងៃនេះ។ ហើយឥឡូវនេះ ខ្ញុំឃើញសហព្រះរាជអាជ្ញា គាត់បន្តធ្វើហួសហេតុ គឺគាត់មិនដឹង -- គាត់ធ្វើជាមិនដឹងមិនឮចំពោះចម្លើយរបស់សាក្សី ដែលគាត់ឆ្លើយថា គាត់មិនដឹងអំពីតួនាទីរបស់ ឌឿន ហើយគាត់នៅតែបន្តផ្ដល់ជូននូវសារទូរលេខ ដើម្បីសាក្សីនេះ គាត់ធ្វើការប៉ាន់ស្មានទៅលើតួនាទីរបស់ ឌឿន នៅវិញ។

[១៣:៣៨:១៨]

យើងមានវិធីសាស្ត្រផ្សេងទៀត ដើម្បីសួរឲ្យដឹងអំពីតួនាទីរបស់ ឌឿន។ ហើយគាត់ -- សាក្សីនៅទីនេះ គាត់មិនដឹងទេ គាត់ឆ្លើយច្បាស់ហើយ។ ហើយគាត់ៗធ្វើបែប នៅតែបន្តធ្វើបែបនេះ គាត់ជា

ការនាំមុខ ហើយធ្វើឲ្យសាក្សីឆ្លើយស្មានៗ។ សូមឲ្យសហព្រះរាជអាជ្ញារៀបចំសំណួរឲ្យបានស្រួល។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតប។ អ្វីដែលលើកឡើងគឺជាការមិនត្រឹមត្រូវ ដែលថាសាក្សីគាត់មិនបានដឹងអំពីតួនាទីរបស់សមមិត្ត ខឿន។ ខ្ញុំសូមជម្រាបដល់តុលាការថា នៅក្នុងរបាយការណ៍ស្តាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត លោកសាក្សីបានពណ៌នាថា ខឿន គឺជាបុគ្គលមួយដែលអាចមានតួនាទីជាប្រធានមន្ទីរ ឬប្រធានការិយាល័យដែលធ្វើការជាមួយនឹងលោក នួន ជា ឬក៏ ខៀវ សំផន។ ដូច្នេះ អានេះគឺជាអ្វីដែលជាការទទួលបានពីចំណេះដឹងរបស់គាត់ ហើយគាត់បានបញ្ជាក់បន្ថែមទៀតថា គាត់ដឹងថា ខឿន មានតួនាទីទាក់ទងទៅនឹងការបែងចែកសម្ភារៈ។ ហេតុដូច្នេះហើយទើបឯកសារដែលយើងបានពិនិត្យមើលពីខាងមុនកន្លងមក គឺត្រូវបានគេបញ្ជូនទៅ ខឿន។ ហេតុដូច្នេះផ្អែកទៅតាមចំណេះដឹងរបស់គាត់ គឺថាបុគ្គលនេះ គាត់មានតួនាទីមួយ។ ហេតុដូច្នេះតាមការស្នើរបស់ខ្ញុំគឺជាការចាំបាច់ដែលយើងត្រូវតែធ្វើការពិនិត្យពិភាក្សាបន្តទៅទៀត ដើម្បីឲ្យដឹងថា តើសាក្សីនោះគាត់ដឹង គាត់ដឹងដល់កម្រិតណា? ដូច្នេះហើយទើបយើងត្រូវបង្ហាញឯកសារ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមជម្រាបសាក្សី សាក្សីមិនត្រូវធ្វើការប៉ាន់ស្មាន ឬក៏ទាយស្មាននោះឡើយ។ ក្នុងករណីដែល សាក្សីមិនមានការយល់ដឹង ឬក៏មិនបានដឹង ឬក៏សាក្សីគាត់ចង់និយាយថា គាត់មិនអាចទាយស្មាននោះទេ នៅពេលនុ៎ងគឺៗ យើងអាចធ្វើដូច្នេះបាន ប៉ុន្តែមិនគួរមានការរារាំងទៅលើការសួរ -- ការដេញដោល សួររបស់ខ្ញុំបែបនេះឡើយ។

[១៣:៤០:៣៤]

**លោក អាកឡូវ វ៉ែកកែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។ ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី នៅពេលដែលសួរដោយសហចៅក្រមស៊ើបអង្កេតនោះ គាត់បានឆ្លើយទៅនឹងសំណើរួចមកហើយ។ មានន័យថានៅពេលដែលយើងអានចម្លើយបែបនេះ គឺសាក្សីគាត់ឆ្លើយថា ប្រហែលជាអ៊ីចឹងៗ។ ដូច្នេះនេះជាការប៉ាន់ស្មានរបស់សាក្សី ហើយឥឡូវនេះសហព្រះរាជអាជ្ញា គាត់ព្យាយាមធ្វើយ៉ាងណាដើម្បីឲ្យបង្វែរការឆ្លើយរបៀបស្មាននេះ ឲ្យក្លាយទៅជាចម្លើយពិតប្រាកដ។

ដូច្នេះនៅក្នុងឆ្នាំ២០០៩ នោះ ចម្លើយហ្នឹងគឺជាចម្លើយរបៀបស្មានមួយហើយ ហើយឥឡូវ -- ហើយគាត់ឆ្លើយបញ្ជាក់ថា គាត់អត់ដឹង។ ហើយឥឡូវនេះលោកសហព្រះរាជអាជ្ញា--

**ប្រធានអង្គជំនុំ៖**

ទៅខ្ញុំបានហើយលោកមេធាវី លោក -- គោលការណ៍យើងឲ្យជំទាស់តែម្តងទេ លោកជំទាស់ពីរដង យើងចង់សាកលមើលដែរ។ តើលោកគោរពវិធានដែលយើងកំណត់ដែរឬអត់? ឃើញថាលោកមិនគោរពនូវវិធានដែលយើងកំណត់ទេ។ យើងកំណត់ភាគីដែលជំទាស់ហ្នឹង ជំទាស់បានតែម្តងទេ។

សូមអញ្ជើញលោក ម៉ែខល កាណាវាស! ហើយចៀសវាងនិយាយបញ្ហាដដែល។ បញ្ហាថ្មីលោកអាចនិយាយបាន ព្រោះបញ្ហាដដែលនេះ ការជំទាស់ហើយ ចប់ហើយ ព្រោះព្រះរាជអាជ្ញាបានតបទៅនឹងសេចក្តីជំទាស់រួចហើយ។

[១៣:៤១:៥៨]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមនិយាយដោយសង្ខេប។

ខាងព្រះរាជអាជ្ញាបានចាប់ផ្តើមចោទសួរ ដោយព្យាយាមផ្តល់យោបល់ចំពោះសាក្សីនូវឯកសារមួយចំនួន ដើម្បីឲ្យសាក្សីអាចដឹង ថាតើ ខឿន ហ្នឹងមានតួនាទីជាអ្វី។ ហើយព្រះរាជអាជ្ញាបានបញ្ជាក់ទៅលើអ្វីដែលសាក្សីបាននិយាយរួចទៅហើយ ប៉ុន្តែនៅក្នុងចម្លើយទី២ គឺសាក្សីបាននិយាយថា នៅពេលដែលគេសួរគាត់អំពី ខឿន គាត់និយាយថា “គាត់មិនដឹងទេ ប្រហែលជាគាត់ធ្វើការនៅក្នុងក្រុមការងារនៃមន្ទីរ៨៧០”។ នេះគឺជាអ្វីដែលគាត់ដឹង តាមដែលគាត់អាចនឹកឃើញនៅពេលដែលគាត់ផ្តល់ចម្លើយទៅដល់សហចៅក្រមស៊ើបអង្កេត។ ហើយឥឡូវនេះព្រះរាជអាជ្ញាព្យាយាមបង្កើតនូវការយល់ដឹង ឬក៏បន្ថែមនូវការយល់ដឹងដោយបង្ហាញនូវឯកសារ នេះគឺជាការមួយដែលមិនត្រឹមត្រូវ ដូចដែលសហការីខ្ញុំបានលើកឡើងរួចទៅហើយ។

ដូច្នេះនេះគឺជាអ្វីដែលខ្ញុំចង់លើកឡើង។

[១៣:៤២:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនណាស់។ ប្រហែលជាអង្គជំនុំជម្រះក៏បានចាប់អារម្មណ៍បញ្ហានេះមុនពេលអាហារថ្ងៃត្រង់ដែរ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះមកដល់ភ្លាម រំឭកដល់សាក្សីភ្លាមអំពីបញ្ហានេះដោយសង្កេតឃើញថា សាក្សីបានឆ្លើយស្ទាន១ តបទៅនឹងសំណួរដោយភាគី កាលពេលហ្នឹងអត់មានជំទាស់អ្វីឡើយ។ អ៊ីចឹងហើយបានអង្គជំនុំជម្រះពិភាក្សាលើបញ្ហានេះ ហើយរំឭកសាក្សីភ្លាម មុនពេល

ផ្តល់វេទិកាឲ្យទៅសហព្រះរាជអាជ្ញាតាំងសំណួរ។

ហើយបើសហព្រះរាជអាជ្ញាតាំងសំណួរ ជាសិទ្ធិរបស់សហព្រះរាជអាជ្ញាអាចសួរបាន ប៉ុន្តែ សាក្សីសូមបញ្ជាក់ថា លោកមិនអាចឆ្លើយស្មានបានទេ។ អ្វីដែលលោកដឹង លោកឃើញ លោកឮ លោក ទទួលបទពិសោធន៍ផ្ទាល់ ឬក៏ការសង្កេតយ៉ាងជាក់ច្បាស់ សូមលោកឆ្លើយតប។ បើពុំដូច្នោះទេ លោក ឆ្លើយថាមិនដឹងជាការចប់ អ្វីក៏ដោយ។ បើពុំដូច្នោះទេ លោកបន្តិចទៀត លោកនឹងទទួលរងនូវសំណួរ រាប់រយសំណួរពីភាគី មេធាវីការពារក្តីដែលនឹងសួរផ្ចញ់លោក។

[១៣:៤៤:១៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានខ្ញុំគិតថា លោក -- ការជំទាស់របស់លោក ម៉ែខល កាណាវាស គឺពាក់ព័ន្ធទៅនឹង បញ្ហានេះមួយផ្នែក--

**ប្រធានអង្គជំនុំ៖**

យើងសម្រេចរួចហើយ លោកអាចសួរបាន។ សាក្សីទេដែលត្រូវឆ្លើយ ឬមិនឆ្លើយ បើសិនជា គាត់មិនដឹងនោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំយល់ច្រឡំទៅលើការសម្រេចនេះ។ ឯកសារដែលខ្ញុំចង់បង្ហាញ សាក្សី គឺឯកសារដែលគាត់បានពិភាក្សាជាមួយនឹងអ្នកស៊ើបអង្កេត គឺឯកសារដែលមានលេខ D200/9.7។ នេះគឺជាកំណត់ហេតុនៃការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ៧៥។

ខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីផ្តល់នូវឯកសារជាក្រដាសជូនទៅដល់សាក្សី។ សូមលោក ប្រធានមេត្តាអនុញ្ញាត។

[១៣:៤៥:១៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ប្រសិនបើលោកពិនិត្យមើលទៅលើទំព័រទី២ គឺខ្ញុំនឹងផ្តល់នូវលេខ ERN តាមក្រោយ ជាភាសាខ្មែរមានលេខ 00019109, ភាសាបារាំងគឺ 00292869, ភាសាអង់គ្លេស 00183393។ ប្រសិនបើលោកមើលទៅលើទំព័រនេះ ខ្ញុំចង់សួរលោកអំពីបន្ទាត់មួយ គឺបន្ទាត់ដែលមានលេខ៨ គឺបង្ហាញពីសមមិត្ត ឌឿន ប្រធានមន្ទីរនយោបាយរបស់៨៧០។ ផ្អែកតាមការយល់ដឹងរបស់លោកនៅពេលនោះ ដោយមិនធ្វើការប៉ាន់ស្មាន មិនទាយស្មានទេ តើលោកអាចប្រាប់បានដែរឬទេ ថាតើតួនាទីបែបនេះ គឺវាស្របទៅតាមការយល់ដឹង ការចាំរបស់លោក ទាក់ទងទៅនឹងតួនាទីរបស់សមមិត្ត ឌឿន?

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំបានជម្រាបលោកតាំងពីក្រុមស៊ើបអង្កេត របស់លោកទៅធ្វើសម្ភាសខ្ញុំមកម្ល៉េះ ថា សមមិត្ត ឌឿន ខ្ញុំមិនដឹង ខ្ញុំមិនស្គាល់ថា សមមិត្ត ឌឿន ជានរណាទេ ហើយការចាត់តាំងរបស់គណៈអចិន្ត្រៃយ៍ឱ្យសមមិត្ត ឌឿន ទទួលភារកិច្ចជាអ្វី ខ្ញុំក៏មិនបានដឹង។

[១៣:៤៧:២២]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយ មិននិយាយពី ឌឿន ទៀតទេ ខ្ញុំសូមសួរសំណួរលោក ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក ខៀវ សំផន។ មុនពេលដែលយើងត្រឡប់មកពិនិត្យមើលទៅលើឧទាហរណ៍ នៃទូរលេខវិញ។ ខ្ញុំសូមអាននូវឃ្លាមួយនេះ ដើម្បីកុំឱ្យខាតពេលវេលា ហើយខ្ញុំនឹងចោទសួរសំណួរលោក ទាក់ទងទៅនឹងឃ្លាមួយនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺជាឯកសារ នៃការស្តាប់ចម្លើយសាក្សីទី១ ដែលមានលេខ E3 គឺ E3/64 ហើយដែលមានលេខ ERN គឺមានលេខ ភាសាខ្មែរ 00328033, ភាសាបារាំងគឺមានលេខ 00411701 ដល់ 702 និងភាសាអង់គ្លេស គឺមានលេខ 00334052។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ នេះគឺជាឃ្លាដែលខ្ញុំចង់អានឱ្យលោកស្តាប់ "សំណួរ៖ ចុះ ខៀវ សំផន វិញ? ចុះចំណែក ខៀវ សំផន? ឆ្លើយ៖ គឺធ្លាប់មានសាររបស់គាត់និយាយអំពីជូនអំបិល អង្ករ ក្រណាត់ ខោអាវ ស្បែកជើង និងសម្ភារៈផ្សេងៗទៅអង្គភាពនេះប៉ុណ្ណេះ ទៅអង្គភាពនោះប៉ុណ្ណោះសម្រាប់ចែកចាយ

ប្រជាជន។ គាត់ជាអ្នកចាត់ចែងសម្ភារៈផ្សេងៗ ដែលផលិតបានជូនទៅប្រជាជន។ ខ្ញុំទទួលសាររបស់ ខៀវ សំផន មិនជាញឹកញាប់ទេ។ ក្រៅពីនេះ ខ្ញុំធ្លាប់បកប្រែសាររបស់ ខៀវ សំផន ដែលមាន លក្ខណៈជាសារាចរណែនាំខ្លះៗដែរ។ ឧទាហរណ៍អំពីបុណ្យជាតិផ្សេងៗ"។ ថាតើអ្វីដែលខ្ញុំបានអានហ្នឹង គឺជាការសង្ខេបអំពីតួនាទីរបស់លោក ខៀវ សំផន ដែលលោកបាននិយាយ តើខ្ញុំសង្ខេបបែប នេះត្រឹមត្រូវដែរឬទេ?

[១៣:៥០:៣៣]

**ធៈ** បាទ ពិតជាត្រឹមត្រូវបាទ។

**សៈ** ខ្ញុំនឹងអាននូវឃ្លាមួយបន្ថែមទៀត គឺចុះក្រោមបន្តិចនៅក្នុងផ្នែកដដែលនេះ ដែលលោកនិយាយដូចតទៅនេះ៖ "ចំពោះ ខៀវ សំផន គាត់ផ្ញើសារជាសរសេរដៃទៅមន្ទីរក-១ ហើយអ្នកដែលផ្ញើនោះ គឺឈ្មោះ សែម ហើយ សែម ផ្ញើសារហ្នឹងទៅក-១ (អ្នកបកប្រែសូមកែតម្រូវ) គឺឈ្មោះ សំ ពេល ខ្លះជូនកាល ខៀវ សំផន ទូរស័ព្ទមកកន្លែងខ្ញុំ ឲ្យខ្ញុំកត់ត្រាខ្លឹមសារតាមទូរស័ព្ទ ហើយប្រាប់ឲ្យខ្ញុំបញ្ជូនសារទៅកន្លែងណាៗ។ រួចហើយកខ្លឹមសារមកបកប្រែសារជាលេខកូដ ហើយបញ្ជូនចេញទៅ។ តើអ្វីដែលខ្ញុំបានសង្ខេបហ្នឹង គឺជាអ្វីដែលលោកបានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេត តើត្រឹមត្រូវដែរឬទេ?

[១៣:៥១:៥៧]

**ធៈ** បាទ អ៊ីចឹងមែន គឺថាខ្ញុំធ្លាប់បានទទួលសាររបស់លោក ខៀវ សំផន តាមរយៈក្រុម សំ ដែលនីរសារបញ្ជូនមកអ៊ីចឹងមែន ហើយពេលខ្លះក៏គាត់ទូរស័ព្ទមកផ្ទាល់ដល់កន្លែងខ្ញុំ អ៊ីចឹងមែន។

**សៈ** នៅពេល ខៀវ សំផន បញ្ជូននីរសារ ដែលប្រើប្រាស់នីរសាររបស់ ក-១ តើលោកដឹងដែរឬទេ ថាតើគាត់បញ្ជូននីរសារនោះមកពីទីតាំង មកទីកន្លែងណាមួយ?

**ធៈ** បាទ ខ្ញុំមិនដឹង។

**សៈ** នៅក្នុងចម្លើយដដែលនេះ គឺចុះក្រោមបន្តិច គឺនៅភាសាខ្មែរដែលមានលេខ 00328035, ភាសាបារាំងគឺមានលេខ 00411703 និងភាសាអង់គ្លេស គឺមានលេខ 00334053។ គេសួរលោកដូចតទៅនេះ៖

[១៣:៥៣:៤៣]

"តើលោកធ្លាប់ទទួលទូរស័ព្ទសុំជួបផ្ទាល់ពីគណៈភូមិភាគដែរឬទេ? ឆ្លើយ៖ ទេ ទូរស័ព្ទរបស់ខ្ញុំ

ទាក់ទងបានតែបីកន្លែងទេ ដូចជា កន្លែង ខៀវ សំផន, យស់ និងកន្លែង ក-១"។ តើខ្ញុំសង្ខេបបែបនេះ គឺជាការសង្ខេបត្រឹមត្រូវអំពីចម្លើយរបស់លោក ដែលថា លោកនិយាយថា ទូរស័ព្ទរបស់លោកទាក់ទងបានតែបីកន្លែងទេ គឺកន្លែង ខៀវ សំផន, យស់ និងកន្លែងក-១ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវបាទ។

**ស៖** លោកដឹងដែរឬទេ ហេតុអ្វីបានចាំបាច់តម្រូវឲ្យមានទូរស័ព្ទរបស់ការិយា -- មន្ទីររបស់លោកជាមួយនឹងមន្ទីររបស់ ខៀវ សំផន ហេតុអ្វីតម្រូវឲ្យមានខ្សែទូរស័ព្ទទំនាក់ទំនងបែបនេះ?

**ឆ៖** បាទ ព្រោះសារទូរលេខធម្មតា គឺវាតែងតែ -- បើផ្ញើដៃមក ជួនណាក៏ ក្រែងលោអក្សរគាត់ហ្នឹង ខ្ញុំមើលទៅវាមិនច្បាស់ ឬក៏ក្នុងករណីដែលគាត់ចង់បញ្ជាថា សារមួយនេះ ត្រូវធ្វើទម្រង់ដូចគ្នាៗហ្នឹង តើទៅប៉ុន្មានទិសអីៗ គាត់នឹង -- ឬក្រុមការងាររបស់គាត់អាចនឹងបញ្ជាក់ខ្ញុំតាមទូរស័ព្ទបាន។ នេះជា ដើម្បីសម្រួលការងារឲ្យស្រួលបាទ ឲ្យបានច្បាស់លាស់បាទ។

**ស៖** នៅពេលដែលលោក ខៀវ សំផន បញ្ជូនសារមកមន្ទីររបស់លោកដើម្បីបញ្ជូនចេញ តើសារហ្នឹង ត្រូវបានបំភ័ន្តអក្ខរៈហើយឬនៅ មុនពេលដែលបញ្ជូនចេញនោះ?

**ឆ៖** បាទ សារហ្នឹង គឺជាសារ ខ្លឹមសារ ដូចជាលិខិតយើងធម្មតាទេ បាទ ហើយគេវាយអង្កុលីលេខស្រាប់ហើយបាទ។ ឯយើងខ្ញុំមានតួនាទីបំភ័ន្តអក្ខរៈទៅតាមខ្លឹមសារដែលគេបញ្ជូនមក។

[១៣:៥៦:៥៧]

**ស៖** ខ្ញុំសូមសួរលោក ថាតើលោកបកស្រាយ -- បកប្រែទូរសារដែលគេផ្ញើបញ្ជូនលោក ខៀវ សំផន ដែរឬទេ? គឺទូរលេខដែលបានផ្ញើមកពីខេត្ត ឬក៏មកពីតំបន់ផ្សេង តើលោកមានបានធ្វើការងារនេះទេ?

**ឆ៖** បាទ រឿងចាត់ចែងថា ជូនអ្នកណាៗហ្នឹង ដូចខ្ញុំបានជម្រាបពីមុនច្រើនមកហើយថា ខ្ញុំធ្វើតាមតែបញ្ជារបស់លោក ប៉ុន ដែលជាអ្នកទទួលខុសត្រូវពីលើខ្ញុំ។ ឯរឿងដាក់ជូនអ្នកណាៗ គឺទៅតាមតែការបញ្ជារបស់លោក ប៉ុន តែប៉ុណ្ណោះ។

**ស៖** តើមានសារណាខ្លះ ដែលធ្លាប់ផ្ញើជូនលោក ខៀវ សំផន ដែរឬទេ? គឺបានន័យថា នៅលើបន្ទាត់ខាងលើដែលសរសេរថា "សារហ្នឹង ផ្ញើជូនគាត់" គឺក្រៅពីការបញ្ជាពី ប៉ុន ដែលថាត្រូវចម្លងជូនទៅគាត់ហ្នឹង តើមានសារណាដែលផ្ញើមកគាត់ផ្ទាល់ទេ?

**ឆ៖** ខ្ញុំមិនបានដឹង ហើយខ្ញុំមិនដែលបានឃើញបាទ ដែល ប៉ុន បញ្ជាមកខ្ញុំថា ឲ្យជូនសារនោះ

ទៅលោក ខៀវ សំផន ទេបាទ។

**ស៖** វគ្គពាក់ព័ន្ធជាមួយនឹងលោក ខៀវ សំផន បញ្ហានេះផងដែរ គឺយើងពិភាក្សាបន្តទៅមុខទៀត គឺលោកនិយាយអំពីតួនាទីរបស់គាត់ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយសាក្សីទី២ របស់លោក។

[១៣:៥៩:១៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺឯកសារដែលមានលេខ E3/67។ ភាសាខ្មែរ មានលេខ 00294538, បារាំង គឺមានលេខ 00374935 និងភាសាអង់គ្លេស គឺមានលេខ 00483966។ ហើយនេះ គឺជាអ្វីដែលបានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនោះ។

សូមដកស្រង់ "ចំពោះ ខៀវ សំផន គាត់ទទួលខុសត្រូវ -- ទទួលបន្ទុកខាងរណសិរ្ស និងរដ្ឋាភិបាល គឺការងារទំនាក់ទំនងជាមួយសម្ដេច សីហនុ ត្រូវជួបជាមួយភ្ញៀវបរទេសតាមផ្លូវរដ្ឋ បែងចែកសម្ភារៈផ្សេងៗទៅមូលដ្ឋាននានា និងភូមិភាគនានា។ ចំពោះសារទូរលេខគេមិនចម្លងជូនខៀវ សំផន។ តាមការយល់របស់ខ្ញុំ ជួនកាលអាច ប៉ុល ពត លោកកោះហៅគាត់ទៅជួបផ្ទាល់"។ ខ្ញុំសូមបន្តទៅមុខទៀត តាមអ្វីដែលអង្គជំនុំជម្រះបានបង្គាប់បញ្ជា ខ្ញុំមិនចង់ឲ្យលោកធ្វើការទាយស្មានទៅលើបញ្ហានេះទេ។ ប៉ុន្តែជាដំបូងខ្ញុំសូមសួរសិន ថាតើអ្វីដែលខ្ញុំសង្ខេបនេះ គឺជាចម្លើយពិតដែលលោកបានផ្ដល់ជូនសហចៅក្រមស៊ើបអង្កេតមែនឬទេ?

**ឆ៖** បាទ ចំពោះចម្លើយខាងដើម គឺជាចម្លើយដែលខ្ញុំបានដឹង បានឃើញដោយផ្ទាល់ខ្លួនឯង ហើយនិងធ្លាប់បានទទួលការងារដែលលោក ខៀវ សំផន ដែលមានការទាក់ទងមកកន្លែងខ្ញុំ។ នេះដូចជាបញ្ហាលោកទទួលការងាររណសិរ្ស ការងាររាជរដ្ឋាភិបាល និងការចែកចាយសម្ភារៈ។ ឯតួនាទីដែលខ្ញុំ ដែលខ្ញុំថា ៗប្រហែលស្មានអីហ្នឹង គឺខ្ញុំ -- គឺសុទ្ធតែខ្ញុំមិនច្បាស់ហើយ ហើយអស់លោកខាងស៊ើបអង្កេតចេះតែដេញដោលសួរ ដើម្បីឲ្យចេញអាតួនាទីរបស់គាត់ហ្នឹង។ ខ្ញុំថាមិនច្បាស់ហើយ លោកចេះតែខំរកវិធីសាស្ត្រយ៉ាងណា ចុចសួរខ្ញុំបាទ។ អ៊ីចឹងអាលើដំបូងខ្ញុំច្បាស់លាស់របស់ខ្ញុំ។

[១៤:០២:០៥]

**ស៖** សូមអរគុណ។ ដោយសារតែលោកបាននិយាយថា លោកដឹងដោយផ្ទាល់ -- លោកមិនបានដឹងដោយផ្ទាល់លើបញ្ហានេះ ដូច្នេះខ្ញុំពុំសួរសំណួរបន្ថែមទៀតនោះទេ។ ដូចដែលយើងបានពិភាក្សាលើកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ៧៥ ប៉ុន្មាននាទីមុននេះ។ ខ្ញុំសូមឲ្យលោក

មើលចំណុចខ្លីមួយ ដែលលោកបានលើកឡើងឆ្លើយជូនអ្នកស៊ើបអង្កេត ហើយឲ្យលោកបញ្ជាក់ តើលោកយល់យ៉ាងណា? ហើយលោកដឹងយ៉ាងម៉េចដែរ? ឯកសារ D200/9.7 ខ្មែរERN គឺ00019111, បារាំងលេខ 00292872, និងអង់គ្លេស 00183394។ ចំណុចនៅក្នុងអត្ថបទនេះ លើកឡើងអំពីបញ្ហារដ្ឋបាល មានចំណុចមួយនោះបានលើកឡើងដូចតទៅ "នៅពេលដែលសារទូរលេខចូលមក នៅពេលដែលយើងទទួលបានភ្លាមៗ អង្គភាពត្រូវបញ្ជូនទៅផ្នែកដែលទទួលភារៈជាបន្ទាន់ ដើម្បីឲ្យគេពិចារណា និងធ្វើសំណើទៅប្រគល់ -- ហើយស្នើអចិន្ត្រៃយ៍ បញ្ហាខ្លះត្រូវប្រញាប់។ បញ្ហាយោធា ឲ្យខាងយោធា, បញ្ហាពាណិជ្ជកម្ម ឲ្យពាណិជ្ជកម្ម, បញ្ហាបក្សឲ្យផ្នែកបក្ស។ ដូច្នេះ បើទៅជិតគ្នា យើងស្រួលប្រមូលកម្លាំងធ្វើការ"។

នៅពេលដែលលោកពិនិត្យមើលឯកសារនេះ លោក នង សុផង់ នៅក្នុងចម្លើយលោកឆ្លើយលើកទី២ លោកបានបញ្ជាក់អំពីការណែនាំមួយ ដែលលោកបានទទួលពី ប៉ុន។ តើត្រឹមត្រូវដែរឬទេ អ្វីដែលខ្ញុំអានអម្បាញ់មិញនេះ គឺផ្ទុះបញ្ចាំងអំពីតួនាទីមុខងារ កន្លែងដែលលោកធ្វើការនោះ តើអ៊ីចឹងដែរឬទេ?

[១៤:០៥:០០]

**ឆ៖** បាទ ខ្លឹមសារនេះ គឺមានពាក់ព័ន្ធទៅនឹងរបៀបរបប ដែលការិយាល័យយើងខ្ញុំត្រូវធ្វើការងារឲ្យបានទៅតាមមតិរបស់អចិន្ត្រៃយ៍លើកឡើងនេះ។ គឺអ៊ីចឹងមែន គឺថាគេត្រូវធ្វើការងារឆ្លើយឆ្លងគ្នាឲ្យបានរហ័ស។ ជាក់ស្តែងគឺថា ដូចខ្ញុំបានប្រាប់ជូនលោកហើយ គឺថាខ្ញុំទទួលបកប្រែហើយពេលណា អីពេលណា គឺខ្ញុំត្រូវបញ្ជូនទៅយ៉ាងរួសរាន់ មិនត្រូវបង្អែបង្អង់ឲ្យសារហ្នឹងកប់នៅកន្លែងខ្ញុំនោះទេ។ គឺត្រូវជូនទៅលោក ប៉ុន ភ្លាមដើម្បីគាត់ចាត់ចែងទៅតាមផ្នែកៗដែលអស់លោកទទួលខុសត្រូវ។ ខាងយោធា ឲ្យខាងយោធា, ខាងពាណិជ្ជកម្ម ឲ្យខាងពាណិជ្ជកម្ម។ បាទ អ៊ីចឹងមែនបាទ។

**ស៖** នៅពេលដែលយើងនិយាយអំពីបញ្ហាយោធានេះ តើវាពិតជាករណីនេះដែរឬទេ ដែលថាការទំនាក់ទំនងជាមួយនឹងយោធា ជាមួយនឹងមជ្ឈិមបក្ស គឺគេក៏ប្រើមន្ទីរ ក-១៨ និងមន្ទីរបំភ័ន្តអក្ខរៈនៃទូរលេខទាំងអស់នោះផងដែរ ឬក៏គេប្រើមធ្យោបាយនៅពេលដែលធ្វើទំនាក់ទំនងយោធាទៅកាន់មជ្ឈិមបក្សនោះ?

**ឆ៖** ខ្ញុំបានដឹង គឺថាការទំនាក់ទំនងផ្នែកខាងយោធា ដែលខ្ញុំបានឃើញគឺគេផ្ញើមកតាមរយៈ ក-១៨។ ហើយបានចូលមកខាងអង្គភាពបកប្រែសារទូរលេខ។ ឯមធ្យោបាយដែលគេទាក់ទងក្រៅពីនេះ ខ្ញុំមិនដឹងបាទ។

[១៤:០៧:៤៤]

**ស៖** សូមអរគុណ។ នៅពេលនេះ យើងទៅពិនិត្យមមើលឧទាហរណ៍នៃសារទូរលេខមួយចំនួន យើងពិនិត្យមើលដោយខ្លីៗតែប៉ុណ្ណោះ។ ហើយខ្ញុំសួរសំណួរលោកពីរ ឬក៏បីសំណួរលើបញ្ហាសារទូរលេខនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រមជាទីគោរព! ឯកសារនេះ មានលេខ E3/871 គឺជាសារទូរលេខមួយផ្សេងចុះថ្ងៃទី២១ ខែមីនា ទំនងជាឆ្នាំ៧៦ ក៏ប៉ុន្តែយើងនឹងសួរបញ្ជាក់ឆ្នាំណាឲ្យបានជាក់លាក់។ ដូច្នេះ សូមអនុញ្ញាតជូនឯកសារនេះទៅកាន់សាក្សី។ លោកប្រធាន។

[១៤:០៨:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំសូមអនុញ្ញាតឲ្យបញ្ចាំងលើកញ្ចក់ទូរទស្សន៍ផងដែរ សម្រាប់ភាគី និងសាធារណជនទាំងអស់។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់។ នេះ គឺជាសារទូរលេខមួយទៀត។ ខ្ញុំដឹងថា ឯកសារនេះវាមានគុណភាពមិនច្បាស់ទេមើលទៅ។ ក៏ប៉ុន្តែសូមឲ្យលោកមើលចំណុចលម្អិតមួយចំនួនដែលសរសេរនៅក្នុងនោះ។ កាលបរិច្ឆេទនៅខាងក្រោម គឺថ្ងៃ២១ ខែមីនា នៅខាងក្រោមនោះ យើងឃើញ ឆន ជាអ្នកសរសេរ ហើយនៅក្រោមនោះ យើងឃើញមាន "ចម្លងជូនបងនួន, បងខៀវ, បងវ៉ែន -- បងវ៉ាន់ មន្ទីរទុកឯកសារ" នៅពេលដែលយើងមើលឃើញបុគ្គលដែលនៅក្នុងមានឈ្មោះចម្លងជូននេះ គឺយើងឃើញមានតែមួយនោះ ប្លែកជាងគេគឺ បងខៀវ តើ បងខៀវ នេះជានរណាដែរ?

[១៤:១០:១០]

**ឆ៖** បាទ បងខៀវ នេះគឺជាឯកឧត្តម សុន សេន មិនមែនលោក ខៀវ សំផន នេះទេបាទ។

**ស៖** ខ្ញុំយល់ សូមអរគុណ។ ខ្ញុំសូមពិនិត្យមើលទៀតថាតើ យើងអាចបញ្ជាក់ចំណុចដែល

ឯកសារនេះបានបង្ហាញដែរឬទេ? គឺនៅខាងដើមនៃសារទូរលេខនេះបានសរសេរថា “គោរពជូនសមមិត្ត បងប៉ុល ជាទីស្នេហារពូក” ហើយនៅខាងក្រោមនោះ គឺសរសេរថា “តាមសេចក្តីរាយការណ៍របស់សមមិត្ត ឈូក តំបន់២៤ ស្តីពីសភាពការណ៍នៅព្រំដែនដូចតទៅ”។ បន្ទាប់មក គេបង្ហាញអំពីព្រឹត្តិការណ៍កើតឡើងនៅថ្ងៃទី១៣ មីនា ឆ្នាំ១៩៧៦។ តើព័ត៌មាននៅក្នុងនេះអាចឲ្យលោកនោះដឹងថាតើសារទូរលេខនេះ គឺគេបញ្ជូននិងរៀបចំពីកន្លែងណាបញ្ជូនមកដែរ?

**ឆ៖** បាទ ចំណងជើងក្បាលសារដាក់ថា “សមមិត្ត បងប៉ុល ជាទីស្នេហារពូក” គឺសំដៅលោក ប៉ុល ពត បាទ បងប៉ុល គឺ ប៉ុល ពត ហ្នឹងហើយ។ ឯសេចក្តីរាយការណ៍របស់សមមិត្ត ឈូក ខ្ញុំក៏មិនស្គាល់ សមមិត្ត ឈូក ដែរ ប៉ុន្តែតំបន់២៤ គឺស្ថិតនៅក្រោមឱវាទរបស់ភូមិភាគបូព៌ាបាទ។ អ៊ីចឹង គឺសារទូរលេខ នេះផ្ញើជូន ប៉ុល ពត ហើយអ្នកដែលធ្វើសារទូរលេខខាងក្រោមដាក់ឈ្មោះ “ផុន” ហ្នឹង គឺបានន័យថា ខាងបូព៌ាដូចឯកសារមុនដែរ ដែលស៊ីញេ ផុនៗ ហ្នឹងបាទ។ គឺទិសរបស់ភូមិភាគបូព៌ា បាទ ខ្លឹមសារនេះ។

[១៤:១២:២៤]

**ស៖** សូមអរគុណ។ នៅពេលដែលយើងមើលចំណុចដែលចាប់ផ្តើមដោយលេខ២ ខ្ញុំសូមអាន។ “ចំពោះការព្រឹត្តិការណ៍គប់គ្រាប់បែក ចំពោះសភាពការណ៍បោកគ្រាប់បែក” ហើយខាងក្រោមហ្នឹង បន្តិចហ្នឹង គឺយើងឃើញថា “នៅពេលនេះយើងចាប់បុគ្គលដែលបោកគ្រាប់បែករួចហើយ គឺជាភ្នាក់ងារគិញ ហើយយើងបានវាយពួកវា សួរអំពីខ្សែចាត់តាំងរបស់វា ហើយបានចំនួនម្តៃប្លាយនាក់ នៅតាមមូលដ្ឋានក្នុងស្រុក ព្រះស្តេច។ ពួកអានេះខ្សែចាត់តាំងមកពីវៀតណាមខាងត្បូង”។ តើលោកចាំដែរឬទេថា លោកបានធ្វើការបកប្រែសារទូរលេខជាក់លាក់មួយនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានបកប្រែសារនេះទេ ហើយក៏មិនមែនជាទិសដែលខ្ញុំទទួលខុសត្រូវនៅក្នុងសម័យហ្នឹងដែរ។ ភូមិភាគបូព៌ា គឺទាក់ទងនឹងសភាពការណ៍នៅតាមព្រំដែនវៀតណាម គឺកន្លែង ប៉ុន គេបកប្រែដោយផ្ទាល់បាទ។ ខ្ញុំមិនមានសិទ្ធិកាន់ទិសនេះទេ។

[១៤:១៤:០៨]

**ស៖** សូមអរគុណ។ តើលោកនឹកឃើញចាំដែរឬទេ តាមរយៈសារទូរលេខដែលលោកបានធ្វើការបកប្រែនោះ? តើលោកនឹកឃើញដែរឬទេ? មានករណីស្រដៀងគ្នាណាមួយដែលគេបានអនុវត្តការធ្វើទារុណកម្មនៅក្នុងតំបន់ ហើយបន្ទាប់មកគេយកព័ត៌មានទាំងអស់នោះដើម្បីបញ្ជូនឡើងទៅមជ្ឈិម តើ

មានដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបលោកខាងដើមហើយ គឺថា ការដែលគេរាយការណ៍ពីរឿងផ្ទៃក្នុង រឿងក្បត់ រឿងអ្វីនោះ មកតាមមុខព្រួញដែលខ្ញុំទទួលនោះ គឺថាវាតិចតួចណាស់ ស្ទើរតែគ្មានម្ដង។ អ៊ីចឹងខ្ញុំសូមមិនអធិប្បាយអីវែងឆ្ងាយនៅលើខ្លឹមសារនេះទេ ពីព្រោះខ្ញុំមិនច្បាស់បាទ មិនៗធ្លាប់បាន ធ្វើដោយផ្ទាល់ដៃខ្លួនឯងទេបាទ។

**ស៖** សូមអរគុណ។ នៅពេលយើងពិនិត្យមើលទម្រង់នៃសារទូរលេខនេះ។ ខ្ញុំដឹងថាលោកមិនបានបកប្រែសារទូរលេខមួយជាក់លាក់ដែលយើងកំពុងតែពិនិត្យមើលនេះនោះទេ ក៏ប៉ុន្តែតើបែបបទទម្រង់របស់វានេះស្របគ្នា ដូចគ្នាទៅនឹងទម្រង់សារទូរលេខផ្សេងទៀត ដែលបានបញ្ជូនទៅមកនាពេលនោះដែរឬទេ? គឺខ្ញុំគ្រាន់តែចង់បញ្ជាក់ទម្រង់វាតែប៉ុណ្ណោះ។ តើវាស្រដៀងដូចគ្នាដែរឬទេ ចំពោះសារ -- ទៅនឹងសារទូរលេខផ្សេងនោះ?

[១៤:១៥:៥៩]

**ឆ៖** បាទ រឿងទម្រង់នៃការរាយការណ៍ហ្នឹង គឺរឿងក្បាលនិងកន្ទុយវាដូចតែគ្នា។ ក៏ប៉ុន្តែចំពោះខ្លឹមសារ វាមិនមានទម្រង់ដូចគ្នាទាំងស្រុងនោះទេ។ របាយការណ៍របស់គេ រាយការណ៍មក អ្វីដែលជាក់ស្ដែង គេដាក់ ខ-១, ខ-២, ខ-៣ អ៊ីចឹង។ គេរាយការណ៍ជាក់ស្ដែងៗតែម្ដង មិនមានគម្រោង ឬទម្រង់ណាដែលតម្រូវថាឲ្យរាយការណ៍ហ្នឹងឲ្យដូចៗគ្នានោះទេបាទ។ អ៊ីចឹងខ្លឹមសាររាយការណ៍គឺវាអាស្រ័យនឹងការជាក់ស្ដែងនៅតាមមូលដ្ឋានរបស់គេបាទ។ គេអាចនិយាយបញ្ហាអីមុន ជួនកាលបញ្ហានយោបាយមុន បញ្ហាយោធាមុន ឬអ្វីមុន គឺអាស្រ័យទៅលើអ្នកសរសេរសារទូរលេខហ្នឹងទេ។

**ស៖** សូមអរគុណ។ នៅពេលនេះយើងចូលពិនិត្យមើលសារទូរលេខមួយទៀត គឺឯកសារលេខ E3/874 វាជាសារទូរលេខមួយទៀត ចុះថ្ងៃទី១៨ កក្កដា ឆ្នាំ១៩៧៦។

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំសូមអនុញ្ញាតពីលោកប្រធានផ្ដល់ឯកសារក្រដាសជូនសាក្សីមួយសន្លឹក។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៤:១៧:៥៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ នៅពេលដែលយើងពិនិត្យមើលសារទូរលេខមួយនេះវិញម្តង គឺវាចាប់ផ្តើមដោយកំណត់លេខទូរលេខ លេខ៥០ ហើយបានផ្ញើជូន "គោរពជូនបងជាទីស្នេហា និងវព្វក។ នៅក្នុងជួរទី១ គេបង្ហាញអំពីសភាពការណ៍ថ្ងៃ ១១.៧ ម៉ោងដប់បួន ទ័ពតំបន់ការពារប្រាសាទព្រះវិហារយកកាំភ្លើងអាកាប្រាំបីដើម និងបេ-៤០ ចំនួនពីរដើមរត់ចូលថៃ"។ វាជាឯកសារមួយវែង មានច្រើនទំព័រ ហើយខ្ញុំមិនអានគ្រប់ចំណុចនោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់សួរលោក ថាតើលោកស្គាល់ទេ សារទូរលេខនេះបញ្ជូនមកពីណាដែរ? ហើយបន្ទាប់មក យើងនឹងទៅពិនិត្យមើលទំព័រចុងក្រោយដែលខ្មែរលេខ ERN គឺ 00003704, បារាំងមានលេខ 00623913, អង់គ្លេស ERN មានលេខ 00003706។ ចំណុចចុងក្រោយនោះ គេសរសេរថា "ស្រុករវៀង មានភ្លៀងបង្គួរហើយ" បន្ទាប់មកគេសរសេរបញ្ចប់ "ការវកិច្ចបដិវត្តន៍សែនកក់ក្តៅបំផុត ថ្ងៃទី១៨ កក្កដា ៧៦។ ឈ្មោះ ហង្ស"។ តើលោកអាចបញ្ជាក់ទេ តើ ហង្ស នេះជានរណាដែរ? លោកអាចបញ្ជាក់បានទេ?

[១៤:២០:០៣]

**ឆ៖** បាទ ហង្ស ហ្នឹងគឺជាគណៈតំបន់ ដែលធ្វើការ -- លោក ហង្ស ហ្នឹងហើយដែលជាអ្នកបញ្ជូនមកខ្ញុំកន្លែងអប់រំខ្ញុំដំបូង តាំងពីសម្ភាសលើកទី១ ហ្នឹង ខ្ញុំប្រាប់ថា លោក ហង្ស ហ្នឹងខ្ញុំមិនស្គាល់ឈ្មោះពិតរបស់លោក ហង្ស ហ្នឹងជានរណាទេ បាទ។

**ស៖** ខ្ញុំគ្រាន់តែចង់សួរ ថាតើ ហង្ស នេះគឺជាបុគ្គលតែមួយដែលលោកបានបញ្ជាក់ប្រាប់យើងខ្ញុំដែរឬទេ? ដើម្បីកត់ត្រាជាប្រតិចារឹក ឯកសារសារទូលេខនេះបញ្ជូន ចម្លងជូន បងនួន, បងខៀវ បងវ៉ាន់, មន្ទីរ ឯកសារ។ យើងខ្ញុំសូមពិនិត្យមើលឯកសារសារទូរលេខមួយទៀតលោក សុផង់ ឯកសារ E3 លេខ E3/1023។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំក៏មានឯកសារនេះជាក្រដាសមួយសន្លឹកដែរ ដើម្បីផ្តល់ជូនទៅកាន់សាក្សី។ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ជូនឯកសារក្រដាសនេះទៅកាន់សាក្សី គឺឯកសារលេខ E3/1023។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:២១:៥០]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅពេលដែលយើងពិនិត្យមើលឯកសារសារទូរលេខនេះ លោក សុផង់ គឺមានដាក់ថាទូរលេខ១១, ២៧១ ខ្ទង់ ឯកសារដែលបានរៀបរាប់អំពីហេតុការណ៍កើតខែកញ្ញា ឆ្នាំ៧៦ ចុះហត្ថលេខាដោយ ឆុន គឺបុគ្គលដូចទៅនឹងបុគ្គលនៅក្នុងសារទូរលេខមុន។ នៅក្បាលទំព័រសរសេរថា "គោរពផ្ញើជូនមន្ទីរ៨៧០ ជាទីស្នេហា និងរឭក"។ តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ តើម-៨៧០ នេះគឺជាអ្វីដែរ? ហើយតើម-៨៧០ ហ្នឹងគឺជាគណៈ ៨៧០ ដូចដែលយើងបានពិភាក្សាគ្នាខាងដើមនោះដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ពាក្យ "ម" នេះ គឺដូចលោកបានអានដោយខ្លួនលោកផ្ទាល់ហើយ ថាមន្ទីរហ្នឹងគឺត្រឹមត្រូវហើយ តំណាងឲ្យមន្ទីរហ្នឹង។ មន្ទីរ ៨៧០ ក៏ដូចជា ៨៧០ ដែរគឺសំដៅទៅលើគណៈមជ្ឈិមដូចតែគ្នាទេបាទ ឬមួយក៏អង្គការ៨៧០ ហ្នឹង ក៏គេប្រើ ច្រើនប្រើដែរ។ គណៈ៨៧០ អង្គការ៨៧០ ឬមួយក៏ជូន៨៧០ ទទេ គឺក៏មានន័យថា មជ្ឈិមហើយ មជ្ឈិម កន្លែងមជ្ឈិមហើយបាទ។

[១៤:២៣:៥៥]

**ស៖** ដូច្នេះខ្ញុំយល់ថា អ្វីដែលម-៨៧០ នេះ ឬក៏នៅពេលដែលគេហៅថា អង្គការ៨៧០ ដូចអ្វីដែលលោកលើកឡើង គឺសំដៅទៅលើមជ្ឈិមនេះឯង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំយល់ដូច្នេះមែនបាទ។

**ស៖** ខ្ញុំសូមឲ្យលោកពិនិត្យមើលខ្លឹមសារ នៅក្នុងសារទូរលេខនេះវិញម្តង សូមឲ្យលោកមើលដោយសង្ខេប។ ហើយតើលោកអាចជួយពន្យល់យើងខ្ញុំបានដែរឬទេ? ប្រសិនបើលោកមិនអាចទេ សូមជម្រាបយើងខ្ញុំថាមិនអាច។ ក្នុងនេះសរសេរថា "យើងខ្ញុំសូមរាយការណ៍ពីសភាពការណ៍នៅព្រំដែនតំបន់២៣ មានដូចតទៅ៖ នៅថ្ងៃទី០៤ កញ្ញា ឆ្នាំ១៩៧៦ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ខ្មាំង

បានទម្លាក់វិទ្យុថតសំឡេងមួយគ្រឿង មកលើភូមិសំរោងថ្មី ឃុំទួលស្ដី ស្រុកចន្ទ្រា។ ពេលធ្លាក់មកដល់ដី នៅឮសូរឆេត១ ជាប់ឥតដាច់ តែពេលនោះកុមារឃ្វៀលគោក្របីឃើញក៏រត់ទៅរើសយកផ្តាច់ខ្សែភ្លើង និងលួសខ្មៅរបូតចេញខ្លះ រហូតដល់បាត់សូរសំឡេង។ ចំណុចនេះ គឺវាបង្ហាញអំពីហេតុការណ៍តូចមួយ តាមខ្លឹមសារពិនិត្យមើលច្បោល១ សំណួររបស់ខ្ញុំនោះគឺខ្ញុំចង់សួរថា តើវាជាការងារធម្មតាសាមញ្ញដែលត្រូវរាយការណ៍ រឿងតូច១ក៏ដោយ រួមទាំងម៉ាស៊ីនថតសំឡេងដែលវាធ្លាក់មកហើយដែលក្មេងនោះរើសបាន តើអ៊ីចឹងដែរឬទេ?

[១៤:២៦:០៨]

**ឆ៖** បាទ អ្វីក៏ដោយ ឲ្យតែមានសភាពការណ៍ចម្លែក ដែលទាក់ទងនឹងបញ្ហាសន្តិសុខ បញ្ហាសុវត្ថិភាព ទាក់ទងដល់សភាពការណ៍តាមព្រំដែន គឺសុទ្ធតែត្រូវធ្វើរបាយការណ៍ឡើងលើបាទ។

**ស៖** សូមអរគុណ។ ហើយយើងបន្តទៅមុខទៀត ពាក់ព័ន្ធទៅនឹងសារទូរលេខដែលវាជាសារទូរលេខ បង្ហាញពេលវេលាខិតទៅមុខ១ទៀត ហើយខ្ញុំក៏សូមបង្ហាញឯកសារដល់សាក្សី E3/882។ ឯកសារសារទូរលេខចុះថ្ងៃទី៤ ខែតុលា ឆ្នាំមួយពាន់ប្រាំបួន-- ខែសីហា ឆ្នាំ១៩៧៧។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារជាក្រដាសទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:២៧:៣៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ដូចដែលលោកស្គាល់ឯកសារនេះស្រាប់ហើយ។ ខ្ញុំសូមបញ្ជាក់នៅក្នុងប្រតិចារឹកថា ការបកប្រែជាភាសាអង់គ្លេស គឺមានតែមួយផ្នែកតែប៉ុណ្ណោះ ហើយបារាំងបកប្រែបានពេញលេញ។ អ្វីដែលខ្ញុំចង់សួរនៅពេលនេះគឺ ខ្ញុំនឹងអានការបកប្រែព្រាង ជាភាសាអង់គ្លេសចេញពីឯកសារដើម ហើយសូមឲ្យលោកបញ្ជាក់ ថាតើខ្លឹមសារអ្វីដែលខ្ញុំអានជូនលោកស្តាប់នេះ គឺវាត្រឹមត្រូវដែរឬទេ? ឯកសារនេះចាប់ផ្តើមដោយសរសេរថា "ថ្ងៃ៤ សីហា ឆ្នាំ១៩៧៧ ទូរលេខ ៦២, ១៤៧៤ខ្ទង់"

ចំណងជើងដាក់ថា "គោរពជូនម-៨១ ជាទីគោរពស្នេហា"។ តើលោកស្គាល់ពាក្យ ម-៨១ នេះដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំមិនធ្លាប់ដែលឃើញម-៨១ទេ បើសិនណាជាម-៨៧ ប្រហែលជាសំដៅម-៨៧០ ប៉ុន្តែខ្ញុំសន្និដ្ឋាន ថា ៨១ នេះគេមិនដែលមាននរណាប្រើទេ ហើយក៏មិនដែលមានលេខហ្នឹងទេ។ បើលេខ ៨៧ អានេះត្រូវជាង ពីព្រោះឃើញហាក់ដូចជាចំណុចលុបនៅកន្លែងលេខ១នេះ។ បើ ៨៧ គឺគេធ្លាប់ប្រើ លេខ ៨៧០ គេវាវែងពេក ដូច្នេះគេដាក់ត្រឹម៨៧ បាទ--

[១៤:២៩:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរបានហើយ ភាពចាំបាច់តបទៅនឹងសំណួរ បើលោកដឹងលោកថា ដឹង បើមិនដឹងទេ គឺមិនដឹងទៅចប់ហើយ។ បាទ ចៀសវាងនិយាយចាកឆ្ងាយចេញពីវិសាលភាពចាំបាច់ នៃការឆ្លើយតប ឬក៏ភាពគ្រប់គ្រាន់នៃការឆ្លើយតបទៅនឹងសំណួរ។

[១៤:៣០:១២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**លោក នង សុផង់៖**

**ឆ៖** បាទ សូម -- បញ្ហានេះ សូមឆ្លើយថាមិនដឹងបាទ ព្រោះមិនដែលឃើញបាទ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណ។ ដើម្បីកត់ត្រាជាប្រតិចារឹក ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះចម្លងជូនបងនួន- - អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវ៉ន, បងខៀវ មន្ទីរ ឯកសារ--

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំសូមឡើងប៉ុន្មាននាទី ឡើងបញ្ជាក់ប៉ុន្មាននាទី។ ខ្ញុំមិនឃើញថា ចាំបាច់ត្រូវលើក ចំណុចចូលទៅក្នុងប្រតិចារឹកនោះទេ។ ប្រសិនបើសាក្សីគាត់ថាមិនដឹងហើយយើងបន្តទៅមុខទៀត។ គោលបំណងហ្នឹងគឺយ៉ាងម៉េច នៅពេលដែលគាត់អានហ្នឹងដើម្បីផ្តល់ជាសញ្ញាបញ្ជាក់ ឬក៏ផ្តល់ជា ព័ត៌មានណាមួយទៅដល់សាក្សី ដើម្បីឲ្យសាក្សីដឹង។ មិនចាំបាច់អានបន្ថែមទេ ចូលប្រតិចារឹកធ្វើអី បើសិនជាវាមាននៅក្នុងសំណុំរឿងរួចទៅហើយនោះ។

[១៤:៣១:៣៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមគាំទ្រការជំទាស់របស់លោកមេធាវី ម៉ៃខល កាណាវាស ហើយក៏សូមជំទាស់ផងដែរ ចំពោះការបង្ហាញបន្ថែមរបស់តំណាងអយ្យការនេះ។ ពីព្រោះថាការបង្ហាញបន្ថែមនេះ វាមានន័យស្មើនឹងការធ្វើសេចក្ដីសន្និដ្ឋាន ហើយដែលសេចក្ដីសន្និដ្ឋាននោះមិនមែនធ្វើនៅពេលនេះទេ គឺសម្រាប់ពេលចុងក្រោយនៃការដេញដោលនេះ។ បាទ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ហេតុផលដែលខ្ញុំធ្វើបែបនេះ គឺព្រោះថា ឯកសារហ្នឹងមានទាំងបីភាសា យើងមិនអាចបង្ហាញឯកសារទាំងបីនៅលើអេក្រង់ក្នុងពេលជាមួយគ្នាបានទេ។ ខ្ញុំធ្វើបែបនេះ គឺដើម្បីបង្ហាញអំពីឯកសារ ហើយខ្ញុំមិនមានចេតនាបន្ថែមអ្វីនោះឡើង។ ខ្ញុំគ្រាន់តែអានពីក្នុងឯកសារតែប៉ុណ្ណោះ។ ខ្ញុំគិតថា ខ្ញុំមិនមានចេតនាមិនល្អណាមួយចំពោះការងារនេះឡើយ គឺខ្ញុំគ្រាន់តែជួយដល់អង្គជំនុំជម្រះដើម្បីឲ្យដឹងអំពីលក្ខណៈរបស់ឯកសារ ថាតើអ្នកណាដែលផ្ញើជូនទៅអ្នកណាខ្លះ ឬក៏មានឈ្មោះអ្នកណាខ្លះ?

[១៤:៣២:៤៦]

លោកប្រធាន ខ្ញុំរីករាយមិនអាន ប្រសិនបើមានការសម្រេចបែបនេះ ហើយម្យ៉ាងទៀតការមិនអាននោះ គឺវាធ្វើឲ្យខ្ញុំចំណេញពេលផងដែរ។

[១៤:៣៣:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៣:១១]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបន្តទៅមុខទៀត ពីព្រោះឯកសារនេះមាននៅក្នុងសំណុំរឿងរួចហើយ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** គឺមានការនិយាយយោងដោយខ្លីមួយនៅក្នុងចំណុចនេះ គឺនៅក្នុងកថាខណ្ឌ "ខ" គឺនៅទំព័រទី១ នៃឯកសារនេះ ដែលមានជាបីភាសាផងដែរ។ គឺវាបានបញ្ជាក់ថា "ក្នុងពេលថ្មីៗនេះមានព័ត៌មានដែលថា ទាហានកម្ពុជាបានធ្វើការសម្លាប់ជាទ្រង់ទ្រាយធំទៅលើប្រជាជនវៀតណាម ប្រជាជនស៊ីវិលវៀតណាមជាង ១.០០០នាក់ នៅក្នុងខេត្តហាទៀង និង ឃៀនជៀន"។ តើលោកចាំដែរឬទេ តាមបទពិសោធន៍របស់លោកផ្ទាល់ក្នុងការបកប្រែឯកសារទូរលេខនេះ តើលោកចាំមានការនិយាយពាក់ព័ន្ធទៅនឹងជម្លោះជាមួយនឹងវៀតណាមដែរឬទេ?

[១៤:៣៤:៣២]

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំមិនដឹង។ ខ្ញុំមិនដែលបានបកប្រែឯកសារនេះ ហើយក៏ឯកសារនេះ ក៏ខ្ញុំមិនធ្លាប់ឃើញដែលចៅក្រមស៊ើបអង្កេតបានប្រគល់ឲ្យខ្ញុំ។ ដូច្នេះ ខ្ញុំសូមរក្សាសិទ្ធិមិននិយាយបាទ។

**ស៖** សូមអរគុណ។ ហើយសំណួរចុងក្រោយទាក់ទងទៅនឹងឯកសារមួយនេះផងដែរ គឺថានៅចុងបំផុតនៃឯកសារនេះ គឺបុគ្គលម្នាក់ឈ្មោះ ឈាន។ តើលោកស្គាល់ថា ឈាន ហ្នឹងជាអ្នកណាដែរ តើលោកអាចប្រាប់បានទេ?

**ផ៖** បាទ ខ្ញុំមិនស្គាល់ទេបាទ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវនេះ យើងបន្តទៅនឹងឯកសារមួយប្រភេទទៀតដែលលោកបានពិភាក្សាជាមួយនឹងសហចៅក្រមស៊ើបអង្កេតរួចមកហើយ គឺឯកសារ D200/9.5។ ហើយឯកសារនេះ គឺជាសេចក្ដីណែនាំរបស់មន្ទីរ ៨៧០ ចុះថ្ងៃ៣ មករា ឆ្នាំ១៩៧៨។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមានឯកសារជាក្រដាសជូនលោកសាក្សី។ សូមលោកប្រធានអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៤:៣៦:៤៣]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមឲ្យលោកពិនិត្យមើលទៅលើចំណងជើងអត្ថបទ គឺជា "សេចក្តីណែនាំរបស់៨៧០ កម្មវត្ថុ៖ ទស្សនៈគោលជំហរ និងមាគ៌ាវាយខ្មាំងយួនឈ្លានពាន"។ ហើយឯកសារនេះ គឺមាននូវចំណងជើងតូចៗជាច្រើន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។ លោក សុផង់ លោកអាចពិនិត្យលើទៅឯកសារនេះ ហើយលោកឃើញថាមានចំណារសរសេរដៃមួយចំនួននៅលើឯកសារនេះ។ នៅក្នុងកិច្ចសម្ភាសន៍ទី២របស់លោក នៅពេលដែលលោកមើលទៅលើចំណារសរសេរដៃទាំងអស់នេះ លោកបាននិយាយដូចតទៅ គឺឯកសារ E3/67, ខ្មែរ ERN មានលេខ 00294544, ភាសាបារាំងគឺមានលេខ 00374939, ភាសាអង់គ្លេស គឺមានលេខ 00483962។ លោកនិយាយដូចតទៅនេះ៖ "ខ្ញុំស្គាល់អក្សរសរសេរនេះ គឺអក្សររបស់ ប៉ុល ពត។ ព្រោះ ប៉ុល ពត មានសិទ្ធិធ្វើការកែតម្រូវ ព្រោះគាត់មានសិទ្ធិកែ។ អក្សរសរសេរដៃពណ៌ក្រហមនេះ ជាអក្សររបស់លោក ប៉ុល ពត ផ្ទាល់ ពីព្រោះខ្ញុំចំណាំបានដោយសារខ្ញុំធ្លាប់ឃើញអក្សររបស់ ប៉ុល ដែល ប៉ុន យកមកឲ្យខ្ញុំបកប្រែ ឬនៅពេលដែលមានសារខ្លីៗគាត់សរសេរផ្ទាល់ដៃ ផ្ញើតាម ប៉ុន មកឲ្យខ្ញុំបកប្រែ"។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ ថាតើអ្វីដែលខ្ញុំអានហ្នឹង គឺជាចម្លើយដែលលោកផ្តល់ តើត្រឹមត្រូវដែរឬទេ?

[១៤:៣៨:៥១]

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** ដោយសារតែមានពេលវេលាកំណត់ ខ្ញុំមិនអានឯកសារនេះទាំងផ្ទាល់នោះទេ។ ប៉ុន្តែខ្ញុំចង់ឲ្យលោកមើលទៅលើផ្នែកមួយនៅចុងនៃឯកសារនេះ។ គឺឯកសារ D200/9.5 ភាសាខ្មែរមានលេខ 00381222, ភាសាបារាំង គឺមានលេខ 00754715 ហើយភាសាអង់គ្លេស គឺមានលេខ 00707388។ ឯកសារនេះបានបញ្ជាក់ដូចតទៅ៖ "សេចក្តីបញ្ជាក់ -- សេចក្តីណែនាំនេះត្រូវចែកចាយ និងសិក្សាក្នុងគណបក្សភាគ តំបន់ ស្រុក សហករណ៍ ក្នុងគណៈសមរភូមិ គណៈកងពល វរសេនាធំ វរសេនាតូច អនុសេនាធំ អនុសេនាតូច ក្រុម និងយុទ្ធជន គណៈបញ្ជាការមុខព្រួញនីមួយៗឲ្យៗជ្រួតជ្រាបសាចុះសាឡើង ដកពិសោធជាប់ និងកែលម្អការអនុវត្ត"។ ហើយនៅខាងក្រោមឯកសារនេះគឺចុះហត្ថលេខាដោយគណៈ៨៧០។ លោក សុផង់ តើលោកចាំដែរឬទេ ថាមានសេចក្តីណែនាំបែបនេះ? គឺសេចក្តីណែនាំដែលចេញដោយគណៈ៨៧០ ហើយបង្គាប់បញ្ជាដល់ភាគ, ភូមិភាគ, តំបន់, និងគណៈកម្មការទាំងអស់នៅទូទាំងប្រទេសឲ្យធ្វើតាម? តើលោកចាំថាមានឯកសារបែបនេះទេ?

**ឆ៖** បាទ ខ្ញុំបានចងចាំថាមានឯកសារបែបនេះមែន។ ប៉ុន្តែមិនមែនជាឯកសារដែលជាសំណេរកែកំណែអ៊ីចឹងទេ គឺជាអត្ថបទចុងក្រោយ ដែលគេបានកែលម្អរួចស្រេចហើយបាទ។

[១៤:៤១:៣០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណសាក្សី អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណៈបានជ្រាបថា នៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៤ ខែកញ្ញា ឆ្នាំ២០១២ នៅវេលារសៀលអង្គសវនាការ អ៎! អង្គជំនុំជម្រះនឹងមិនធ្វើសវនាការសួរដេញដោលសាក្សីទេ។ ដោយមូលហេតុអង្គហេតុអង្គជំនុំជម្រះមានកិច្ចការចាំបាច់ត្រូវប្រជុំ ពិភាក្សាដោះស្រាយបញ្ហាមួយចំនួន។

អាស្រ័យហេតុនេះសូមភាគី និងសាធារណជនជ្រាប។

បញ្ហាទី២ អង្គជំនុំជម្រះសួរទៅតំណាងសហព្រះរាជអាជ្ញា ថាតើការបែងចែកពេលវេលា ក្នុង

ការសួរដេញដោលសាក្សីរូបនេះ ជាមួយនឹងខាងក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ? ពីព្រោះការបែងចែកពេលវេលានេះ គឺក្រុមភាគីទាំងពីរ គឺមានពេលវេលាសេសសល់ល្ងាច ហើយនិងព្រឹកស្អែកមួយព្រឹកទៀតប៉ុណ្ណោះ។

[១៥:០៣:២៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ វាអាចជាបញ្ហាបកប្រែនៅត្រង់នេះ។ ខ្ញុំយល់ថា លោកប្រធានលើកឡើងថា ការ -- យើងខ្ញុំនឹងបញ្ចប់ការដេញដោលសាក្សីរូបនេះនៅព្រឹកថ្ងៃស្អែក។ ពេលវេលាដែលយើងទទួលតាមការកំណត់របស់អង្គជំនុំជម្រះ គឺពីរថ្ងៃ និងមួយភាគបួននៃថ្ងៃទៀត ប្រសិនបើខ្ញុំយល់មិនខុសនោះទេ។ ដូច្នេះបើសរុបទៅ គឺ១០ម៉ោង ១៥នាទី។ យើងខ្ញុំនឹងធ្វើការកត់ត្រាទុកនូវពេលវេលាដែលខ្ញុំសួរដេញដោល។ នៅពេលនេះគឺថាយើងបានចំណាយពេល៥ម៉ោងជាងរួចមកហើយ។ ចំពោះខាងយើងខ្ញុំ ខាងសហព្រះរាជអាជ្ញា គឺយើងត្រូវការតែ១ម៉ោងកន្លះទៀតតែប៉ុណ្ណោះ។ ដូច្នេះប្រហែលជានៅក្នុងថ្ងៃនេះ១ម៉ោង ហើយស្អែកព្រលឹមឡើងនោះ យើងត្រូវការកន្លះម៉ោងបន្ថែមទៀត។ ហើយយើងខ្ញុំសង្ឃឹមថាសហមេធាវីនាំមុខនោះ គឺគាត់ប្រហែលជាអាចត្រូវការពេលវេលាកន្លះម៉ោងទៅ១ម៉ោងទៅតាម -- ត្រូវការ -- ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ត្រូវការប្រហែល២ម៉ោងកន្លះ ទៅលើពេលវេលារបស់គាត់។ ដូច្នេះហើយគឺចំពោះយើងខ្ញុំៗនឹងបន្តទៅមុខទៀតទៅតាមពេលវេលាកំណត់នេះ ហើយយើងខ្ញុំនឹងមិនឲ្យហួសនៅព្រឹកស្អែកត្រឹមម៉ោងអាហារថ្ងៃត្រង់នោះទេ។ នេះជាពេលវេលាដែលយើងខ្ញុំបានបញ្ជាក់លោកប្រធាន។

[១៥:០៥:២៤]

**ប្រធានអង្គជំនុំ៖**

អរគុណសូមអញ្ជើញបន្តតាំងសំណួរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ខ្ញុំសូមអរគុណ ដែលលោកវិលត្រឡប់មកផ្ដល់សក្ខីកម្មឡើងវិញនៅពេលនេះ ហើយយើងខ្ញុំសូមអរគុណ ដែលលោកចំណាយពេលសម្រាប់យើងខ្ញុំប្រហែលជា -- ចំពោះថ្ងៃនេះ

ជិត១ម៉ោងទៀត។ ឯកសារដែលយើងមើលអម្បាញ់មិញនេះគឺ D200/9.5។ ខ្ញុំសូមបញ្ជាក់ថា តើខ្ញុំស្តាប់ឮត្រឹមត្រូវដែរឬទេ គឺថា លោកបានឆ្លើយថា លោកបានឃើញឯកសារនេះ ឯកសារចុងក្រោយមួយច្បាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានសរសេរចំណាររបស់បុគ្គលម្នាក់ផងដែរ តើអ៊ីចឹងដែរឬទេ?

**លោក នង សុផង់៖**

**ផ៖** បាទ ពិតជាត្រឹមត្រូវមែនបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងមើលចំណុចទី១ នៃសារទូរលេខនោះ នៃឯកសារនោះ ខ្ញុំនឹងសួរលោកទាក់ទងទៅនឹងឯកសារ ចំណុចលេខមួយរ៉ូម៉ាំង ពាក់ព័ន្ធទៅនឹងព័ត៌មានទូទៅអំពីខ្មាំង។ ខ្ញុំនឹងអានអត្ថបទនេះឲ្យលោកស្តាប់ ហើយឲ្យលោកជួយបញ្ជាក់ជូនយើងខ្ញុំ “ជួរខាងមុខ គឺវាបង្ហាញអំពីស្ថានភាពនេះ ហើយវាមានមូលដ្ឋាននៅគ្រប់វិស័យទាំងអស់ ទាំងសេដ្ឋកិច្ច យោធា ទាំងនៅខាងក្នុង និងនៅក្រៅប្រទេស។ វិស័យទាំងនេះត្រូវបានគ្រប់គ្រង គ្រប់ទិដ្ឋភាពដោយកម្ពុជាប្រជាធិបតេយ្យ ហើយបានធ្វើការទំនាក់ទំនងជាមួយនឹងសមមិត្តគណៈប្រធានរដ្ឋនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៧។ សមមិត្តទាំងអស់នឹងយល់ឲ្យបានច្បាស់តាមរយៈឯកសារនេះ”។ នៅទីនេះគឺយើងមិននិយាយច្រើនអំពីបញ្ហានេះទេ។ ដោយសារលោកបានឃើញឯកសារនេះ លោក នង សុផង់ តើលោកធ្លាប់ឮ ខ្លឹមសារនៃសុន្ទរកថានេះ ដែលធ្វើឡើងដោយគណៈប្រធានរដ្ឋនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ដែរឬទេ?

[១៥:០៨:១៣]

**ផ៖** បាទ ខ្ញុំធ្លាប់បានស្តាប់សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ដែលលោកបានផ្សាយផ្ទាល់ នៅថ្ងៃ៣១ ធ្នូ ១៩៧៧ តាមវិទ្យុជាតិកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ខ្ញុំអានសុន្ទរកថាមួយដែលជារបស់លោក ខៀវ សំផន ហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ទៅលើខ្លឹមសារនៃសុន្ទរកថារបស់លោក ខៀវ សំផន ថាតើវាត្រឹមត្រូវនឹងអ្វីដែលលោកបានស្តាប់តាមរយៈការផ្សព្វផ្សាយនៅក្នុងវិទ្យុដែរឬទេ? ខ្ញុំនឹងអានចំណុចខ្លីមួយចេញពីឯកសារនុ៎ង ឯកសារលេខ D108/43.9។ ចំណុចដែលពាក់ព័ន្ធលេខ ERN នោះគឺ S00008729 ជាអកុសល យើងមិនមានឯកសារនេះជាភាសាខ្មែរ និងបារាំងនោះទេ។ យើងខ្ញុំបានដាក់សំណើសុំបកប្រែរួចមកហើយ។ យើងខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ខ្ញុំអានតែមួយប្រយោគ ឬក៏ពីរប្រយោគតែប៉ុណ្ណោះ ដើម្បីសួរបញ្ជាក់ថាតើខ្លឹមសារនេះសាក្សីបានស្គាល់ និងបានធ្លាប់ឮដែរឬទេ? គឺឯកសារ D108/43/9។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[១៥:១០:២៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សុន្ទរកថានោះរួមមានដូចតទៅ។ ខ្ញុំនឹងអានឲ្យបានយឺតៗ ដើម្បីឲ្យអ្នកបកប្រែ បកប្រែតាមខ្ញុំ ហើយខ្ញុំចង់សួរ តើលោកធ្លាប់ឮដែរឬទេ? ហើយដឹងអំពីខ្លឹមសារនេះដែរឬទេ? "បក្សកុម្មុយនីស្តកម្ពុជា គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា សភាតំណាងប្រជាជនកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យអំពាវនាវឲ្យបក្សទាំងមូល កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់ និងប្រជាជនកម្ពុជាទាំងអស់លើកស្មារតីឲ្យរឹងប៉ឹង ស្មារតីបដិវត្តន៍ឲ្យបានរឹងប៉ឹងបន្ថែមទៀត ហើយនិងបង្កើនកម្លាំង ពង្រីកស្មារតីស្នេហាជាតិ និងពង្រឹងនូវស្មារតីជាតិ ដើម្បីធានា និងពង្រីកនូវផ្លែផ្កាជ័យជម្នះបដិវត្តន៍របស់យើង"។ ខ្ញុំឈប់ត្រង់ចំណុចនេះសិន ហើយបន្តិច ចំណុចនៅក្រោមបន្តិចនោះ គឺសរសេរថា "បក្សកុម្មុយនីស្តកម្ពុជា គឺជាបក្សមួយត្រឹមត្រូវដែលបានដំណើរការដោយជោគជ័យ នៅក្នុងការតស៊ូបដិវត្តន៍មួយយ៉ាងលំបាកលំបិន"។

[១៥:១១:៥៥]

លោក នង សុផង់ ខ្ញុំបានអានចំណុចខ្លឹមសារនៃសុន្ទរកថានេះ តើលោកធ្លាប់ឮ ឬក៏វាស្គាប់ ពេលដែលលោកស្តាប់ទៅ គឺលោកស្គាល់ទៅលើខ្លឹមសារដែលខ្ញុំបានអាននៅក្នុងឆ្នាំ១៩៧៧ ដែលគេថ្លែងការណ៍ដូច្នេះដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ សេចក្តីថ្លែងការណ៍វែងៗដូច្នេះ ខ្ញុំពុំចាំអស់ទេបាទ។

**ស៖** សូមអរគុណ។ យើងនឹងបន្តឈប់ពិនិត្យមើលឯកសារនេះ។ ខ្ញុំនឹងសូមអនុញ្ញាតសួរសារទូរលេខមួយចំនួនតូចទៀត បន្ទាប់មកខ្ញុំនឹងបញ្ជូនទៅលើសារទូរលេខ ឯកសារសារទូរលេខ ហើយខ្ញុំ

នឹងចូលទៅដល់ប្រធានបទមួយទៀតបន្ទាប់។ សារទូរលេខបន្ទាប់មួយទៀត គឺ E3/1076 គឺជាសារទូរលេខចុះថ្ងៃ៨ ខែមេសា ឆ្នាំ១៩៧៨។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំសូមអនុញ្ញាតយកឯកសារជាក្រដាស ដាក់ជូនសាក្សី និងបញ្ចាំង -- សូមអនុញ្ញាតបញ្ចាំងនៅក្នុងកញ្ចក់ទូរទស្សន៍។

[១៥:១៣:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក នង សុផង់ នេះគឺជាឯកសារសារទូរលេខមួយក្នុងចំណោមឯកសារ សារទូរលេខនានាផ្សេងទៀត ដែលយកមកពិភាក្សាជាមួយលោកនៅចំពោះមុខអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដែលឯកសារនេះចុះថ្ងៃទី៨ មេសា ១៩៧៨ ចំណងជើងឯកសារនេះសរសេរថា "ជម្រាបបងជាទីគោរពស្នេហា" ហើយបានចុះហត្ថលេខាដោយលេខ៤៧ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៨។ តើលោកនៅចាំទេ ៤៧ នេះគឺសំដៅទៅលើបុគ្គលណាដែរ?

[១៥:១៤:៣៦]

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំចងចាំបាន ៤៧ គឺជាលេខកូដសម្ងាត់របស់ឯកឧត្តម សុន សេន បាទ។

**ស៖** សូមអរគុណ។ នៅក្នុងចំណុច៣ ខាងដើម គឺគេបានលើកឡើងអំពីប្រតិបត្តិការយោធា គឺខ្ញុំមិនចាំបាច់សង្ខេបទេ គឺឯកសារនេះសរសេរច្បាស់លាស់រួចមកហើយ។ ចំណុច៤ សរសេរថា"សភាពការណ៍ខាងមូលដ្ឋាន យើងបន្តសម្រិតសម្រាំងជាបន្តបន្ទាប់ទៀត។ ចំណុច៥ "ស្អែកសមមិត្ត ចាន់ ទៅជួបបងភឹម"។ តើលោកស្គាល់ទេ នឹកឃើញទេ សមមិត្ត ចាន់ និង បងភឹម នេះសំដៅលើបុគ្គលណាដែរ?

**ឆ៖** ខ្ញុំសមមិត្ត ចាន់ ខ្ញុំមិនស្គាល់។ ឯបងភឹម គឺសំដៅ សោម ភឹម ដែលជាលេខាបក្សភូមិភាគបូព៌ាបាទ។

**ស៖** តើលោកដឹងទេ នៅពេលនិយាយក្នុងចំណុច៤ ថា "ខាងមូលដ្ឋានយើងបន្តសម្រិតសម្រាំងជាបន្តបន្ទាប់ទៀត"នោះ គឺគេចង់បានន័យយ៉ាងម៉េចដែរ? ប្រសិនបើលោកមិនដឹង ក៏មិនជាបញ្ហាអ្វីដែរ

សូមលោកជួយបញ្ជាក់?

**ឆ៖** រឿងសម្រិតសម្រាំងនៅមូលដ្ឋាន ខ្ញុំមិនបានដឹងទេ ពីព្រោះខ្ញុំធ្វើការនៅតែក្នុងការិយាល័យនៅភ្នំពេញឯណោះ។ មិនបានដឹង មិនបានឃើញ ការសម្រិតសម្រាំងជាក់ស្តែងយ៉ាងណាទេ បាទ។

**ស៖** សូមអរគុណ។ យើងកុំពិនិត្យមើលខ្លឹមសារនៃសារទូរលេខនេះ ក៏ប៉ុន្តែយើងមើលខាងឆ្វេងខាងលើបំផុតនៃឯកសារនេះម្តង។ វារាងលុបបន្តិច ដោយមានលេខដាមពីលើ។ ក៏ប៉ុន្តែអ្នកបកប្រែបញ្ជាក់ថា សរសេរហ្នឹង សរសេរថា “បងវ៉ាន់”។ តើត្រឹមត្រូវដែរឬទេ? តើនៅពេលដែលលោកអាននោះនៅខាងឆ្វេងបំផុត ខាងលើនោះ តើគេបានសរសេរ “បងវ៉ាន់” ដូច្នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំឃើញអ៊ីចឹងមែន។

[១៥:១៧:៥៩]

**ស៖** សូមអរគុណ។ នៅក្នុងឯកសារ D200/9 ខ្មែរ 00294541, បារាំង 00374937, អង់គ្លេស 00483969។ លោកបាននិយាយដូចតទៅ “ចំណារសរសេរដោយដៃ សរសេរថា បងវ៉ាន់ នោះ គឺសំដៅលើ អៀង សារី ដែលលោកជារដ្ឋមន្ត្រីការបរទេស។ ចំណារនេះប្រហែលជា ថេរ ជាអ្នកសរសេរ មិនមែន ប៉ុន នោះទេ។ ពួកគេមិនបានដាក់ចម្លងជូនគាត់ ដោយសារតែពេលខ្លះ វាបន្ទាន់ពេក”។

ដូច្នេះតើនេះវាជាការសង្ខេបចម្លើយរបស់លោកនៅចំពោះសហចៅក្រមស៊ើបអង្កេតដែលលោកបានឆ្លើយដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានឆ្លើយដូច្នោះមែន ថា បងវ៉ាន់ គឺ អៀង សារី បាទ។

[១៥:១៩:២៦]

**ស៖** ដើម្បីឲ្យយុត្តិធម៌ យើងខ្ញុំចង់បញ្ជាក់ថា តើយើងយល់យ៉ាងណាដែរ។ លោកបានលើកឡើងថា នេះជាចំណាររបស់ ថេរ។ ដូច្នេះ តើលោកធ្លាប់ឃើញចំណាររបស់ ថេរ នេះញឹកញាប់ដែរឬទេ? ហើយលោកស្គាល់ចំណាររបស់ ថេរ នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដាក់ថា ប្រហែលហ្នឹង គឺបានន័យថា ខ្ញុំមិនសូវច្បាស់បាទ។

**ស៖** សូមអរគុណ។ ប្រសិនបើអាច សូមឲ្យយើងមើលសារទូរលេខចំនួនពីរទៀត ដែលពាក់ព័ន្ធទៅនឹង បងវ៉ាន់។ សារទូរលេខទី១ គឺ E3/936 វាជាឯកសារមួយទៀតដែលលោកបានយកមកពិភាក្សាជាមួយនឹងចៅក្រមស៊ើបអង្កេតផងដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមានឯកសារនេះជាក្រដាសជូនសាក្សីមួយច្បាប់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៥:២១:១៩]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅពេលដែលយើងពិនិត្យមើលឯកសារនេះ លោក សុផង់ សូមឲ្យលោកពិនិត្យមើលខាងឆ្វេង ខាងលើម្តងទៀត។ តើចំណារនេះបានសរសេរថា “បងវ៉ាន់” ដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ បានសរសេរដូចៗគ្នាដែរបាទ។

**ស៖** នៅពេលដែលលោកពិភាក្សាជម្រាបអ្នកស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងឯកសារនេះ លោកបានបញ្ជាក់ថា ឯកសារ D200/9 គឺលេខ E3/67 ខ្មែរគឺមានលេខ 00294535, បារាំង 0030 -- បារាំងមានលេខ 00374932, អង់គ្លេសគឺ 00483964។ លោកបានលើកឡើងថា ចំណារដាក់ថា “បងវ៉ាន់” គឺផ្ញើជូនទៅ អៀង សារី។ សរសេរអក្សរសរសេរដៃចំណារនេះ គឺជាអក្សររបស់ ប៉ុន។ តើត្រឹមត្រូវដែរឬទេ ដែលលោកថាអក្សរដៃនេះ គឺជាអក្សររបស់ ប៉ុន?

**ឆ៖** បាទ នេះគឺជាត្រឹមត្រូវបាទ អក្សរ ប៉ុន។

[១៥:២៣:៣៤]

**ស៖** ឥឡូវនេះ ដើម្បីឲ្យយើងយល់ជ្រួតជ្រាបលើសារទូរលេខនេះ។ យើងឃើញខាងក្រោមខាងស្តាំសរសេរជាភាសាខ្មែរ លោកបានសរសេរថា លោកបានលើកឡើងថា “លោកមិនបានស្គាល់អក្សរសរសេរដៃដែលបានដាក់ថ្ងៃទទួល ហើយនិងម៉ោងនោះទេ”។ តើត្រឹមត្រូវដែរទេ ដែលលោកថាមិនស្គាល់អក្សរសរសេរដៃនេះទេ?

**ឆ៖** បាទ ខ្ញុំមិនស្គាល់មែន ព្រោះអក្សរហ្នឹងប្លែក។ ២) អក្សរដាក់ថា “បងវ៉ាន់”។

**ស៖** សូមអរគុណ។ នៅពេលនេះ យើងខ្ញុំសូមបង្ហាញឯកសារចុងក្រោយមួយទៀត ដែលក្នុងនោះមានចំណារសរសេរដាក់ថា “បងវ៉ាន់”។ គឺឯកសារលេខ E3/812 ជាសារទូរលេខមួយទៀត មកពី

៤៧ ចុះថ្ងៃ២៦ ខែមេសា ឆ្នាំ១៩៧៨។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំមានឯកសារនេះជាក្រដាសមួយច្បាប់ជូនទៅដល់សាក្សី ហើយយើងខ្ញុំក៏សូមអនុញ្ញាតបញ្ចាំងតាមកញ្ចក់ទូរទស្សន៍ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៥:២៥:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

នៅពេលដែលយើងមើលឯកសារនេះ សូមឲ្យខាងបច្ចេកទេសសោតទស្សន៍បញ្ចាំងលើកញ្ចក់ទូរទស្សន៍ផងដែរ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅខាងឆ្វេងខាងលើ គឺយើងចំណារមួយទៀត ដែលសរសេរថា “បងវ៉ាន់” តើត្រូវដែរឬទេលោក នង សុផង់? នង សុផង់ តើមានសរសេរថា “បងវ៉ាន់” អ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** ពាក់ព័ន្ធទៅនឹងអក្សរសរសេរដៃនេះ លោកបានឆ្លើយនៅក្នុងចម្លើយដំបូងរបស់លោក គឺឯកសារ E3/64 ខ្មែរគឺ 00398043, បារាំងគឺ 00411710, អង់គ្លេសគឺ 00334060។ ខ្ញុំសូមដកស្រង់សម្ដី ចំណារនេះដាក់ថា “បងវ៉ាន់ គឺ អៀង សារី គឺជាអក្សររបស់ ប៉ុន ដោយសារតែខ្ញុំធ្លាប់ឃើញអក្សររបស់គាត់នៅពេលដែលគាត់យកឯកសារមកឲ្យខ្ញុំបកប្រែ”។ តើនេះសង្ខេបអ្វីដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតបានត្រឹមត្រូវដែរឬទេ ដែលក្នុងនោះលោកបានលើកឡើងថា លោកស្គាល់ថា អក្សរនេះគឺជាអក្សរដៃរបស់ ប៉ុន?

[១៥:២៧:២៦]

**ឆ៖** បាទ ពិតជាត្រឹមត្រូវបាទ។

**ស៖** តើត្រឹមត្រូវផងដែរឬទេ ដែលថាលោកស្គាល់អក្សរដៃរបស់ ប៉ុន ដោយសារតែនៅក្នុងចម្លើយរបស់លោក លោកបានបានលើកឡើងថា លោកបានឃើញអក្សរដៃរបស់គាត់ញឹកញាប់ណាស់

ដោយសារតែគាត់បានយកឯកសារមកឲ្យលោកបកប្រែ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** តាមការយល់របស់លោកលើការងារ ឬរបៀបរបបធ្វើការងារ តើគេមានហេតុផលអ្វីដែល ប៉ុន នោះតែងញឹកញយណាស់ សរសេរអក្សរដោយដៃរបស់គាត់ ដាក់ថា "បងវ៉ាន់"នោះ?

**ឆ៖** បាទ ហេតុផលដូចជាសារទូរលេខមុនៗដែរ គឺថាសភាពការណ៍ទាំងអស់នេះ គឺវាទាក់ទងនឹងបញ្ហាព្រំដែនរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ ដូច្នេះ ខ្លឹមសារនេះជាគោលការណ៍ គឺលោក ប៉ុន បានដឹងច្បាស់ថា ត្រូវជូនទៅក្រសួងការបរទេសដើម្បីឲ្យលោកបានទទួលព័ត៌មានអំពីសភាពការណ៍នៅតាមព្រំដែន ដែលមានជម្លោះគ្នារវាងវៀតណាម និងកម្ពុជាបាទ។

**ស៖** ខ្ញុំសូមអនុញ្ញាតសួរលោកសំណួរមួយសំណួរទៀត ពាក់ព័ន្ធនឹងចំណុចនេះ។ លោកឃើញហើយនៅខាងក្រោយ ខាងក្រោមឯកសារបំផុតនោះ គឺសរសេរដាក់ថា "ចម្លងជូនអ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ និងឯកសារ"។ ដូច្នេះផ្អែកតាមរបៀបរបបធ្វើការងាររបស់គេនៅពេលនោះ តាមដែលលោកដឹង ដោយសារនៅក្នុងនេះយើងឃើញមាន អ៊ំវ៉ាន់ នៅក្នុងកន្លែងដែលគេដាក់ថា ចម្លងជូន។ ចុះហេតុអ្វីបានជាគេសរសេរចំណារបន្ថែមនៅទំព័រដំបូងដាក់ថា "បងវ៉ាន់" ទៀត?

[១៥:៣០:៣៤]

**ឆ៖** បាទ បញ្ហានេះគឺលោក ប៉ុន គាត់ចង់បញ្ជាក់ច្បាស់ថា រឿងហ្នឹងទាក់ទងនឹងកិច្ចការបរទេស។ អ៊ីចឹងគឺជាការចាំបាច់ណាស់ សង្កត់ហើយ សង្កត់ទៀត កុំឲ្យភ្លេចជូន អ៊ំវ៉ាន់ ហ្នឹង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ជំទាស់នោះទេ ហើយខ្ញុំគិតថា លោកសាក្សីគាត់ដឹងថាគាត់មិនអាចទាយស្មានទេ។ ដូច្នេះគាត់គ្រាន់តែប្រាប់ថា តើ ប៉ុន ធ្វើអ្វីប្រាប់ព័ត៌មានអ្វីដល់គាត់ គាត់គ្រាន់តែប្រាប់ថាគាត់ដឹងដោយរបៀបណាទៅ។ គាត់មិនអាចថា គាត់ដឹងថា ប៉ុន ធ្វើអ្វី គាត់និយាយអ្វីមួយដែលថា និយាយអំពីការដំណើរការការងារ ដែល ប៉ុន បានធ្វើ ដូច្នេះ គាត់ហាក់ដូចជាទាយស្មាន។ ដូច្នេះហើយ ខ្ញុំចង់ឲ្យមានការឆ្លើយឲ្យបានត្រឹមត្រូវ ឬក៏ដើម្បីកុំឲ្យមានការពិចារណាទៅលើអ្វី ដែលជាការប៉ាន់ស្មានហ្នឹង គឺឲ្យដកចម្លើយដែលជាការប៉ាន់ស្មានហ្នឹងចេញពីកំណត់ត្រាទៅ។

**លោក អាប់ឌុលឡាក់ ថារីក៖**

នេះគឺជាមតិប្រហាក់ប្រហែលគ្នា ដែលយើងបានស្តាប់ឮខាងមេធាវីការពារ ខៀវ សំផន បាននិយាយ គឺថាមិនចង់ឲ្យមានការនិយាយអំពីការផ្សព្វផ្សាយ ប៉ុន្តែដោយសារតែឯកសារពីព្រឹកមិញហ្នឹង គឺយើងថាមិនទាន់ ដល់មានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការសាកសួរទៅលើសាក្សី។ ហើយខ្ញុំមានចេតនានឹងសួរសាក្សីទៅលើបញ្ហាមួយចំនួនទាក់ទងទៅនឹងឯកសារដែលយើងនិយាយពីពេលព្រឹកមិញនេះ។ ប៉ុន្តែអ្វីដែលខាងព្រះរាជអាជ្ញាបាននិយាយថា គឺយើងចង់ផ្តែកទៅលើឯកសារនោះដើម្បីឲ្យសាក្សីបង្ហាញពីព័ត៌មានដែលគាត់បានដឹង។

[១៥:៣២:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣២:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្ត! ហើយរំឭកម្តងទៀត សាក្សីសូមចងចាំឲ្យច្បាស់ថា សាក្សីឆ្លើយតែការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ ចងចាំ។ ហើយយ៉ាងតិចបំផុតក៏មានបទពិសោធន៍ផ្ទាល់កាត់ និងការសង្កេតជាក់លាក់នៅអង្គហេតុ ព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ។ នេះជាករណីយកិច្ចនៅក្នុងការឆ្លើយតប។ កាលណាមិនដឹង មិនច្បាស់ទេ អត់អាចប្រើពាក្យ ប្រហែល អាច ឬក៏តាមសេចក្តីសន្និដ្ឋានរបស់ខ្លួនបានទេ។

[១៥:៣៣:៣៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមសួរអំពីបទពិសោធន៍ និងការយល់ដឹងផ្ទាល់ខ្លួនរបស់លោក លោកសាក្សី។ នៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួមជាមួយ ប៉ុន ដែលលោកបានរៀបរាប់ប្រាប់យើងកាលពីព្រឹកមិញនេះ។ តើធ្លាប់មានរបាយការណ៍ ដែលបង្ហាញថា ឯកសារដែលត្រូវផ្ញើជូនអ៊ំៗ មិនត្រូវបានគេបញ្ជូនទៅអ៊ំៗទាំងនោះ តើធ្លាប់មានករណីនេះដែរឬទេ?

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំមិនដឹងបាទ។

**ស៖** ខ្ញុំគ្រាន់តែចង់បញ្ជាក់។ នៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួម ហើយលោកបានពិភាក្សា

ជាមួយ ប៊ុន គឺយើងនិយាយក្នុងពេលដែលលោកធ្វើការជាមួយ ប៊ុន រហូតតែម្តង។ លោកមិនដែលធ្លាប់ឮការនិយាយណាមួយ ដែលថាមានបញ្ហាក្នុងការបញ្ជូនឯកសារ គឺឯកសារមិនត្រូវបានគេបញ្ជូនទៅកាន់អ៊ំៗទាំងនោះ។ តើលោកធ្លាប់ឮពីបញ្ហានេះទេ?

**ឆ៖** បាទ ពេលប្រជុំមិនដែលឮ ប៊ុន លើកបញ្ហានេះទេបាទ។

[១៥:៣៥:០៥]

**ស៖** សូមអរគុណលោក។ ឥឡូវនេះយើងពិនិត្យមើលទៅលើទូរលេខមួយទៀត ហើយទូរលេខនេះប្រហែលជាទូរលេខចុងក្រោយដែលយើងត្រូវពិភាក្សាគ្នា។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺជាឯកសារដែលមានលេខ D200/3.3 គឺឯកសារចុះថ្ងៃទី៧ កក្កដា ឆ្នាំ៧៨។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីប្រគល់ឯកសារជាលាយលក្ខណ៍អក្សរ ជាក្រដាសទៅជូនសាក្សី ហើយសូមអនុញ្ញាតបង្ហាញលើនៅអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៣៦:២១]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នេះ គឺជាឯកសារមួយដែលលោកបានពិភាក្សាជាមួយអ្នកស៊ើបអង្កេតផងដែរ។ គឺជាឯកសារដែលផ្ញើជូនចំពោះក្រុមហ៊ុន រិនហ្វុង ហុងកុង គឺមានលេខយោង 086-HK/78 ហើយចុះហត្ថលេខាដោយ ហ្វ័រត្រា “FORTRA” ភ្នំពេញ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យបង្ហាញឯកសារហ្នឹងនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ ដើម្បីពិនិត្យទៅលើចំណារនៅខាងលើ ខាងឆ្វេង គឺមានចំណារជាលាយលក្ខណ៍អក្សរដែលសរសេរថា “បានផ្ញើជូនបងហែម”។ មើលនឹងច្បាប់ដើម HK សំបុត្រចម្លងឡាំងឈុតគំរូពីរឡាំង ហើយមានចុះហត្ថលេខា និងដាក់ថ្ងៃ ៧-៧ កាលបរិច្ឆេទ ៧-៧”។ នៅពេលដែលលោកមើលទៅលើឯកសារមួយនេះ លោកបាននិយាយនៅក្នុងចម្លើយរបស់លោកគឺឯកសារ E3/64 ខ្មែរ ERN គឺមានលេខ 00328042, ភាសាបារាំងគឺមានលេខ 00041709, ភាសាអង់គ្លេសគឺមាន 00334059។

[១៥:៣៨:២០]

បាននិយាយថា “បងហែម គឺសំដៅទៅលើលោក ខៀវ សំផន។ ទូរលេខមួយនេះគឺនិយាយអំពីពាណិជ្ជកម្ម ហេតុដូច្នេះហើយទើបគេចម្លងជូន ខៀវ សំផន។ ខ្ញុំធ្លាប់ទទួលទូរលេខរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការបញ្ជូនអំបិល។ ប្រហុក និងស្ករ”។ តើអ្វីដែលខ្ញុំនិយាយហ្នឹង គឺជាអ្វីដែលលោកបានជម្រាបសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានជម្រាបដូច្នោះមែន។

**ស៖** សូមអរគុណលោក។ ហើយមានសំណួរពីរនៅខាងក្រោមចម្លើយនោះ គឺគេសួរលោកដូចតទៅនេះ “សំណួរ៖ តើទូរលេខនេះគេនិយាយអំពីការលក់ស្រូវអង្ករឬទេ? ចម្លើយ៖ គឺថាបាទ គឺវា គឺ តារិទ្ធ ជារដ្ឋមន្ត្រីនៅខាងហុងកុងនោះ ជាអ្នកបញ្ជូនទូរលេខនេះ។ ទូរលេខនេះ ប្រហែលជាផ្ញើតាមទូរលេខ ឬក៏ផ្ញើទៅខាងក្រសួងការបរទេស ឬក៏ផ្ញើទៅស្ថានទូត”។ ដោយយើងពិនិត្យទៅលើផ្នែកទី១ ថាតើជាការត្រឹមត្រូវដែរឬទេ ដែលលោកនិយាយថា ទូរលេខនេះ គឺដោយ គឺសរសេរដោយ តារិទ្ធ?

**ឆ៖** អ៊ីចឹងគឺខ្ញុំបាននិយាយជាមួយនិងចៅក្រមស៊ើបអង្កេតហើយ នេះមិនមែនជាអ្វីដែលខ្ញុំធ្វើផ្ទាល់ដោយដៃទេ។ ហើយខ្ញុំបាននិយាយប្រាប់គាត់ថា ពាក្យប្រហែល។ ដូច្នេះ គឺសុំមិនអាចនិយាយបន្តទៀតទេ ខ្លឹមសារនេះ សុំនិយាយថាមិនដឹងទៅវិញ។ ពីព្រោះមិនមែនដែលខ្ញុំធ្វើផ្ទាល់បាទ។

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់លម្អិតទៅលើបញ្ហានេះ គឺធ្វើឲ្យយើងងាយស្រួលយល់ ហើយខ្ញុំសូមបន្តទៅទៀត ដោយខ្ញុំមិនសួរលោកបន្ថែមទៅលើឯកសារនេះទេ។ ឯកសារមួយប្រភេទទៀត ដែលលោកបានពិភាក្សាជាមួយអ្នកស៊ើបអង្កេត គឺឯកសារដែលជារបាយការណ៍ដែលមានប្រវែងទំហំវែង ហើយខ្ញុំចង់បង្ហាញជូនលោក។ ហើយយើងអាចពិភាក្សាឲ្យបានលម្អិតទៅលើឯកសារប្រភេទនោះ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ឯកសារនោះ គឺជាឯកសារដែលមានលេខ E3/951 គឺជាលិខិតទំនាក់ទំនងចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ៧៨ ហើយផ្ញើជូនអង្គការ៨៧០។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីប្រគល់នូវឯកសារក្រដាសជូនទៅសាក្សី ហើយនិងសូមបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមលោកប្រធានអនុញ្ញាត។

[១៥:៤១:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅក្នុងចម្លើយទី២ E3/67 នៅត្រង់សំណួរចម្លើយ ២៧ និង២៨។ លោកបានបញ្ជាក់ដូចតទៅ គឺលោកបញ្ជាក់ថា "អ្នកដែលបញ្ជូនឯកសារនេះ គឺប្រធានតំបន់ពាយ័ព្យ គឺលោកនិយាយថាអ្នកបញ្ជូនហ្នឹង គឺឈ្មោះ ញឹម ប្រធានតំបន់ពាយ័ព្យ ហើយផ្ញើទៅមន្ទីរ៨៧០។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ដែលជូនទៅ គឺអង្គការ៨៧០ គឺជាត្រឹមត្រូវ។ តាញឹម នេះមិនមែនជាគណៈតំបន់ទេ។ គឺជាលេខាភូមិភាគពាយ័ព្យនៅពេលនោះបាទ។

**ស៖** ខ្ញុំគិតថា ប្រហែលជាមានបញ្ហានៅក្នុងការបកប្រែ។ ខ្ញុំក៏ដឹងដែលថា គាត់ជាប្រធានភូមិភាគពាយ័ព្យ។ នៅពេលដែលយើងពិនិត្យទៅលើឯកសារមួយនេះ ខ្ញុំសង្កេតឃើញថា វាមិនមាននូវបទដ្ឋាននៃទូរលេខជាទូទៅ គឺមិនមាននៅក្បាលទំព័រ ថាតើលោកអាចជម្រាបបានដែរឬទេ តើវាជាទូរលេខ ឬមួយក៏ជារបាយការណ៍ជាលាយលក្ខណ៍អក្សរប្រភេទផ្សេងទេ?

[១៥:៤៤:២១]

**ឆ៖** បាទ ឯកសារនេះមិនមែនជាទូរលេខដែលក្រុមខ្ញុំធ្លាប់បកប្រែនោះទេ។ ប្រសិនបើជាសារទូរលេខដែលចេញពីកន្លែងយើងខ្ញុំ ឬក្រុមយើងខ្ញុំ វាមានក្បាល មានក្បាលច្បាស់លាស់។ ទូរលេខប៉ុន្មានហើយទូរលេខទាំងអស់ហ្នឹងប៉ុន្មានខ្ទង់។ អានេះគេតែងតែដាក់ជានិច្ចកាល។ តែនេះគ្មានក្បាល គ្មានខ្ទង់អ្វីទាំងអស់ គ្មានលេខទូរលេខអ្វីទាំងអស់។ ដូច្នេះសារនេះ ពុំមែនជាសារដែលក្រុមយើងខ្ញុំបានធ្វើទេបាទ។

**ស៖** សូមលោកជម្រាបយើង ថាតើឯកសារប្រភេទនេះ គេបញ្ជូនទៅវិញទៅមក គឺថាគេបញ្ជូនទៅអង្គការហ្នឹងតាមរបៀបណាដែរ?

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់នូវវិធីរបស់គេ ដែលគេបញ្ជូនសារនេះទៅអង្គការ៨៧០ តាមវិធីណាទេបាទ។

**ស៖** សូមអរគុណលោក។ នៅក្នុងការងាររបស់លោក ក្នុងនាមជាអ្នកបកប្រែ និងបំភានអក្ខរៈ តើលោកតែងតែបកប្រែនូវឯកសារ ឬក៏នូវទូរលេខដែលបញ្ជូនពីប្រធានភូមិភាគពាយ័ព្យ គឺលោក ញឹម ដែរឬទេ?

[១៥:៤៦:៣៨]

**ឆ៖** បាទ ក្នុងការបកប្រែ ខ្ញុំធ្លាប់បានឃើញហត្ថលេខាលោក ញ៉ឹម ដែរ ប៉ុន្តែមិនមែនមានលក្ខណៈសារហ្នឹងវែងៗដូច្នេះទេ ជាសារខ្លីៗបាទ។

**សៈ** ដោយសារតែនេះ គឺជាលិខិតទំនាក់ទំនងពីលោក ញ៉ឹម។ ខ្ញុំចង់ដឹងថាតើ ខ្លឹមសារនៃលិខិតនេះមានលក្ខណៈប្រហាក់ប្រហែលជាមួយនឹងសារទូរលេខដែលលោកបានបកប្រែដែរឬអត់? ប្រសិនបើយើងមើលទៅលើទំព័រជាភាសាខ្មែរមានលេខ 00021043, ភាសាបារាំងគឺមានលេខ 00296222, និងភាសាអង់គ្លេសមានលេខ 00185216។ គឺមានផ្នែកមួយដែលចាប់ផ្ដើមត្រង់លេខ២ "ស្ថានភាពរស់នៅរបស់ប្រជាជន" ហើយរបាយការណ៍បានដកស្រង់ដូចតទៅនេះ៖ "នៅក្នុងភូមិភាគ ការខ្វះខាតគឺបីតំបន់។ មួយបួកបួន បួកប្រាំ។ ទាំងអស់តំបន់៥ ខ្វះជាងគេ រួចមកតំបន់១, តំបន់៤"។ គេបានបញ្ជាក់ថា តំបន់៥ ថាខ្វះខាតទាំងបួនស្រុក។ ហើយឯកសារបានពណ៌នាបន្តទៅទៀតអំពីការបែងចែកទៅឲ្យប្រជាជននៅអង្ករមួយកំប៉ុង ឬមួយកំប៉ុងកន្លះ។ ប្រសិនបើយើងមើលទៅលើឯកសារនេះ គឺទៅមើលទៅលើខ្លឹមសារនៃឯកសារនេះ ថាតើទូរលេខដែលលោកធ្លាប់បកប្រែ ធ្លាប់ពិភាក្សាអំពីបញ្ហាប្រហាក់ប្រហែលគ្នា គឺបញ្ហាខ្វះខាតម្ហូបអាហារនេះដែរឬទេ?

[១៥:៤៨:២២]

**ឆ៖** បាទ មិនមែនតែភូមិភាគមួយទេដែលរាយការណ៍អំពីជីវភាពប្រជាជន ឲ្យបាន -- មកថ្នាក់លើឲ្យបានដឹង គឺមានភូមិភាគជាច្រើន និងតំបន់ខ្លះទៀតក៏គេរាយការណ៍ប្រហាក់ប្រហែលគ្នាដូច្នេះដែរបាទ។

**សៈ** ដើម្បីបញ្ជាក់ឲ្យច្បាស់ថាខ្ញុំយល់ថាអ្វីដែលលោកនិយាយ គឺថាស្ថានភាពប្រហាក់ប្រហែលគ្នា គឺកង្វះខាតម្ហូបអាហារនេះ គឺត្រូវបានគេរាយការណ៍តាមសារទូរលេខ។ ហើយលោកធ្លាប់បកប្រែនូវឯកសារដែលនិយាយពីខ្វះខាតហ្នឹង មិនមែនត្រឹមតែភូមិពាយ័ព្យទេ គឺនៅគ្រប់ភូមិភាគទាំងអស់។ តើមែនដែរឬទេ?

**ឆ៖** បាទ របាយការណ៍វាមិនដូចគ្នាទាំងស្រុងទេ។ តំបន់ខ្លះគេថា ជីវភាពប្រជាជនបានធូរធារ ហើយការធ្វើស្រែចម្ការបានភោគផលច្រើន។ កន្លែងខ្លះមួយហិកតាបីតោន ឬរហូតទៅដល់កន្លែងខ្លះទៀតបានទៅដល់ ១០តោននោះក៏មានដែរបាទ។

[១៥:៥០:៥៥]

**ស៖** សូមអរគុណ។ ឥឡូវនេះយើងត្រឡប់ទៅលើផ្នែកមួយទៀតនៃឯកសារមួយនេះ ហើយឯកសារនេះគឺមានលេខ គឺនៅទំព័រទី៣ ជាបីភាសា -- ទំព័រទី១ ជាបីភាសា គឺផ្នែកដែលមានចំណងជា "ខ្មាំងផ្ទៃក្នុងនៅក្នុងប្រទេស"។ ខ្ញុំសូមអាននូវការដកស្រង់ដោយសង្ខេប "ក្នុងតំបន់ គឺថាខ្មាំងផ្ទៃក្នុងបានមកនៅថ្ងៃ៥ ខែ៥ ហើយបានសម្រេចក្នុងការនាំប្រជាជនទៅជាមួយពួកគេ។ ក៏ប៉ុន្តែនៅពេលដែលពួកគេចាកចេញជាមួយនឹងមនុស្សជាង៥០នាក់ យើងកម្ទេចពួកគេទាំងអស់ ហើយមានតែពីរនាក់ប៉ុណ្ណោះដែលបានរត់ចេញ ហើយយើងកំពុងតាមចាប់។ នៅក្នុងតំបន់៤, ៥ និង៣ ដូចគ្នានេះដែរ គឺមានការរត់គេចរបស់ប្រជាជនដោយខ្មាំង។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងកម្ទេចខ្មាំងពួកនោះបានសឹងតែទាំងអស់"។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បង្ហាញ ថាតើក្នុងទូរលេខដែលលោកធ្លាប់ធ្វើការបកប្រែ តើធ្លាប់មាននៅបញ្ហាប្រហាក់ប្រហែលគ្នា គឺការរាយការណ៍អំពីព័ត៌មានខ្មាំងខាងក្នុង ដែលមកនាំប្រជាជឲ្យរត់គេចហើយបន្ទាប់មកត្រូវបានគេដេញចាប់? តើធ្លាប់មានបញ្ហានេះដែរឬទេ?

**ឆ៖** បាទ ក្នុងចម្លើយរបស់ខ្ញុំជាមួយចៅក្រមស៊ើបអង្កេត ខ្ញុំនិយាយពាក្យនៅក្នុងខ្លឹមសារដែលលោកសួរអម្បាញ់មិញនេះ វាប្រហែល វាស្មាន គឺច្រើនណាស់។ ដូច្នេះមិនអាចយកជាការបានទេបាទ។

**ស៖** សូមអរគុណ ដែលលោកបានបញ្ជាក់ច្បាស់។ ឥឡូវនេះខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំចង់សួរលោកអំពីសំណួរពីរបី ទាក់ទងទៅនឹងការរៀនសូត្រ វគ្គរៀនសូត្រដែលលោកបានចូលរួម។ លោកបានបញ្ជាក់រួចហើយថា លោកធ្លាប់ចូលរួមនៅវគ្គរៀនសូត្រ ហើយវគ្គមួយចំនួនពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេស ហើយវគ្គមួយចំនួននិយាយអំពីបញ្ហានយោបាយ។ តើលោកធ្លាប់ចូលរួមវគ្គរៀនសូត្រហ្នឹងនៅកន្លែងណាខ្លះ? តើមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** បាទ វគ្គរៀនសូត្រមានពីរកន្លែង។ មួយនៅអតីតសាលាបច្ចេកទេសសូវៀតបាទ និងមួយទៀតសាលារៀនសូត្រនយោបាយ ដែលសម្រាប់ទូទាំងប្រទេស គឺនៅបុរីកីឡាបាទ។

[១៥:៥៤:៣៨]

**ស៖** តើលោកអាចជម្រាបបានដែរឬទេ ថាតើអ្នកណាជាអ្នកបង្រៀនវគ្គរៀនសូត្រនៅអតីតវិទ្យាស្ថានសូវៀត? តើអ្នកណាជាអ្នកបង្រៀន?

**ឆ៖** បាទ អ្នកបង្រៀនគឺលោក ប៉ង់ ហើយនិងលោក ភុំ បាទ ជាអ្នកបង្រៀនផ្នែកនយោបាយ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ថា ខ្ញុំទទួលបានចម្លើយគឺថា អ្នកបណ្ដុះបណ្ដាលគឺឈ្មោះ ប៉ង់ ថាតើ ប៉ង់ ហ្នឹងគឺជាបុគ្គលតែមួយ ដែលលោកបានស្គាល់នៅពេលដែលលោកធ្វើការនៅ ប-២០ តើជាមនុស្ស

តែមួយ មែនដែរឬទេ?

[១៥:៥៥:៣២]

**ឆ៖** បាទ ប៉ង់ នេះគឺជាមនុស្សតែមួយ ដែលខ្ញុំបានធ្លាប់ជួបនៅ ប-១៧ តាំងពីខ្ញុំមកដល់ ប-១៧ ប៉ង់ ហ្នឹងក៏បានបំពាក់បំប៉ននយោបាយខ្ញុំ ហើយរហូតមកដល់ភ្នំពេញគឺ ប៉ង់ ហ្នឹងដដែលបាទ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ យើងពិនិត្យមើលទៅលើទីតាំងមួយទៀត គឺនៅបុរីកីឡា។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាលោកធ្លាប់ចូលរួមវគ្គអប់រំនៅបុរីកីឡាផងដែរ?

**ឆ៖** បាទ ភាគច្រើន ខ្ញុំមិនដែលបានប្រជុំធំដុំអីនៅបុរីកីឡាទេ តែលោកសួរថា កន្លែងណាខ្លះ? ខ្ញុំក៏ឆ្លើយថា បុរីកីឡាទៅ។ តាមពិត គឺការដែលខ្ញុំបានរៀន គឺនៅសាលាបច្ចេកទេសសូវៀតបាទ។

**ស៖** សូមអរគុណ។ តើការបង្រៀននៅវិទ្យាស្ថានមិត្តភាពសូវៀតហ្នឹង តើ ប៉ង់ គាត់បង្រៀនពីប្រធានបទអ្វីដែរ?

**ឆ៖** បាទ ការបង្រៀនរបស់ ប៉ង់ គឺថាវាស៊ីគ្នានឹងសេចក្តីថ្លែងការណ៍របស់គណៈប្រធានរដ្ឋ ហើយក៏វាស៊ីគ្នានឹងសេចក្តីណែនាំរបស់៨៧០ ដែលជាឯកសារដែលលោកបង្ហាញស្រាប់មកហើយ។

**ស៖** គឺឯកសារដែលនិយាយអំពីជម្លោះជាមួយវៀតណាម តើមានប្រធានបទអ្វីផ្សេងទៀត ក្រៅពីជម្លោះជាមួយវៀតណាម ដែលបានពិភាក្សានៅក្នុងវគ្គនោះ?

**ឆ៖** បាទ សូមបញ្ជាក់ថា ខ្លឹមសារមិនមែនតែរឿងមួយទេ គឺនិយាយអំពីគ្រប់ទិដ្ឋភាពទាំងនយោបាយ សេដ្ឋកិច្ច យោធា ក្នុងប្រទេស និងក្រៅប្រទេសបាទ គឺថាសភាពការណ៍រួមទូទៅបាទ។

**ស៖** តើលោកចាំដែរឬទេថាមានឯកសារជាលាយលក្ខណ៍អក្សរ ដែលគេប្រើប្រាស់នៅក្នុងវគ្គរៀនសូត្រនោះ ថាតើគេមានផ្តល់ឯកសារជាលាយលក្ខណ៍អក្សរ ឬមួយគេមានអានឯកសារអ្វីទេ នៅក្នុងវគ្គរៀនសូត្រទាំងនោះ?

[១៥:៥៩:១២]

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ។ ហើយក៏គ្មានអ្វី ជាលាយលក្ខណ៍អក្សរ សម្រាប់ជាកំណត់ហេតុឲ្យខ្ញុំរក្សាទុករហូតដល់ថ្ងៃនេះទេបាទ។

**ស៖** ខ្ញុំសូមសួរលោក ដូចតទៅនេះ នៅពេលនោះគឺនៅក្នុងឆ្នាំ៧៥ ដល់ ៧៩ តើលោកគឺជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ឬមួយក៏នៅក្នុងយុវកកដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនទាន់បានចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ គឺគ្រាន់តែជាសមាជិកសម្ព័ន្ធ

យុវជន ហៅថា យុវកកហ្នឹងបាទ។

**ស៖** សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នៅពេលនេះ ខ្ញុំចង់លើកយកប្រធានបទថ្មី ប៉ុន្តែខ្ញុំមើលទៅម៉ោងថា តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តប្រធានបទថ្មី ឬមួយក៏ខ្ញុំសូមត្រូវបញ្ចប់ត្រឹមចំណុចនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ ហើយសម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៤ ខែកញ្ញា ឆ្នាំ២០១២ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្ម នង សុផង់ ដែលនឹងបន្តការតាំងសំណួរដេញដោល ដោយតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមភាគី និងសាធារណជនជ្រាប ហើយសូមបញ្ជាក់បន្ថែមថា នៅក្នុងថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងដំណើរសវនាការស្ដាប់សក្ខីកម្មសាក្សីរូបនេះ តែមួយព្រឹកតែប៉ុណ្ណោះ។

[១៦:០១:១៧]

លោក នង សុផង់ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ សក្ខីកម្មត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្ម នៅថ្ងៃស្អែកទៀតដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទាប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនគាត់ទាំងបីនាក់មកកាន់បន្ទាប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*